# ខ្មែរ

高棉

Khmer



2/2015 NO.41

ISSN 2095-249X

ខ្មែរ 高棉 2/2015 NO.41



# 读《高棉》看中国

中柬友谊的桥梁　文化交流的纽带　友好往来的使者　经贸合作的平台

# អានទស្សនាវដ្ដី “ខ្មែរ” ទស្សនាប្រទេសចិន

ស្ពានមិត្តភាពចិន-កម្ពុជា ចំណងផ្លាស់ប្ដូរខាងវប្បធម៌ បេសកជនមេត្រីភាព វេទិកាសហប្រតិបត្តិការខាងសេដ្ឋកិច្ចនិងពាណិជ្ជកម្ម




**主管：**中华人民共和国国务院新闻办公室　**主办：**云南省人民政府新闻办公室　**编辑出版：**《高棉》杂志社

**社址：**中国云南省昆明市环城西路577号　**邮编：**650034　**E-mail：**magazinekh@163.com

**编辑部电话：**86-871-64181611（传真）　**办公室电话：**86-871-64101644　**发行部电话：**86-871-64101727

**KAI WAH PLAZA**
**INTERNATIONAL HOTEL**
KUNMING
佳华广场酒店
★★★★★
中国 · 昆明



The Kai Wah Plaza International Hotel is located in the city center of Kunming, the "Spring City" of China. The property offers spectacular views of both the city and surrounding mountains. Located only 15 minutes from Kunming International Airport, this hotel is the ideal venue to organize your corporate stay, conference, tour, exhibition, or other social events. This 5 star property is the only hotel in Kunming with a western General Manager. The hotel has 525 elegant guest rooms, including 163 suites. The Kai Wah Tower Floors are our exclusive new facilities, guaranteeing maximum convenience to the discerning traveler. The hotel's meeting facilities are the best among the most extensive in the city and boast an 880 square meter ballroom.

KAI WAH PLAZA
INTERNATIONAL HOTEL









TEL:86-871-3562828
FAX:86-871-3561818
No.157 Beijing Road,Kunming,China
Website:http://www.kaiwahplaza.com

# 云南建工集团有限公司

## ក្រុមហ៊ុន YUNNAN CONSTRUCTION ENGINEERING GROUP CO., LTD.

云南建工集团有限公司是在云南建工集团总公司基础上，于2009年11月6日改制而成。目前，集团已发展成为集工程总承包、房地产开发、城市建设投资开发、建筑工程施工、机电设备安装、商品混凝土生产、路桥市政工程施工、钢结构工程施工、水利水电工程施工、地基工程施工、建材与设备供销、建筑科研、勘察设计、建筑劳务于一体的多层次大型企业集团；是云南省政府国资委履行出资人职责的20户省管企业和15户省属重要骨干企业之一。集团现有全资子公司、控股公司和直管企事业单位31个；现有在职职工16000人，各类专业技术人员7797人，其中具有高级职称751人。

近年来，集团努力进行结构调整，千方百计拓展市场，综合实力显著增强，为云南的经济建设和社会发展做出了显著贡献。2013年完成总产值434.23亿元，完成竣工面积828.1万平方米。科技水平显著提高，国际市场的开拓能力不断增强。截至2013年12月，集团累计获得全国建筑工程鲁班奖22项，国家优质工程银质奖32项，詹天佑土木工程大奖提名奖1项，全国用户满意工程13项，全国和省级以上科技进步奖400多项，获部省级优质工程奖390项，连续9次入选中国承包商60强。截至2013年9月，集团公司连续22次入选中国企业500强。集团先后在也门、南非、泰国、老挝、乌干达、伊拉克、马尔代夫、毛里求斯、赤道几内亚、柬埔寨等国家承接各类工程，并荣获老挝政府颁发的“发展勋章”、“劳动勋章”等荣誉。2010年至2013年，集团公司连续四年进入美国《工程新闻记录》（ENR）杂志全球最大225家国际承包商排行榜，创造了良好的国际声誉。集团以高效、优质的服务和重合同、守信用的严谨作风，赢得了广大客户、行业主管部门、金融机构的充分信赖，连年被评为AA级企业，享有较高的商誉，“云南建工”品牌已经成为国内建筑业界的知名品牌。

在实现较快发展的基础上，集团全力加快战略转型的步伐，加快企业的股份制改造，将集团进一步发展成拥有设计、科研、施工、咨询、投融资建设一体化发展能力的核心竞争力更强的现代大型建筑企业集团和中国西部一流建工集团。

ក្រុមហ៊ុន YUNNAN CONSTRUCTION ENGINEERING GROUP CO., LTD. (YCEG) គឺជាក្រុមហ៊ុនមួយដែលត្រូវបានបង្កើតឡើងដោយកែសម្រួលរចនាសម្ព័ន្ធពីក្រុមហ៊ុន YUNNAN CONSTRUCTION ENGINEERING GROUP CORPORATION នៅថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។ សព្វថ្ងៃ ក្រុមហ៊ុននេះបានក្លាយជាក្រុមហ៊ុនគ្រុបខ្នាតធំដែលប្រមូលផ្តុំនូវមុខងារចម្រុះ ដូចជាម៉ៅការធ្វើវិស្វកម្ម អភិវឌ្ឍន៍អចលនវត្ថុ វិនិយោគនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុង អនុវត្តការសាងសង់ដំឡើងគ្រឿងបរិក្ខារអគ្គិសនី ផលិតបេតុង សាងសង់ស្ពាននិងផ្លូវថ្នល់ អនុវត្តវិស្វកម្មគ្រោងដែកថែប អនុវត្តវិស្វកម្មធារាសាស្ត្រនិងវារីអគ្គិសនី អនុវត្តការសាងសង់គ្រឹះអគារលក់ដូរសម្ភារៈសំណង់និងបរិក្ខារស្រាវជ្រាវអំពីវិទ្យាសាស្ត្រស្ថាបត្យកម្មគូរប្លង់ខាងស្ថាបត្យកម្ម និងផ្តល់ពលកម្មសាងសង់ជាដើម ។វាជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនទាំង ២០ ដែលមានគណៈកម្មាធិការគ្រប់គ្រងទ្រព្យសម្បត្តិជាតិខេត្តយូណានជាអ្នកវិនិយោគនិងជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនសំខាន់ទាំង ១៥ នៃខេត្តយូណាន ។ បច្ចុប្បន្ន ក្រុមហ៊ុន YCEG មានសាខាក្រុមហ៊ុនកាន់កាប់ភាគហ៊ុននិងអង្គភាពក្រោមចំណុះផ្ទាល់ចំនួន ៣១ និងមានបុគ្គលិកការងារ ១៦000 នាក់ អ្នកបច្ចេក-ទេសចំនួន ៧៧៩៧ នាក់ ព្រមទាំងអ្នកជំនាញការចំនួនជាង ៧៥១ រូប ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ក្រុមហ៊ុន YCEG បានខិតខំកែសម្រួលរចនាសម្ព័ន្ធពង្រីកទីផ្សារដោយពេញទំហឹង ដែលបានធ្វើឱ្យក្រុមហ៊ុនមានសមត្ថភាពចម្រុះកាន់តែខ្លាំងឡើងៗ និងបានចូលរួមចំណែកជាច្រើនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចនៃខេត្តយូណាន ។ នៅឆ្នាំ ២០១៣ ក្រុមហ៊ុន YCEG បានសម្រេចផលិតកម្មតម្លៃសរុប ៤៣៤២៣ លានយ៉ាន់ប្រាក់ចិន និងបានបញ្ចប់ការសាងសង់ជាស្ថាពរ ដែលមានទំហំសរុប ៨,២៨១ លានម៉ែត្រការ៉េ ។ អាស្រ័យលើនេះ ក្រុមហ៊ុន YCEG មានកម្រិតបច្ចេកទេសវិទ្យាសាស្ត្រកាន់តែខ្ពស់ឡើងនិងមានសមត្ថភាពកាន់តែខ្លាំងសម្រាប់ពង្រីកទីផ្សារអន្តរជាតិ ។ គិតមកទល់ខែធ្នូ ឆ្នាំ ២០១៣ ក្រុមហ៊ុន YCEG បានទទួលនូវរង្វាន់វិស្វកម្មស្ថាបត្យកម្មលូបាន ថ្នាក់ជាតិចំនួន ២២ រង្វាន់ប្រាក់វិស្វកម្មគុណភាពខ្ពស់ចំនួន ៣២ រង្វាន់លើកឈ្មោះនៃរង្វាន់វិស្វកម្មសាងសង់ ចានធានអ៊ីវ ចំនួន ១ រង្វាន់វិស្វកម្មទទួលការពេញចិត្តពីអាតិថិជនទូទាំងប្រទេសចំនួន ១៣ រង្វាន់រីកចម្រើនខាងវិទ្យាសាស្ត្រថ្នាក់ជាតិនិងថ្នាក់ខេត្តចំនួនជាង ៤០០ និងរង្វាន់វិស្វកម្មគុណភាពខ្ពស់ថ្នាក់ខេត្ត និងថ្នាក់ក្រសួងចំនួន ៣៩០ ព្រមនិងបានត្រូវជ្រើសរើសជាក្រុមហ៊ុនម៉ៅការខ្លាំងទាំង ៦០ របស់ប្រទេសចិន ៩ លើកជាប់គ្នា ។ គិតមកទល់ខែកញ្ញា ឆ្នាំ ២០១៣ ក្រុមហ៊ុន YCEG បានជាប់ឈ្មោះជាសហគ្រាសខ្លាំងទាំង ៥០០ របស់ចិន ២២ លើកជាប់គ្នា ។ ក្រុមហ៊ុន YCEG ធ្លាប់បានទទួលបន្ទុកធ្វើវិស្វកម្មគ្រប់ប្រភេទនៅប្រទេសច្រើនលើពិភពលោកដែលរួមមានប្រទេសយ៉េមែន អាហ្វ្រិកខាងត្បូង ថៃ ឡាវ អ៊ូហ្គង់ដា អ៊ីរ៉ាក់ ម៉ាល់ឌីវ ម៉ូរីស ហ្គីណេអេក្វាទ័រនិងកម្ពុជាជាដើម ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុន YCEG ក៏បានទទួលមេដាយអភិវឌ្ឍន៍ មេដាយពលកម្ម និងកិត្តិយសមួយចំនួនទៀតពីរដ្ឋាភិបាលឡាវដែរ ។ ក្នុងអំឡុងពេលពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៣ ក្រុមហ៊ុន YCEG បានត្រូវដាក់បញ្ចូលក្នុងបញ្ជីក្រុមហ៊ុនម៉ៅការអន្តរជាតិធំជាងគេទាំង ២២៥ លើពិភពលោកក្នុងទស្សនាវដ្តី“កំណត់ហេតុអំពីព័ត៌មានវិស្វកម្ម”(ENR)របស់សហរដ្ឋអាមេរិកក្នុងរយៈពេល ៤ ឆ្នាំជាប់ ដែលបានធ្វើឱ្យក្រុមហ៊ុនមានកិត្តិនាមល្អប្រសើរលើឆាកអន្តរជាតិ ។ ជារួម ក្រុមហ៊ុន YCEG បានទទួលនូវការជឿទុកចិត្តយ៉ាងពេញលេញពីសំណាក់អាតិថិជនស្ថាប័នគ្រប់គ្រងនិងគ្រឹះស្ថានហិរញ្ញវត្ថុ ដោយផ្អែកលើសេវាកម្ម ដែលមានគុណភាពនិងប្រសិទ្ធភាពខ្ពស់ ព្រមទាំងរចនាបថស្មោះត្រង់ ។ ជាពិសេស ក្រុមហ៊ុន YCEG បានត្រូវបោះឆ្នោតជ្រើសរើសជាសហគ្រាសថ្នាក់ AA ជាច្រើនជាប់និងមានឈ្មោះល្បីខាងពាណិជ្ជកម្ម ដោយបានធ្វើឱ្យ “YCEG” (ក្រុមហ៊ុនស្ថាបត្យកម្មយូណាន)ក្លាយជាម៉ាកល្បីឈ្មោះមួយលើវិស័យស្ថាបត្យកម្មក្នុងប្រទេសចិន ។

ដោយឈរលើមូលដ្ឋានរីកចម្រើនយ៉ាងឆាប់រហ័ស ក្រុមហ៊ុន YCEG បានផ្តោតការយកចិត្តទុកដាក់លើការពន្លឿនដំណើរផ្លាស់ទម្រង់ជាយុទ្ធសាស្ត្រ ជំរុញការកែទម្រង់សហគ្រាសទៅជារបបភាគហ៊ុន ដើម្បីកសាងក្រុមហ៊ុន YCEG ឱ្យទៅជាសហគ្រាសស្ថាបត្យកម្មទំនើបខ្នាតធំ ដែលមានសមត្ថភាពចម្រុះខ្លាំងក្លាដោយប្រមូលផ្តុំនូវការគូរប្លង់ស្រាវជ្រាវវិទ្យាសាស្ត្រអនុវត្តការសាងសង់ពិគ្រោះយោបល់និងធ្វើវិនិយោគ ព្រមនិងជាសហគ្រាសស្ថាបត្យកម្មលំដាប់ថ្នាក់លេខ ១ នៅតំបន់ខាងលិចប្រទេសចិន ។



**អ្នកគ្រប់គ្រងទូទៅ :** ការិយាល័យព័ត៌មាននៃក្រុមប្រឹក្សាកិច្ចការរដ្ឋ សាធារណរដ្ឋប្រជាមានិតចិន
**អ្នករៀបចំ :** ការិយាល័យព័ត៌មានសាលាខេត្តយូណាន
**អ្នកជួយរៀបចំ :** ក្រុមហ៊ុន YUNNAN CONSTRUCTION ENGINEERING GROUP CO., LTD.
**អ្នករៀបរៀងនិងបោះពុម្ពផ្សាយ :** ទីភ្នាក់ងារទស្សនាវដ្ដី "ខ្មែរ"
**អគ្គទីប្រឹក្សា :** ZHAO JIN MAOWENGUO
**ទីប្រឹក្សា :** YANG WENHU XUAN YUCAI CAI CHUNSHENG ZHANG RUICAI LI LIANBIN LIU RONG
**នាយកទីភ្នាក់ងារ :** LI QIAN
**នាយករង :** GUO JIANCHU WU JINGBO TIAN HUQING HAIJIANG
**អគ្គនិពន្ធនាយក :** YANG YUN
**ប្រធានការិយាល័យនិពន្ធទូទៅ :** YU ZHENGYU **អនុប្រធានការិយាល័យនិពន្ធទូទៅ :** WANG WEIYUN
**ប្រធានការិយាល័យផ្នែកនិពន្ធ :** WANG ZHIQIAN LI KE
**អនុប្រធានផ្នែកនិពន្ធទស្សនាវដ្ដី"ខ្មែរ" :** SHEN YAN
**អ្នកនិពន្ធភាសាចិន :** LI QIUJU
**អ្នកនិពន្ធភាសាខ្មែរ :** LIU RONG
**អ្នកពិនិត្យការបកប្រែ :** LU YUCHU ស្វាយ ណារិន
**អ្នកពិនិត្យនិងសម្រួលការបកប្រែ(ជនជាតិខ្មែរ) :** ស៊ីឡេង
**បកប្រែ :** វិទ្យាស្ថានភាសាអាស៊ីអាហ្វ្រិកនៃសកលវិទ្យាល័យភាសាបរទេសប៉េកាំង LIXUANZHI
**រចនារូបភាព :** LIU FAN
**អ្នកត្រួតពិនិត្យប្រព័ន្ធបណ្ដាញ :** ZHANG SHOUYI
**ជំនួយការ :** ZHANG JUNHONG
**អនុប្រធានផ្នែកប្រព័ន្ធបណ្ដាញ :** LI TAO
**អ្នករៀបរៀងប្រព័ន្ធបណ្ដាញ :** LI WENJUN SHI YANQIONG
**ប្រធានផ្នែកបោះពុម្ពផ្សាយ :** ZOU HEPING **បោះពុម្ពផ្សាយ :** CHEN LONG
**អ្នកចូលរួមការរៀបរៀង :** LU RUI HE RULAN
**អាស័យដ្ឋាន :** ផ្ទះលេខ ៥៧៧ ផ្លូវហ្វួនឈឹងស៊ី ទីក្រុងគុនមិញ ខេត្តយូណាន ប្រទេសចិន
**លេខកូដប្រៃសណីយ៍ :** ៦៥០០៣៤
**លេខទូរស័ព្ទនិងទូរសារផ្នែកនិពន្ធ :** ៨៦-៨៧១-៦៤១៨១៦១១
**លេខទូរស័ព្ទការិយាល័យ :** ៨៦-៨៧១-៦៤១០១៦៤៤
**អ៊ីម៉ែល :** magazinekh@163.com
**គេហទំព័រ :** http://www.yunnangateway.com
**អាសយដ្ឋាននៃទីស្នាក់ការអ្នកយកព័ត៌មានប្រចាំនៅរាជធានីភ្នំពេញរបស់ទស្សនាវដ្ដី"ខ្មែរ" :**
ផ្ទះលេខ ១៥ ផ្លូវ ៦០៤ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**ទូរស័ព្ទលេខ :** ០០៨៥៥-០១២៩៨២០៦៥
**ទូរសារលេខ :** ០០៨៥៥-០២៣៨៨៤០២៨
**លេខទូរស័ព្ទផ្នែកបោះពុម្ពផ្សាយ :** ៨៦-៨៧១-៦៤១០១៧២៧
**ក្របខ័ណ្ឌនៃការចែកចាយ :** បោះពុម្ពផ្សាយនិងចែកចាយជាសាធារណៈនៅក្នុង និងក្រៅប្រទេសចិន
**លេខកូដបោះពុម្ពផ្សាយតាមប្រៃសណីយ៍ :** ៦៤-៣៧
**ថ្ងៃ-ខែ-ឆ្នាំបោះពុម្ពផ្សាយ :** ថ្ងៃទីមួយប្រចាំខែ
**លេខស្តង់ដារអន្តរជាតិ :** ISSN 2095-249X
**លេខក្នុងប្រទេសចិន :** CN 53-1219/C
**លេខអាជ្ញាប័ណ្ណផ្សាយពាណិជ្ជកម្ម :** ៥៣០០០០៤០០០០៩៤
**បោះពុម្ពដោយ :** រោងបោះពុម្ពចូលីង ទីក្រុងគុនមិញ
**តម្លៃកំណត់ :** ១៥ យាន់(ប្រាក់ចិន)



ទេដ្ឋភាពទូទៅនៃផ្លូវពាងជៀវ ទីក្រុងថៃយាន ខេត្តសានស៊ី
山西省太原市并州路360°全景 cfp 图

主管：中华人民共和国国务院新闻办公室
主办：云南省人民政府新闻办公室
协办：云南建工集团有限公司
编辑出版：《高棉》杂志社

总顾问：赵 金 卯稳国
顾问：杨文虎 宣宇才 蔡春生 张瑞才
李联斌 刘 荣
社长：李 茜
副社长：郭建初 吴静波 田虎青 海 江
总编辑：杨 云
总编室主任：禹正玉 副主任：汪伟云
编辑总监：王志谦 李 可
编辑部副主任：沈 燕
中文编辑：李秋菊
柬文编辑：刘 蓉
译审：陆禹初 Svay Narin
外籍审稿：SY LENG
翻译：北京外国语大学亚非学院 李轩志
美术设计：刘 帆
网络总监：张守义
总监助理：张俊宏
网络部副主任：李 涛 网络编辑：李文君 施艳琼
发行部主任：邹和平 发行：陈 龙
编务：陆 蕊 何如兰

社址：中国云南省昆明市环城西路577号
邮编：650034
编辑部电话：86-871-64181611（传真）
办公室电话：86-871-64101644
E-mail：magazinekh@163.com
http：//www.yunnangateway.com
金边记者站：柬埔寨王国金边市堆谷区万谷湖一分区604路15号
电话：00855-012982065 023884028（传真）

发行部电话：86-871-64101727
发行范围：国内外公开发行
邮发代号：64-37
出版日期：每月1日
国际标准刊号：ISSN 2095-249X
国内统一刊号：CN 53-1219/C

广告经营许可证号：5300004000094
印刷：昆明卓林包装印刷有限公司
定价：15元（人民币）

# មាតិកា 目 录



**06 អត្ថបទពិសេសប្រចាំលេខនេះ 本期特稿**

06 ប្រមូលផ្តុំដួងចិត្តម៉ាកាវ រួមគ្នាសម្រេចសុបិនចិន អបអរសាទរខួបទី ១៥ ឆ្នាំនៃការវិលត្រឡប់មកប្រទេសចិនវិញរបស់ម៉ាកាវ
10 ឯកឧត្តមនាយករដ្ឋមន្ត្រីចិន លី ខឺឈាំង មានវត្តមានក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គលើកទី ៥
12 ឯកឧត្តម យ៉ាង ជីឈី ចូលបង្គំគាល់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងចូលជួបសម្តែងការគួរសមជាមួយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា
14 កិច្ចប្រជុំលើកទី ២ នៃគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលចិននិងកម្ពុជា ប្រារព្ធធ្វើនៅរាជធានីភ្នំពេញ
18 ធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោយមានភាពកាន់តែស៊ីជម្រៅ បញ្ចេញកម្លាំងរស់រវើករបស់ចិន



**20 ប្រទេសចិនបច្ចុប្បន្ន 今日中国**

20 ប្រទេសចិនពង្រីកទំហំនាំចូល នាំមកនូវកាលានុវត្តភាពថ្មីដល់ពិភពលោកទាំងមូល
24 ធនាគារធំៗលើពិភពលោកដណ្តើមបង្កើតសាខានៅក្រុងឆឹងទូ



**26 សុបិនចិន 中国梦**

26 ច្រកអន្តរជាតិអឺលានហោធី
28 ស្រុកអ៊ីយាន់ដ៏ស្រស់ស្អាតពិពណ៌នានូវសុបិនដ៏អស្ចារ្យ

**30 ចំណាប់អារម្មណ៍អំពីអាស៊ាន 聚焦东盟**

30 រួមគ្នាស្ថាបនាផ្លូវសូត្រលើសមុទ្រ តភ្ជាប់សុបិនអាស៊ីប៉ាស៊ីហ្វិក សិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការប្រព័ន្ធផ្សព្វផ្សាយអាស៊ាននិងចិន ជប៉ុន កូរ៉េខាងត្បូង (១០+៣)លើកទី ៧ ប្រារព្ធធ្វើនៅក្រុងប៉េកាំង
32 ឆ្នាំផ្លាស់ប្តូរវប្បធម៌ចិន-អាស៊ាន ២០១៤ ទទួលបានសមិទ្ធផលជាផ្លែផ្កាដ៏ច្រើន



**34 ច្រកទ្វារនៃខេត្តយូណាន 云南之窗**

34 មានមេត្រីភាពជាមួយប្រទេសជិតខាង រួមគ្នាស្វែងរកភាពរុងរឿងចុំថ្កើង ទិវាវប្បធម៌និងសិល្បៈប្រទេសតាមដងទន្លេឡានឆាង-មេគង្គ ២០១៤ រៀបចំដោយជោគជ័យ
36 ស្តារផ្លូវសូត្រនៅភាគខាងត្បូងឱ្យមានភាពរុងរឿងឡើងវិញ ផ្តល់កម្លាំងជំរុញសម្រាប់ការអភិវឌ្ឍន៍យូណានដោយលោតផ្លោះ
38 ឈរលើមូលដ្ឋានប៉ាវសាន បើកទូលាយចំពោះភាគខាងលិចខេត្តយូណាន ដើរឆ្ពោះទៅកាន់តំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង បុរីពាណិជ្ជកម្មអន្តរជាតិអ៊ីអ៊្វូ ម៉ាវហ្វូ ក្រុងប៉ាវសានចាប់ដំណើរការធ្វើអាជីវកម្ម
40 សួនឧស្សាហកម្មនិងពាណិជ្ជកម្មប៉ាវសានរៀបចំសិក្ខាសាលាស្តីពីការទាក់ទាញអ្នកវិនិយោគ
42 ជំរុញការអភិវឌ្ឍនវិស័យពាណិជ្ជកម្ម ជួយស្រុកជនជាតិតៃឱ្យសម្រេចសុបិនចិន
44 ក្រុមហ៊ុនស្ថាបនកម្មយូណាន បើកភ្លោងឆ្ពោះទៅកាន់អនាគត

**50 កម្លាំងទាក់ទាញនៃប្រទេសកម្ពុជា 魅力柬埔寨**

50 "ភូមិអណ្តែតទឹកវៀតណាម" នៅលើបឹងទន្លេសាប

**54 ទេសចរណ៍ 旅游**



54 ទីក្រុងបុរាណហ៊ុយចូវ
56 វាលស្មៅអ៊ីលី

**58 ប្រពៃណីទំនៀមទម្លាប់ប្រជាជន 历史文化**

58 ចម្លាក់ថ្មហ្វូយអាន បុប្ផនៃសិល្បៈចម្លាក់ខាងត្បូង

**60 ប្រពៃណីទំនៀមទម្លាប់ប្រជាជន 民族风情**

60 ចម្រៀងធំជនជាតិតុង

**62 ការសិក្សាភាសាចិន 学汉语**

62 ចំណេះដឹងមូលដ្ឋាន(៤១)



# ប្រមូលផ្តុំដួងចិត្តម៉ាកាវ រួមគ្នាសម្រេចសុបិនចិន អបអរសាទរខួបទី ១៥ ឆ្នាំនៃការវិលត្រឡប់មកប្រទេសចិនវិញរបស់ម៉ាកាវ



ឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតីចិន អញ្ជើញចូលរួមពិធីអបអរសាទរខួបទី ១៥ ឆ្នាំនៃការវិលត្រឡប់មកប្រទេសចិនវិញរបស់ម៉ាកាវ

中国国家主席习近平出席庆祝澳门回归祖国15周年大会　新华社 图

## 凝聚澳门心　共圆中国梦

### ——庆祝澳门回归15周年

彩旗飘扬，国歌嘹亮。回归祖国15年之际，澳门一派生机勃勃、喜庆欢乐的景象。

2014年12月19日至20日，中国国家主席习近平来到祖国南海之滨的澳门考察访问。28个小时，15场重要活动。习近平主席对新一届特别行政区政府带领澳门居民昂扬前行的期待，对澳门同胞民生福祉的关怀，对珍视和传承爱国爱澳传统的寄语，对开创“一国两制”崭新局面的重托，深植澳门同胞心中，也向世界讲述了一个精彩的“中国故事”。



ម៉ាកាវរៀបចំពិធីបង្ហូតទង់ដើម្បីអបអរសាទរខួបទី ១៥ ឆ្នាំនៃការវិលត្រឡប់មកប្រទេសចិនវិញរបស់ម៉ាកាវ

澳门举行升旗仪式庆祝回归祖国15周年　新华社 图

ទង់ចម្រុះពណ៌បក់រវិចៗ ភ្លេងជាតិឮរណ្តំ។ ក្នុងឱកាសខួបទី ១៥ ឆ្នាំនៃការដែលម៉ាកាវវិលត្រឡប់មកប្រទេសចិនវិញនោះ តំបន់ម៉ាកាវបានបង្ហាញនូវភាពរស់រវើកនិងអបអរសប្បាយរីករាយនៅគ្រប់ទីកន្លែង ។

កាលពីថ្ងៃទី ១៩ ដល់ទី ២០ ខែធ្នូ ឆ្នាំ ២០១៤ ឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតីចិនបានអញ្ជើញទៅទស្សនកិច្ចនៅតំបន់ម៉ាកាវដែលស្ថិតនៅតាមឆ្នេរសមុទ្រខាងត្បូងនៃប្រទេសចិន ។ រយៈពេលតែ ២៨ ម៉ោងប៉ុណ្ណោះ មានសកម្មភាពសំខាន់ចំនួន ១៥ ។ ក្តីសង្ឃឹមចំពោះថ្នាក់ដឹកនាំអាណត្តិថ្មីនៃតំបន់រដ្ឋបាលពិសេសម៉ាកាវក្នុងការដឹកនាំប្រជាជនម៉ាកាវបោះជំហានទៅមុខយ៉ាងក្លៀវក្លា ការយកចិត្តទុកដាក់ចំពោះជីវភាពរស់នៅរបស់បងប្អូនជនរួមជាតិនៅម៉ាកាវ ប្រសាសន៍អំពីការបន្តផ្សព្វផ្សាយប្រពៃណីស្នេហាជាតិនិងស្រឡាញ់ម៉ាកាវ និងការប្រគល់ភារៈដ៏សំខាន់សម្រាប់បើកទំព័រថ្មីនៃការអនុវត្តយុទ្ធសាស្ត្រ“ប្រទេសមួយប្រព័ន្ធដឹកនាំពីរ” បានបង្កប់យ៉ាងជ្រាលជ្រៅក្នុងដួងចិត្តរបស់បងប្អូនជនរួមជាតិម៉ាកាវ និងបានបកស្រាយពី“រឿងរ៉ាវចិន”ដ៏អស្ចារ្យ ។

បន្ទាប់ពីម៉ាកាវវិលត្រឡប់មកប្រទេសចិនវិញ សាលា






រាត្រីសមោសរអបអរខួបទី ១៥ ឆ្នាំនៃការវិលត្រឡប់មកប្រទេសចិនវិញរបស់ម៉ាកាវ ប្រារព្ធនៅម៉ាកាវ

庆祝澳门回归祖国15周年文艺晚会在澳门举行　新华社 图

តំបន់រដ្ឋបាលពិសេសបានកំណត់គោលនយោបាយផ្តល់ផ្ទះស្នាក់នៅសាធារណៈក្នុងគោលបំណងសម្រេចការ“មានផ្ទះស្នាក់នៅរស់នៅនិងប្រកបរបរដោយភាពសប្បាយរីករាយ”។ នេះគឺជាវិធានការមួយ ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងគោលនយោបាយផ្តល់ផ្ទះជួលឬទិញដោយតម្លៃថោកសម្រាប់ប្រជាជនមានជីវភាពទន់ខ្សោយនៅចិនដីគោក ។ ផ្ទះស្នាក់នៅសាធារណៈនៅឈ្វូងសមុទ្រស៊ីផៃគឺជាគម្រោងផ្ទះស្នាក់នៅសាធារណៈធំជាងគេនៅតំបន់ម៉ាកាវដែលមានផ្ទះខុនដូចំនួនជាង ៩ ០០០ ។

រយៈពេល ១៥ ឆ្នាំ មានការប្រែប្រួលយ៉ាងខ្លាំងគួរឱ្យកត់សម្គាល់ ។ ម៉ាកាវ ដែលជាតំបន់មួយមានផ្ទៃដីត្រឹមតែ ៣០ គីឡូម៉ែត្រការ៉េនោះ ក្រោមការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋាភិបាលចិនដីគោក ព្រមទាំងការដឹកនាំពីមន្ត្រីប្រចាំការច្រើនអាណត្តិនិងសាលាតំបន់រដ្ឋបាលពិសេស យុទ្ធសាស្ត្រនិងរបប“ប្រទេស



ឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតីចិនជូនអំណោយជាសៀវភៅដល់សកលវិទ្យាល័យម៉ាកាវ ហើយចុះហត្ថលេខាលើសៀវភៅដែលជូនជាអំណោយ

中国国家主席习近平向澳门大学赠送书籍，并现场在赠书函上签名　新华社 图



ម៉ាកាវរៀបចំពិធីបាញ់កាំជ្រួចដើម្បីអបអរខួបទី ១៥ ឆ្នាំនៃការវិលត្រឡប់មកប្រទេសចិនវិញរបស់ម៉ាកាវ
澳门举行庆祝回归15周年烟花汇演　新华社 图

មួយប្រព័ន្ធដឹកនាំពីរ” និង “អ្នកម៉ាកាវគ្រប់គ្រងម៉ាកាវ” បានទទួលនូវលទ្ធផលជាផ្លែផ្កាក្នុងការគ្រប់គ្រងផ្ទាល់ដោយកម្រិតខ្ពស់ ។

ក្នុងរាត្រីសមោសរអបអរខួបទី ១៥ ឆ្នាំនៃការវិលត្រឡប់មកប្រទេសចិនវិញរបស់ម៉ាកាវដែលរៀបចំនៅយប់ថ្ងៃទី ១៩ រូបភាពខ្សែភាពយន្តរបស់យុវជនយុវនារី ១ ៩៩៩ នាក់ ដែលកើតនៅឆ្នាំ ១៩៩៩ ដែលជាឆ្នាំនៃការវិលត្រឡប់មកវិញរបស់ម៉ាកាវនោះ ត្រូវបានបញ្ចាំងនៅលើអេក្រង់ដ៏ធំ ។ កាលពីមុនពួកគេជាទារក ថ្ងៃនេះបានធំធាត់ជាយុវជនយុវនារីដ៏មានកម្លាំងរស់រវើក ហើយតំបន់រដ្ឋបាលពិសេសម៉ាកាវដែលមានអាយុកាល ១៥ ឆ្នាំក៏បង្ហាញពីភាពក្មេងវ័យក្លាហាននិងរឹងមាំ ហើយពោរពេញដោយកម្លាំងទាក់ទាញផងដែរ ។

ក្នុងកិច្ចប្រជុំស្ដីពីការអបអរសាទរខួបទី ១៥ នៃការវិលត្រឡប់មកវិញរបស់ម៉ាកាវដែលរៀបចំនៅថ្ងៃទី ២០ ខែធ្នូនោះ ឯកឧត្តមប្រធានាធិបតី ស៊ី ជីនភីង បានមានប្រសាសន៍ថា ក្នុងអំឡុងពេល ១៥ ឆ្នាំបន្ទាប់ពីម៉ាកាវវិលត្រឡប់មកប្រទេសចិនវិញ ការអនុវត្តជាក់ស្ដែងនូវយុទ្ធសាស្ត្រ“ប្រទេសមួយប្រព័ន្ធដឹកនាំពីរ”បានទទួលនូវលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈនេះ ។ ទន្ទឹមនឹងនេះដែរ ម៉ាកាវនិងចិនដីគោកមានការផ្លាស់ប្ដូរនិងកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ បន្តចូលរួមចំណែកជាច្រើនក្នុងការអនុវត្តគោលនយោបាយកែទម្រង់និងបើកចំហ ព្រមទាំងការជំរុញដំណើរទំនើបភាវូបនីយកម្មរបស់ប្រទេសចិន ហើយចែករំលែកគ្នាអំពីកាលានុវត្តភាពនៃការអភិវឌ្ឍន៍ប្រទេសជាតិ ។ បងប្អូនជនរួមជាតិម៉ាកាវមានមនោសញ្ចេតនាទទួលស្គាល់ និងស្រឡាញ់ប្រទេសជាតិកាន់តែខ្លាំងក្លា និងមានមនោសញ្ចេតនាជនជាតិចិនដែលអាចប្រៀបប្រដូចបានថា“ឈាមជ័រខាប់ជាងទឹក” ។ ក្នុងនាមជាតំបន់ប្រវត្តិសាស្ត្រនិងវប្បធម៌ដែលប្រមូលផ្ដុំនូវវប្បធម៌ចិននិងវប្បធម៌បស្ចិមប្រទេស ម៉ាកាវបាននិងកំពុងបង្ហាញពីរូបភាពដ៏មានកម្លាំងរស់រវើក និងទាក់ទាញយ៉ាងខ្លាំង ។

ក្នុងអំឡុងពេលទស្សនកិច្ចនៅម៉ាកាវ ឯកឧត្តម ស៊ី ជីនភីង បានសង្កត់ធ្ងន់ថា “ប្រទេសមួយប្រព័ន្ធដឹកនាំពីរ”គឺជាគោលនយោបាយមូលដ្ឋានមួយរបស់ជាតិ ហើយការប្រកាន់ខ្ជាប់នូវគោលនយោបាយនេះ គឺជាសំណូមពរដ៏ចាំបាច់សម្រាប់រក្សានិងជំរុញវិបុលភាពរបស់ហុងកុង និងម៉ាកាវក្នុងរយៈពេលយូរអង្វែង ហើយក៏ជាផ្នែកដ៏សំខាន់មួយសម្រាប់ស្តារប្រជាជាតិចិនឱ្យមានភាពរុងរឿងឡើងវិញផងដែរ ។

ឯកឧត្តម ស៊ី ជីនភីង បានថ្លែងនូវជំនឿចិត្តថា ក្រោមកិច្ចខិតខំប្រឹងប្រែងពីរដ្ឋាភិបាលចិន សាលាតំបន់រដ្ឋបាលម៉ាកាវនិងគ្រប់មជ្ឈដ្ឋានក្នុងសង្គម ព្រមទាំងការគាំទ្រយ៉ាងពេញទំហឹងពីប្រជាជនគ្រប់ជនជាតិ ការអនុវត្តគោលនយោបាយ“ប្រទេសមួយប្រព័ន្ធដឹកនាំពីរ”ប្រាកដជានឹងអាចបើកទំព័រដ៏ថ្មីអស្ចារ្យជាច្រើនទៀត ចំណែកម៉ាកាវដែលជាផ្កាឈូកដ៏ស្រស់ស្អាតរបស់ចិននេះមុខជានឹងអាចរីកស្គុះស្គាយកាន់តែស្រស់ត្រកាលនិងមានភាពត្រចះត្រចង់ថែមទៀតជាមិនខាន ។



ទិដ្ឋភាពនៃរោងចក្រផលិតបំពង់នៃវិស្វកម្មស្ពាននិងផ្លូវក្រោមសមុទ្រហុងកុង-ជូហៃ-ម៉ាកាវ
港珠澳大桥岛隧工程沉管预制厂全景　新华社 图

图/cnsphoto

# ឯកឧត្តមនាយករដ្ឋមន្ត្រីចិន លី ខឺឈាំង មានវត្តមានក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គលើកទី ៥

## 中国国务院总理李克强出席大湄公河次区域经济合作第五次领导人会议

中国国务院总理李克强于当地时间2014年12月20日上午在曼谷出席大湄公河次区域经济合作第五次领导人会议开幕式。泰国总理巴育主持会议，缅甸总统吴登盛、柬埔寨首相洪森、老挝总理通邢、越南总理阮晋勇和亚洲开发银行行长中尾武彦与会。与会各方就深化区域合作、加强互联互通等深入交换意见，达成广泛共识。



ឯកឧត្តម លី ខឺឈាំង នាយករដ្ឋមន្ត្រីចិន អញ្ជើញចូលរួមនិងថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គលើកទី ៥

中国国务院总理李克强出席大湄公河次区域经济合作第五次领导人会议并发言

ឯកឧត្តម លី ខឺឈាំង នាយករដ្ឋមន្ត្រីចិន បានអញ្ជើញចូលរួមពិធីបើកសម្ពោធកិច្ចប្រជុំថ្នាក់ដឹកនាំស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គលើកទី ៥ នៅព្រឹកថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៤ នៅក្រុងបាងកកប្រទេសថៃ ។ ឯកឧត្តម ប្រា យុទ្ធ នាយករដ្ឋមន្ត្រីថៃ ឯកឧត្តម អ៊ូ ថេនសេន ប្រធានាធិបតីមីយ៉ាន់ម៉ា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ឯកឧត្តម ថុង ស៊ីង នាយករដ្ឋមន្ត្រីឡាវ ឯកឧត្តម ង្វៀន តាន់ដុង នាយករដ្ឋមន្ត្រីវៀតណាម និងឯកឧត្តម Takehiko Nakao ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំលើកនេះ ។ អង្គប្រជុំបានផ្លាស់ប្តូរគ្នាយ៉ាងស៊ីជម្រៅលើវិស័យធ្វើកិច្ចសហប្រតិបត្តិការក្នុងតំបន់ឱ្យកាន់តែស៊ីជម្រៅ និងលើកកម្ពស់កម្រិតថ្នាក់នៃការតភ្ជាប់គ្នា ព្រមនិងបានឈានដល់មតិឯកភាពគ្នាជាទូទៅ ។

ឯកឧត្តម លី ខឺឈាំង បានថ្លែងថា ប្រទេសចិននឹងប្រកាន់ខ្ជាប់នូវគោលនយោបាយដើរតាមមាគ៌ាអភិវឌ្ឍន៍ដោយសន្តិភាព រក្សាស្ថិរភាពនិងសន្តិភាពក្នុងតំបន់ និងគាំទ្រដោយឥតងាករេនូវដំណើរសមាហរណកម្មអាស៊ាន ហើយផ្តល់អាទិភាពផ្នែកការទូតជាមួយបណ្តាប្រទេសអាស៊ាន ។ ភាគីចិនរីករាយសហការគ្នាជាមួយប្រទេសទាំង ៥ បង្កើតក្របខ័ណ្ឌថ្មីសម្រាប់ជំរុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅ ។ ឯកឧត្តមបានលើកឡើងនូវមតិចំនួន ៥ ដូចខាងក្រោម ៖

ទី១-ធ្វើកិច្ចសហប្រតិបត្តិការលើវិស័យហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែស៊ីជម្រៅ ។ ចាត់ទុកការកសាងសមាគមផ្លូវដែកក្នុងតំបន់ជាកាលានុវត្តភាពសំខាន់ ជំរុញការកសាងប្រព័ន្ធដឹកជញ្ជូនចម្រុះក្នុងអនុតំបន់ បង្កើនភាពងាយស្រួលក្នុងការឆ្លងដែន និងលើកកម្ពស់កម្រិតតភ្ជាប់គ្នាខាងគ្រឿងទន់ ។

ទី២-បង្កើតរបបថ្មីអំពីកិច្ចសហប្រតិបត្តិការឧស្សាហកម្ម ។ ភាគីចិនរីករាយសកម្មចូលរួមការកសាងសួនឧស្សាហកម្ម និងបច្ចេកទេសនៅក្នុងប្រទេសទាំង ៥ ជាពិសេសនៅតាមផ្លូវដែកដែលជិតនឹងសហការសាងសង់ដោយភាគីចិននិងថៃ ហើយរីករាយបង្កើតរោងចក្រនៅតាមតំបន់ផ្សេងៗដោយផ្អែកលើសមត្ថភាពផលិតកម្មកម្រិតខ្ពស់ ដើម្បីជួយប្រទេសជិតខាងបង្កើនឱកាសការងារ ។

ទី៣-បង្កើនការគាំទ្រខាងហិរញ្ញវត្ថុចំពោះកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មនិងការវិនិយោគ ។ ភាគីចិននឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសតាមទន្លេមេគង្គលើ ការបង្កើតមណ្ឌលទូទាត់ឆ្លងដែនដោយប្រើប្រាស់រូបិយវត្ថុរបស់ខ្លួន ពង្រីកទ្រង់ទ្រាយនៃការប្តូរប្រាក់របស់ខ្លួនដោយផ្ទាល់ គាំទ្រភាគីទាំងពីរពង្រីកកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ។ អាស្រ័យលើគោលការណ៍ទីផ្សារភាវូបនីយកម្ម និងនិរន្តរភាព គាំទ្រគម្រោងសំខាន់ស្តីពីកិច្ចសហប្រតិបត្តិការផ្នែកតភ្ជាប់គ្នា និងឧស្សាហកម្ម ។

ទី៤-ជំរុញការអភិវឌ្ឍន៍បុព្វហេតុសង្គមកិច្ចនិងជីវភាពរស់នៅរបស់ប្រជាជន ។ ភាគីចិននឹងបន្តផ្តល់ការគាំទ្រនិងជំនួយឧបត្ថម្ភយ៉ាងពេញទំហឹងដល់ប្រទេសខ្វះការអភិវឌ្ឍន៍ ហើយបង្កើនប្រាក់ចំណូលប្រជាកសិករតាមរយៈការពង្រីកកសិពាណិជ្ជកម្ម ។

ទី៥-លើកកម្ពស់កម្រិតថ្នាក់នៃការបើកចំហនិងការសហការគ្នាក្នុងការអភិវឌ្ឍន៍តំបន់ ។ ប្រទេសអនុតំបន់ត្រូវបង្កើនការវិនិយោគ ស្វាគមន៍ភាគីនានានៅក្រៅអនុតំបន់សកម្មចូលរួម បន្តធ្វើឱ្យស្ថាប័នអន្តរជាតិដើរតួនាទីសំខាន់ដូចជាធនាគារអភិវឌ្ឍន៍អាស៊ីជាដើម ។ ធ្វើឱ្យប្រទេសខ្លួនមានការតភ្ជាប់កាន់តែជិតស្និទ្ធជាមួយផែនការអភិវឌ្ឍន៍អនុតំបន់ រក្សាការសម្របសម្រួលគ្នាតាមរយៈយន្តការសហប្រតិបត្តិការដូចជាសហគមន៍អាស៊ាន អាស៊ានបូកមួយ និងអាស៊ានបូកបីជាដើម ។ លើកកម្ពស់សមត្ថភាពប្រកួតប្រជែងក្នុងខ្សែសង្វាក់តម្លៃពិភពលោកទាំងមូលរបស់ប្រទេសអនុតំបន់ ។

ជាទីចុងបញ្ចប់ ឯកឧត្តម លី ខឺឈាំង បានគូសបញ្ជាក់ថា ការអភិវឌ្ឍន៍ប្រទេសចិនត្រូវតែមានបរិយាកាសសន្តិភាព និងស្ថិរភាពក្នុងតំបន់ ។ ការអភិវឌ្ឍន៍ប្រទេសចិននិងការអភិវឌ្ឍន៍តំបន់បានផ្តល់ឱកាសល្អៗទៅវិញទៅមក ។ ភាគីចិនរីករាយពួតដៃជាមួយភាគីពាក់ព័ន្ធផ្សេងៗ រួមគ្នាលើកកម្ពស់កម្រិតថ្នាក់នៃកិច្ចសហប្រតិបត្តិការរវាងចិននិងអាស៊ាន ព្រមទាំងកិច្ចសហប្រតិបត្តិមហាអនុតំបន់ទន្លេមេគង្គ ដើម្បីនាំមកនូវផលប្រយោជន៍កាន់តែច្រើនដល់តំបន់ជុំវិញនិងប្រជាជននៃបណ្តាប្រទេសក្នុងតំបន់ ។




កិច្ចប្រជុំថ្នាក់ដឹកនាំស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គលើកទី ៥

大湄公河次区域经济合作第五次领导人会议

图/cnsphoto

# ឯកឧត្តម យ៉ាង ជីឈី ចូលបង្គំគាល់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងចូលជួបសម្តែងការគួរសមជាមួយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ជួបប្រាស្រ័យជាមួយឯកឧត្តម យ៉ាង ជីឈី ទីប្រឹក្សានៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន នៅរាជធានីភ្នំពេញ ភាគីទាំងពីរបានផ្លាស់ប្តូរមតិអំពីការពង្រឹងចំណងមិត្តភាពចិននិងកម្ពុជា និងការបង្កើនកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងពីរ

柬埔寨首相洪森在金边会见中国国务委员杨洁篪，双方就发展中柬关系、加强两国全面战略合作交换了看法

## 柬埔寨国王西哈莫尼、首相洪森分别会见杨洁篪

2014年12月31日，柬埔寨国王西哈莫尼、首相洪森在金边分别会见中国国务委员杨洁篪。

ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ ឯកឧត្តម យ៉ាង ជីឈី ទីប្រឹក្សានៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន បានចូលបង្គំគាល់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងចូលជួបសម្តែងការគួរសមជាមួយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងឱកាសចូលបង្គំគាល់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម យ៉ាង ជីឈី បានពាំនាំមកនូវការសាកសួរព្រះរាជសុខទុក្ខយ៉ាងស្និទ្ធស្នាលពីសំណាក់ឯកឧត្តម ស៊ី ជីនភីង ប្រធានាធិបតីចិន ថ្វាយចំពោះព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាវីរក្សត្រីនរោត្តម មុនីនាថ សីហនុ ។ ឯកឧត្តមបានទូលថា ក្រោយពីប្រទេសចិននិងកម្ពុជាបង្កើតទំនាក់ទំនងការទូតរៀងមក បុព្វហេតុមិត្តភាពរវាងប្រទេសទាំងពីរហាក់ដូចជាដើមស្រល់ដ៏រស់រវើកឆ្លងកាត់ភ្លៀងខ្យល់លូតលាស់យ៉ាងឆាប់រហ័ស ។ ប្រជាជននឹងចងចាំ និងរំលឹកជានិច្ចកាលនូវព្រះរាជវិភាគទានដ៏ថ្លៃថ្លា លើសលប់របស់ព្រះករុណាព្រះបរមរតនកោដ្ឋក្នុងការពង្រឹងនិងពង្រីកចំណងមិត្តភាពរវាងប្រទេសចិននិងកម្ពុជា ។ ប្រទេសចិននឹងប្រកាន់ខ្ជាប់នូវគោលនយោបាយគោរពរាប់អានជាមួយប្រទេសកម្ពុជា រួមសហការជាមួយប្រទេសកម្ពុជា ដើម្បីលើកកម្ពស់កម្រិតថ្នាក់នៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងជំរុញទំនាក់ទំនងនៃប្រទេសទាំងពីរឱ្យឈានទៅមុខឥតឈប់ឈរ ។

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី បានសូមឱ្យឯកឧត្តម យ៉ាង ជីឈី ពាំនាំនូវសេចក្តីជូនពរដ៏ល្អបវររបស់ព្រះអង្គនិងសម្តេចព្រះមហាវីរក្សត្រីនរោត្តម មុនីនាថ សីហនុ ជូនចំពោះឯកឧត្តមប្រធានាធិបតី ស៊ី ជីនភីង ។ ព្រះអង្គបានមានព្រះរាជបន្ទូលថាប្រទេសកម្ពុជានិងចិនមានមិត្តភាពជាភាតរភាព ប្រជាជននៃប្រទេសទាំងពីរស្រឡាញ់រាប់អានគ្នាជាប់រហូតមក ។ ព្រះរាជវង្សានុវង្សកម្ពុជារក្សាថ្នាក់ថ្នម និងយកចិត្តទុកដាក់ដល់ចំណងមិត្តភាពដ៏ល្អប្រពៃជាមួយប្រទេសចិន ហើយនិងទទួលបន្តនិងពង្រីកថែមទៀតនូវបុព្វហេតុមិត្តភាពកម្ពុជា-ចិន ដែលពូនជ្រុំឡើងដោយព្រះបរមរតនកោដ្ឋ ជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យឈានទៅមុខឥតឈប់ឈរ ។

នៅពេលចូលជួបសម្តែងការគួរសមជាមួយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ឯកឧត្តម យ៉ាង ជីឈី បានថ្លែងថា ប្រទេសចិននិងកម្ពុជាជាអ្នកជិតខាងល្អ មិត្តល្អ ដៃគូល្អយ៉ាងពិតប្រាកដ ។ ប៉ុន្មានឆ្នាំកន្លងទៅនេះ ក្រោមការយកចិត្តទុកដាក់និងការគាំទ្រពីសំណាក់អ្នកដឹកនាំនៃប្រទេសទាំងពីរ ទំនាក់ទំនងរវាងចិននិងកម្ពុជាបានរីកចម្រើនដោយមានស្ថិរភាព និងបានទទួលលទ្ធផលជាផ្លែផ្កាលើគ្រប់វិស័យ ។ បច្ចុប្បន្ន ប្រទេសចិននិងកម្ពុជាបានប្រឈមមុខនឹងកាលានុវត្តភាពដ៏សំខាន់សម្រាប់ធ្វើកំណែទម្រង់ និងបានធ្វើឱ្យភាគីទាំងពីរមានផលប្រយោជន៍ជាយុទ្ធសាស្ត្ររួមកាន់តែទូលំទូលាយ ។ ឯកឧត្តម យ៉ាង ជីឈី បានគូសបញ្ជាក់ថា កិច្ចប្រជុំលើកទីពីរនៃគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលចិននិងកម្ពុជាបានទទួលជោគជ័យយ៉ាងគាប់ប្រសើរ ។ ភាគីទាំងពីរបានពិភាក្សានិងឯកភាពគ្នាថា នឹងរក្សាការប្រាស្រ័យទាក់ទងរវាងថ្នាក់ដឹកនាំជាតិនិងគណបក្សបង្កើនការផ្លាស់ប្តូរបទពិសោធន៍ផ្នែកនយោបាយនិងការគ្រប់គ្រងប្រទេស ពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្ម កសិកម្ម ថាមពល និងធារាសាស្ត្រជាដើម ព្រមទាំងកិច្ចសហប្រតិបត្តិការអំពីការតភ្ជាប់គ្នា ព័ត៌មានវិទ្យា និងទូរគមនាគមន៍ ពង្រឹងកិច្ចសហ-ប្រតិបត្តិការលើវិស័យ ជីវភាពរស់នៅរបស់ប្រជាជន ដើម្បីធ្វើឱ្យប្រជាជនកាន់តែច្រើនទទួលបានផលប្រយោជន៍ពីកិច្ចសហ-ប្រតិបត្តិការមិត្តភាពចិននិងកម្ពុជា បង្កើនការផ្លាស់ប្តូរផ្នែកវប្បធម៌ធ្វើឱ្យប្រជាជននៃប្រទេសទាំងពីរមានមនោសញ្ចេតនាកាន់តែស៊ីជម្រៅ បណ្តុះបណ្តាលអ្នកបន្តវេនសម្រាប់បុព្វហេតុមិត្តភាពចិននិងកម្ពុជា ។

ជាការឆ្លើយតប សម្តេចតេជោបានមានប្រសាសន៍ថា កម្ពុជាជាមិត្តស្មោះរបស់ចិន ភាគីកម្ពុជារក្សាថ្នាក់ថ្នម និងយកចិត្តទុកដាក់ខ្ពស់លើចំណងមិត្តភាពប្រពៃណីរវាងប្រទេសទាំងពីរ កម្ពុជាសូមថ្លែងអំណរគុណចំពោះភាគីចិនដែលបានផ្តល់ការគាំទ្រដល់ភាគីកម្ពុជាក្នុងការអភិវឌ្ឍន៍ប្រទេសជាតិដោយមានស្ថិរភាព ។ ភាគីកម្ពុជានឹងរួមសហការគ្នាជាមួយភាគីចិនបង្កើនកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយឱ្យកាន់តែស៊ីជម្រៅ បង្កើនការប្រាស្រ័យទាក់ទងរវាងថ្នាក់ដឹកនាំជាន់ខ្ពស់ ជំរុញកិច្ចសហប្រតិបត្តិការពហុវិស័យឱ្យទទួលសមិទ្ធផលកាន់តែធំធេង និងចូលរួមចំណែកកាន់តែច្រើន ក្នុងការស្វែងរកភាពរុងរឿងនិងស្ថិរភាពក្នុងតំបន់ ។



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ជួបប្រាស្រ័យជាមួយឯកឧត្តម យ៉ាង ជីឈី ទីប្រឹក្សានៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន

柬埔寨首相洪森会见中国国务委员杨洁篪

图/cnsphoto

# កិច្ចប្រជុំលើកទី ២ នៃគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលចិននិងកម្ពុជា ប្រារព្ធធ្វើនៅរាជធានីភ្នំពេញ



ឯកឧត្តម យ៉ាង ជីឈី ទីប្រឹក្សានៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន និងឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ជួបជាមួយអ្នកសារព័ត៌មាន

中国国务委员杨洁篪与柬埔寨副首相兼外交国际合作部大臣贺南洪共同会见记者

## 中柬政府间协调委员会第二次会议在金边举行

2014年12月30日，中柬政府间协调委员会第二次会议在柬埔寨金边举行。中国国务委员杨洁篪与柬埔寨副首相兼外交国际合作部大臣贺南洪共同主持会议。会议总结了委员会首次会议以来双方各领域合作取得的成果，对下一阶段双边关系发展及各领域合作进行了规划和部署。

ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០១៤ កិច្ចប្រជុំលើកទី ២ នៃគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលចិននិងកម្ពុជាបានប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។ ឯកឧត្តម យ៉ាង ជីឈី ទីប្រឹក្សានៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន និងឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានអញ្ជើញចូលរួមជាអធិបតីនៃកិច្ចប្រជុំលើកនេះ ។ អង្គប្រជុំបានបូកសរុបនូវសមិទ្ធផលផ្សេងៗនៃកិច្ចសហប្រតិបត្តិការទ្វេភាគីបន្ទាប់ពីកិច្ចប្រជុំលើកដំបូងនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលនិងបានកំណត់ផែនការអំពីការអភិវឌ្ឍន៍ទំនាក់ទំនងទ្វេភាគីនិងកិច្ចសហប្រតិបត្តិការលើពហុវិស័យនៅជំហានក្រោយ ។

ឯកឧត្តម យ៉ាង ជីឈី បានគូសបញ្ជាក់ថា ប្រទេសចិននិងកម្ពុជាជាមិត្តល្អនិងបងប្អូនល្អដែលរួមសុខរួមទុក្ខ និងជួយឈឺឆ្អាលគ្នាទៅវិញទៅមក ។ ក្នុងរយៈពេលជាងជិតមួយឆ្នាំបន្ទាប់ពីការរៀបចំកិច្ចប្រជុំលើកដំបូងនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលរៀងមក ការអភិវឌ្ឍន៍ទំនាក់ទំនងប្រទេសទាំងពីរបានទទួលលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ ។ ថ្នាក់ដឹកនាំនៃប្រទេសចិននិងកម្ពុជាបានឯកភាពគ្នាលើការជំរុញឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងបានចង្អុលបង្ហាញទិសដៅសម្រាប់ការអភិវឌ្ឍន៍ទំនាក់ទំនងទ្វេភាគី ។ ភាគីទាំងពីរបានអនុវត្តដោយគ្រប់ជ្រុងជ្រោយតាមផែនការសហប្រតិបត្តិការដែលកំណត់ក្នុងកិច្ចប្រជុំលើកដំបូងនៅដើមឆ្នាំ ២០១៤ និងបានទទួលសមិទ្ធផលក្នុងកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម កសិកម្ម កិច្ចការពារជាតិ ការអនុវត្តច្បាប់ ទំនាក់ទំនងគណបក្ស និងវប្បធម៌ជាដើម ដែលបាននាំមកនូវផលប្រយោជន៍យ៉ាងធំធេងដល់ប្រជាជននៃប្រទេសទាំងពីរ ។ ស្ថិតក្រោមបរិបទថ្មី ប្រទេសចិននិងកម្ពុជាមានផលប្រយោជន៍ជាយុទ្ធសាស្ត្ររួមកាន់តែទូលំទូលាយនិងមានចន្លោះសហប្រតិបត្តិការកាន់តែធំធេង ។ ភាគីទាំងពីរត្រូវតែអនុវត្តជាក់ស្តែងតាមចំណុចឯកភាពរួមនៃថ្នាក់ដឹកនាំប្រទេសទាំងពីរ ប្រើប្រាស់ឱ្យកាន់តែល្អប្រសើរនូវយន្តការគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលលើកកម្ពស់ដោយឥតឈប់ឈរនូវកម្រិតនៃកិច្ចសហប្រតិបត្តិការ



ឯកឧត្តម យ៉ាង ជីឈី ទីប្រឹក្សានៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន(រូបទី ៣ ខាងឆ្វេងដៃ) ចូលរួមពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីចិន-កម្ពុជា

杨洁篪（左三）出席中柬双边合作文件签字仪式



កិច្ចប្រជុំលើកទី ២ នៃគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលចិននិងកម្ពុជាប្រារព្ធធ្វើនៅរាជធានីភ្នំពេញ

中柬政府间协调委员会第二次会议在金边举行




ឯកឧត្តម យ៉ាង ជីឈី (រូបខាងស្តាំដៃ) និងឯកឧត្តម ហោ ណាំហុង រួមគ្នាបើកស្លាកនៃផ្ទះវប្បធម៌ចិននៅរាជធានីភ្នំពេញ
杨洁篪（右）与贺南洪共同为金边中国文化之家揭牌

ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដើម្បីចូលរួមការអភិវឌ្ឍន៍បុព្វហេតុកំណែទម្រង់នៃប្រទេសទាំងពីរ ។ ភាគីចិនសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះភាគីកម្ពុជាក្នុងការសកម្មជំរុញការអភិវឌ្ឍន៍ទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រចិន-អាស៊ាន ហើយរីករាយរួមសហការគ្នាជាមួយភាគីកម្ពុជាសំដៅរួមគ្នាជំរុញការកសាង“ខ្សែក្រវាត់មួយនិងផ្លូវមួយ” បង្កើត“សហគមន៍រួមវាសនាតែមួយចិន-អាស៊ាន” ដើម្បីចូលរួមចំណែកកាន់តែច្រើនក្នុងការបើកទំព័រថ្មីនៃការអភិវឌ្ឍន៍ទំនាក់ទំនងរវាងចិននិងអាស៊ាន ។



ឯកឧត្តម យ៉ាង ជីឈី និងឯកឧត្តម ហោ ណាំហុង រួមគ្នាដើរចូលក្នុងសាលប្រជុំ
杨洁篪与贺南洪步入会场

ឯកឧត្តម ហោ ណាំហុង បានថ្លែងថា ប្រទេសចិនជាមិត្តល្អរបស់កម្ពុជា ហើយទំនាក់ទំនងនៃប្រទេសទាំងពីរមានមូលដ្ឋានដ៏រឹងមាំ ។ ភាគីកម្ពុជាសូមថ្លែងអំណរគុណចំពោះភាគីចិនដែលបានផ្តល់ការគាំទ្រដ៏មានតម្លៃ និងជំនួយឧបត្ថម្ភដ៏ថ្លៃថ្លាចំពោះភាគីកម្ពុជាក្នុងរយៈពេលដ៏យូរកន្លងមក កម្ពុជាសូមវាយតម្លៃខ្ពស់ចំពោះ“ខ្សែក្រវាត់មួយនិងផ្លូវមួយ” “សហគមន៍រួមវាសនាតែមួយអាស៊ាន-ចិន” និងការផ្តួចផ្តើមមួយចំនួនទៀតរបស់ចិនសម្រាប់ជំរុញវិបុលភាពនិងការអភិវឌ្ឍន៍តំបន់ ព្រមទាំងវិធានការជាក់ស្តែងមួយចំនួនធំដូចជាការបង្កើតមូលនិធិផ្លូវសូត្រ និងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ីជាដើម ។



បន្ទាប់ពីកិច្ចប្រជុំលើកដំបូងនៃគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាល ប្រទេសទាំងពីរបានទទួលសមិទ្ធផលជាច្រើនលើកិច្ចសហប្រតិបត្តិការពហុវិស័យ ។ ភាគីកម្ពុជានឹងរួមសហការគ្នាជាមួយភាគីចិន អនុវត្តឱ្យបានល្អប្រសើរតាមផែនការសហប្រតិបត្តិការឆ្នាំក្រោយ ពង្រឹងនិងពង្រីកថែមទៀតនូវចំណងមិត្តភាពប្រពៃណីរវាងប្រទេសទាំងពីរ និងធ្វើឱ្យកិច្ចសហប្រតិបត្តិការជាក់ស្តែងលើពហុវិស័យមានភាពកាន់តែស៊ីជម្រៅ ។



ឯកឧត្តម យ៉ាង ជីឈី និងឯកឧត្តម ហោ ណាំហុង អញ្ជើញទស្សនាបន្ទប់អានសៀវភៅនៃផ្ទះវប្បធម៌ចិននៅរាជធានីភ្នំពេញ
杨洁篪与贺南洪参观金边中国文化之家图书室

ភាគីទាំងពីរបានឯកភាពគ្នាយ៉ាងទូលំទូលាយអំពីផែនការមេ និងវិធានការជាក់ស្តែងនៃកិច្ចសហប្រតិបត្តិការជំហានក្រោយ ហើយឯកភាពគ្នាលើការបង្កើនការប្រាស្រ័យទាក់ទងរវាងថ្នាក់ដឹកនាំជាន់ខ្ពស់និងទំនាក់ទំនងជាយុទ្ធសាស្ត្រ ពង្រីកកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្មឱ្យកាន់តែស៊ីជម្រៅ សម្រេចនូវការផ្តល់ផលប្រយោជន៍ទៅវិញទៅមកនិងឈ្នះ-ឈ្នះ ប្រើប្រាស់ជំនួយឧបត្ថម្ភរបស់ចិនឱ្យបានល្អប្រសើរ សំដៅបម្រើដល់ផលប្រយោជន៍ប្រជាជន លើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជន ពង្រីកការផ្លាស់ប្តូរផ្នែកវប្បធម៌ និងផ្សព្វផ្សាយអំពីចំណងមិត្តភាពប្រពៃណី ។ ក្រៅពីនេះ ភាគីទាំងពីរក៏បានផ្លាស់ប្តូរមតិយ៉ាងស៊ីជម្រៅអំពីបញ្ហាអន្តរជាតិ និងបញ្ហាក្នុងតំបន់ ដែលយកចិត្តទុកដាក់ដូចគ្នាផងដែរ ។




ឯកឧត្តម យ៉ាង ជីឈី និងឯកឧត្តម ហោ ណាំហុង អញ្ជើញទស្សនាថ្នាក់រៀនភាសាចិននៅផ្ទះវប្បធម៌ចិននៅរាជធានីភ្នំពេញ
杨洁篪等参观金边中国文化之家中文课堂

# ធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោយមានភាពកាន់តែស៊ីជម្រៅ បញ្ចេញកម្លាំងរស់រវើករបស់ចិន

## 全面深改：释放中国活力

2014年，中国深改元年，注定要在历史上留下浓重的一笔。

既有解放思想又有实事求是；既有整体推进又有重点突破；既有顶层设计又有“摸着石头过河”……

全面深化改革，释放出中国发展的活力。

ឆ្នាំ ២០១៤ ជាឆ្នាំដំបូងនៃការធ្វើឱ្យកំណែទម្រង់ចិនមានភាពកាន់តែស៊ីជម្រៅ ដែលប្រាកដជានឹងអាចត្រូវកត់ត្រាក្នុងប្រវត្តិសាស្ត្រជាក់ជាមិនខាន ។



ស្រុកជានតឺខេត្តជឺជាំង “សួនផ្លែឈើនិងបន្លែ” បង្កើតរូបភាពថ្មីនៃការទស្សនាកម្សាន្តនៅតំបន់ជនបទ

浙江建德：“果蔬乐园”打造乡村旅游观光新模式 新华社 图



រូបថតជាឯកសារអំពីការអនុវត្តការសាងសង់នៅត្រើយខាងត្បូងនៃវិស្វកម្មប្រឡាយមេឆ្លងទន្លេលឿងនៃគម្រោងបង្ហូរទឹកពីភាគខាងត្បូងទៅខាងជើង

南水北调中线总干渠穿黄（黄河）工程南岸施工资料照片 新华社 图

មានទាំងការរំដោះស្មារតីនិងការអនុវត្តតាមស្ថានភាពជាក់ស្តែង ទាំងការជំរុញជាទូទៅនិងការដោះស្រាយបញ្ហាលេចធ្លោទាំងការគូរប្លង់ទូទៅនិងការ“ស្ទាបថ្មឆ្លងទន្លេ(ធ្វើការដោយស្ទាបស្ទង់ជាជំហានៗ)”...

ការធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោយមានភាពកាន់តែស៊ីជម្រៅ បានបង្ហាញពីកម្លាំងរស់រវើកនៃការអភិវឌ្ឍន៍ប្រទេសចិន ។

ក្នុងនាមជា“កំពូលខួរក្បាល”នៃកំណែទម្រង់ចិន ក្រុមការងារមជ្ឈិមជាតិនៃការដឹកនាំការធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោយមានភាពកាន់តែស៊ីជម្រៅ បានរៀបចំកិច្ចប្រជុំ ៧ លើកក្នុងមួយឆ្នាំ ដែលជាការអនុវត្តដោយលម្អិតតាមផែនការទូទៅស្តីពីការធ្វើកំណែទម្រង់នៃកិច្ចប្រជុំពេញអង្គលើកទី ៣ នៃគណៈកម្មាធិការគណបក្សកុម្មុយនិស្តចិនអាណត្តិទី ១៨ ។

ផ្តោតសំខាន់ទៅលើលក្ខណៈជាប្រព័ន្ធ លក្ខណៈទូទៅនិងការសហការគ្នា កិច្ចប្រជុំទាំង ៧ លើក រៀបចំដោយមានលំដាប់លំដោយ និងដំណើរការអនុវត្តជាបន្តបន្ទាប់ ។

កិច្ចប្រជុំលើកទី ១ និងទី ២ របស់ក្រុមការងារមជ្ឈិម-ជាតិនៃការដឹកនាំការងារកំណែទម្រង់គ្រប់ជ្រុងជ្រោយឱ្យកាន់តែស៊ីជម្រៅ សំខាន់គឺគូរប្លង់ជាទូទៅ ដូចជាបានអនុម័ត“គោលការណ៍ស្តីពីការងារនៃក្រុមការងារមជ្ឈិមជាតិសម្រាប់ការដឹកនាំធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោយមានភាពកាន់តែស៊ីជម្រៅ”ជាដើម ហើយបានបង្កើតក្រុមការងារជំនាញ ៦ ដែលពាក់ព័ន្ធនឹងកំណែទម្រង់លើវិស័យផ្សេងៗ ដូចជាកំណែទម្រង់របបសេដ្ឋកិច្ចនិងអេកូ-អរិយធម៌ កំណែទម្រង់ប្រជាធិបតេយ្យនិងនីតិប្បញ្ញត្តិ កំណែទម្រង់របបវប្បធម៌ កំណែទម្រង់របបសង្គម កំណែទម្រង់របបកសាងគណបក្សនិងកំណែទម្រង់ការគ្រប់គ្រងវិន័យ ។



កិច្ចប្រជុំស្តីពីការងារសេដ្ឋកិច្ចមជ្ឈិមជាតិទើបបញ្ចប់ វិធានការកែទម្រង់មួយចំនួនក៏បានចាប់អនុវត្តជាបន្តបន្ទាប់ រៀប-ចំនិងផ្សព្វផ្សាយអំពីបទពិសោធន៍នៃតំបន់ពាណិជ្ជកម្មសេរីសៀងហៃ ហើយធនាគារ WEBANK នៅសិនចិនដែលជាធនាគារឯកជនសាកល្បងទី ១ បានបើកធ្វើអាជីវកម្មជាផ្លូវការ ។ល។

ខេត្តក្វាងតុង ក្រុងធានជីន និងខេត្តហុកគៀនបានក្លាយជាកន្លែងសាកល្បងក្រុមទី ២ បន្ទាប់ពីក្រុងសៀងហៃ ហើយនឹងផ្តល់ជាគំរូកាន់តែច្រើនដល់ការផ្លាស់មុខងាររដ្ឋាភិបាលនៅទូទាំងប្រទេសចិន ។

ការធ្វើកំណែទម្រង់ថ្មីលើដីធ្លីកំពុងតែចាប់ដំណើរការជាផ្លូវការ “មតិស្តីពីកំណែទម្រង់សាកល្បងអំពីការកែនប្រមូលដីធ្លី ការដាក់បញ្ចូលដីធ្លីសម្ងហភាពទៅក្នុងទីផ្សារហ៊ុននិងរបបផ្តល់ដីធ្លីសម្រាប់សាងសង់ផ្ទះនៅជនបទ”បានត្រូវគេបកស្រាយថាជា“ព្រួញទាំង ៣”នៃកំណែទម្រង់ដីធ្លីនៅតាមតំបន់ជនបទ ។

មិនតែប៉ុណ្ណោះទេ កំណែទម្រង់សហគ្រាសរដ្ឋក៏កំពុងសាកល្បងដំណើរការដែរ ។ បន្ទាប់ពីក្រុងសៀងហៃដាក់ចេញនូវគម្រោងកែទម្រង់សហគ្រាសរដ្ឋនៅចុងឆ្នាំទៅ ខេត្តក្រុងនានានៃប្រទេសចិនបានអនុវត្តតាមជំហានសៀងហៃដើម្បីកែទម្រង់លើរបបកម្មសិទ្ធិសហគ្រាស ។ នៅក្នុងសហគ្រាសមជ្ឈិមជាតិ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសម្បត្តិជាតិចិនបានប្រកាសនូវបញ្ជីឈ្មោះនៃសហគ្រាសមជ្ឈិមជាតិក្រុមទី ១ នៅខែកក្កដា ដែលមានឈ្មោះសហគ្រាសចំនួន ៦ ដោយចាប់ដំណើរការអនុវត្តការងារសាកល្បងលើកំណែទម្រង់ក្រុមហ៊ុនវិនិយោគរដ្ឋ របបក្រុមប្រឹក្សាភិបាល កម្មសិទ្ធិចម្រុះ និងការគ្រប់គ្រងវិន័យ ។

ឆ្នាំ ២០១៥ គឺជាឆ្នាំគន្លឹះនៃការធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោយមានភាពកាន់តែស៊ីជម្រៅ ។ ទោះជាមានការលំបាកយ៉ាងណាក៏ដោយ ក៏ត្រូវតែបោះជំហានទៅមុខដោយឥតងាករេឡើយ ។



ទិដ្ឋភាពនៃតំបន់រួចពន្ធវ៉ៃការឈាវក្នុងក្រុងសៀងហៃ

上海市外高桥保税区全景 新华社 图

# ប្រទេសចិនពង្រីកទំហំនាំចូល នាំមកនូវកាលានុវត្តភាពថ្មីដល់ពិភពលោកទាំងមូល

## 中国扩大进口为全球带来机遇

作为世界贸易大国，中国在加强出口的同时亦高度重视进口。近日，国务院出台了《关于加强进口的若干意见》，对此，商务部对外贸易司负责人表示，《意见》中的各项措施遵循以市场需求为导向的原则，着力发挥进口对优化结构和创新升级的促进作用。专家指出，中国政府不断开放市场，进口规模日益扩大，在促进国内经济发展的同时，为全球经济作出了重要贡献。

ក្នុងនាមជាប្រទេសពាណិជ្ជកម្មដ៏ធំមួយលើពិភពលោក ប្រទេសចិនបានផ្តោតសំខាន់ទៅលើការបង្កើនការនាំចេញ និងនាំចូលដោយព្រមពេលជាមួយគ្នា ។ ក្នុងពេលថ្មីៗនេះ ក្រុមប្រឹក្សាកិច្ចការរដ្ឋចិនបានដាក់ចេញនូវ“មតិមួយចំនួនស្តីពីការបង្កើនការនាំចូល”ហៅកាត់“មតិ” ហើយអ្នកទទួលខុសត្រូវនៃនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិនៃក្រសួងពាណិជ្ជកម្មចិនបានថ្លែងថា “មតិ”របស់ក្រុមប្រឹក្សាកិច្ចការរដ្ឋចិនបានចាត់ទុកតម្រូវការទីផ្សារជាគោលការណ៍មូលដ្ឋាន ដើម្បីជំរុញឱ្យការនាំចូលដើរតួនាទីសំខាន់ក្នុងការកែសម្រួលរចនាសម្ព័ន្ធ លើកកម្ពស់លំដាប់ថ្នាក់និងជំរុញការច្នៃប្រឌិត ។ អ្នកជំនាញការបានបញ្ជាក់ថា រដ្ឋាភិបាលចិនបានបើកទូលាយនូវទីផ្សារចិនជាបន្តបន្ទាប់ នាំចូលផលិតផលកាន់តែច្រើន ហើយទន្ទឹមនឹងពេលជំរុញការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិចិន ក៏បានរួមវិភាគទានជាច្រើនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចពិភពលោកផងដែរ ។

“មតិ”ដែលប្រកាសដោយក្រុមប្រឹក្សាកិច្ចការរដ្ឋចិនលើកនេះ បានពង្រីកទំហំនៃការនាំចូលរបស់ប្រទេសចិនដោយមានវិធានការសំខាន់ចំនួន ៨ វិស័យ ដូចជា ទី ១-លើកទឹកចិត្តឱ្យមានការនាំចូលគ្រឿងបរិក្ខារនិងគ្រឿងបន្លាស់គន្លឹះ ។ ទី ២-លើកទឹកចិត្តឱ្យមានការនាំចូលផលិតផលធនធានមានលក្ខណៈនឹងនរ ដើម្បីកែសម្រួលប្រព័ន្ធបម្រុងទុករបស់ចិន គាំទ្រសហគ្រាសនានាបង្កើតប្រព័ន្ធបម្រុងទុកខាងពាណិជ្ជកម្ម ហើយផ្តល់ការគាំទ្រដល់ការវិនិយោគនៅឯបរទេស លើកទឹកចិត្តការនាំចូលនូវធនធានយុទ្ធសាស្ត្រ និងពង្រីកដោយសមហេតុផលនូវទំហំនាំចូលធនធាន ដែលអាចកកើតឡើងវិញ ។ ទី ៣-បង្កើនការនាំចូលផលិតផលប្រើប្រាស់ដោយសមហេតុផល ពន្លឿនការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យជំងឺឆ្លងនៃសត្វនិងរុក្ខជាតិ ជាមួយប្រទេសពាក់ព័ន្ធអំពីជល




កំពង់ផែនៅតំបន់រួចពន្ធយ៉ាងសានក្នុងក្រុងសៀងហៃ
上海洋山保税港区 新华社 图



មន្ត្រីនៃមន្ទីរពិនិត្យជំងឺសត្វនិងរុក្ខជាតិកំពុងពិនិត្យទំនិញសណ្តែកសៀងដែលនាំចូលពីសហរដ្ឋអាមេរិក
检验检疫局工作人员在抽检来自美国的进口大豆 新华社 图

ផល ផ្លែឈើ សាច់គោ និងសាច់ចៀមជាដើម សកម្មជំរុញការចុះបញ្ជីពាណិជ្ជកម្មនៃសហគ្រាសកែច្នៃនិងផលិតផលដែលមានគុណភាពស្របតាមស្តង់ដារ ហើយគាំទ្រសហគ្រាសចិនដែលពេញលក្ខណៈធ្វើកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មអន្តរជាតិ និងលើកទឹកចិត្តសហគ្រាសចិនឱ្យបង្កើតដេប៉ូចែកចាយម៉ាកបរទេស ។ ទី ៤-ខិតខំពង្រីកការនាំចូលផ្នែកសេវាកមពាណិជ្ជ-កម្ម ជំរុញការនាំចូលសេវាកម្មផលិតកម្មនិងទេសចរណ៍លើវិស័យពិគ្រោះយោបល់ខាងពាណិជ្ជកម្ម ការសិក្សាស្រាវជ្រាវការសំថៃថាមពលនិងការពារបរិស្ថាន និងការផ្តល់សេវាកម្មខាងបរិស្ថានជាដើម ដែលជាតម្រូវការចាំបាច់របស់ប្រទេសចិន ។ ទី ៦-លើកកម្ពស់ថែមទៀត នូវកម្រិតងាយស្រួលនៃការនាំចូលផលិតផល ដោយអនុវត្តតាមគោលការណ៍អំពីការណាត់ពេលឆ្លងដែនទាំង ២៤ ម៉ោង និងថ្ងៃឈប់សម្រាកនៃផលិតផលនាំចូល ។ ទី ៧-ខិតខំបង្កើតវេទិកាស្តីពីការនាំចូលផលិតផល ។ ទី ៨-ចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការពហុភាគី ។

អ្នកជំនាញការពាក់ព័ន្ធបានបញ្ចេញយោបល់ថា "មតិ" របស់រដ្ឋាភិបាលចិនបានបង្កើនការនាំចូលបច្ចេកទេស ផលិត-ផល និងសេវាកម្ម ដែលនឹងអាចជួយបង្កើនការផ្គត់ផ្គង់ដ៏មានប្រសិទ្ធភាព និងបំពេញតម្រូវការផលិតកម្មនិងការរស់នៅ



ទំនិញម៉ាកបរទេសលើធ្នើរក្នុងផ្សារលក់ម្សៅទឹកដោះគោនៅក្រុងក្វាងចូវ
广州一家奶粉超市货架上的洋品牌 新华社 图



បុគ្គលិកនៃសហគ្រាសពាណិជ្ជកម្មអេឡិចត្រូនិចអន្តរជាតិឈុងឈីងកំពុងចែកចាយទំនិញនាំចូលដែលអតិថិជនបានទិញ
重庆跨境电商企业员工在分拣消费者订购的进口商品 新华社 图

របស់ប្រជាជនចិន លើកកម្ពស់គុណភាពផលិតផល ជំរុញការច្នៃប្រឌិតនិងបង្កើតរបរថ្មី កែសម្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច ហើយក៏នឹងអាចផ្តល់ផលប្រយោជន៍ដល់ការប្រើប្រាស់រូបិយប័ណ្ណបរទេសឱ្យបានល្អប្រសើរជំរុញការរក្សាតុល្យភាពរវាងចំណូលនិងចំណាយអន្តរជាតិ ព្រមទាំងលើកកម្ពស់នូវកម្រិតនៃការបើកទូលាយនិងការធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិទៀតផង ។

ជាការពិតណាស់ បើឈរលើជំហររៀបចំធនធានឱ្យបានសមហេតុផល និងនាំចូលបច្ចេកទេសទំនើប ប្រទេសចិនមានតម្រូវការដ៏ធំធេងក្នុងការនាំចូល ។ អ្នកវិភាគបានបញ្ជាក់ថា បច្ចុប្បន្ន ប្រទេសចិនកំពុងជំរុញការកែសម្រួលរចនាសម្ព័ន្ធផ្លាស់ទម្រង់សេដ្ឋកិច្ច និងលើកកម្ពស់កម្រិតថ្នាក់លើវិស័យឧស្សាហកម្ម ដូច្នេះការនាំចូលគ្រឿងបរិក្ខារ បច្ចេកទេស និងគ្រឿងបន្លាស់ជឿនលឿន ព្រមទាំងសេវាកម្មផលិតកម្មកម្រិតខ្ពស់ជាដើម មិនត្រឹមតែនឹងអាចបំពេញតម្រូវការនៃផលិតកម្មនិងការអភិវឌ្ឍន៍ក្នុងប្រទេសចិនប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ជាពេលសម្រាប់ជំរុញការផ្លាស់ទម្រង់និងលើកកម្ពស់កម្រិតថ្នាក់នៃប្រព័ន្ធឧស្សាហកម្មក្នុងប្រទេសចិនផងដែរ ។

ការនាំចូលរបស់ប្រទេសចិនមិនគ្រាន់តែបានបំពេញតម្រូវការរបស់ប្រទេសចិនប៉ុណ្ណោះទេ ហើយក៏បានបង្កើតកាលានុវត្តភាពថ្មីសម្រាប់ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃបណ្តាប្រទេសនានាលើពិភពលោកទៀតផង ។ លោក ហ៊ឺ ម៉ាវឈុន ប្រធានមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអំពីការទូតនិងសេដ្ឋកិច្ចនៃសកលវិទ្យាល័យឈីងហួ បានថ្លែងថា ប្រទេសចិនមានតម្រូវការដ៏ធំធេង ហើយតម្រូវការតាមទីផ្សារក្នុងស្រុកមានកម្លាំងទាក់ទាញដូចដែកឆក់អញ្ចឹង ដែលបាននិងកំពុងដើរតួនាទីសំខាន់ណាស់ ក្នុងការជំរុញការធ្វើពាណិជ្ជកម្មអន្តរជាតិរបស់ចិន រឹតបន្តឹងទំនាក់ទំនងរវាងប្រទេសចិននិងបណ្តាប្រទេសផ្សេងៗ និងការបង្កើតពិភពលោកដ៏សុខដុមរមនាមួយ ។

# ធនាគារធំៗលើពិភពលោកដណ្ដើមបង្កើតសាខានៅក្រុងឆឹងទូ

## 全球大银行争相扎根成都

在成都的市中心穿梭，走不了几公里就能看到一些耳熟能详的大银行，汇丰、渣打、花旗、苏格兰皇家、摩根大通、友利……如果将视野拓展到金融范畴，则能看到富登、中航安盟等机构的身影，从银行到保险，从小额贷款到基金公司，都有外国企业参与，金融拼图“洋味十足”。这里现在有着16家外资银行，以及更多的保险、贷款和基金等外资机构，是整个西部地区金融机构种类最齐全、开放度最高的金融城市。（翟茜茜 译）



ធនាគារទី ១ នៅភូមិភាគកណ្ដាលនិងខាងលិចចិនដីគោក ដែលវិនិយោគដោយសហគ្រិនតៃវ៉ាន់ បានត្រូវបង្កើតឡើងនៅក្រុងឈឹងទូ

中国大陆中西部首家台资银行在成都成立 cnsphoto

ពេលដើរចូលទៅក្នុងទីក្រុងឆឹងទូ មិនយូរប៉ុន្មានក៏អាចមើលឃើញធនាគារធំៗ ដែលអ្នកផងស្គាល់ច្បាស់ ដូចជាធនាគារ HSBC STAN Citibank RBS JPMorgan Wooribank ... ហើយខាងវិស័យហិរញ្ញវត្ថុ នៅមានក្រុមហ៊ុន Fullerton Credit និងក្រុមហ៊ុនធានារ៉ាប់រង Groupama AVIC Insurance ជាដើម ចាប់ពីធនាគារដល់អង្គការធានារ៉ាប់រង ពីមីក្រូហិរញ្ញប្បទានដល់ក្រុមហ៊ុនមូលនិធិ សុទ្ធតែមានការចូលរួមពីសំណាក់ក្រុមហ៊ុនបរទេស ។ បច្ចុប្បន្ននៅទីនេះមានធនាគារទុនបរទេសចំនួន ១៦ និងអង្គការទុនបរទេសជាច្រើនមានវិស័យធានារ៉ាប់រង ឥណទាននិងមូលនិធិជាដើម ពោលគឺជាទីក្រុងហិរញ្ញវត្ថុដែលមានប្រភេទអង្គការហិរញ្ញវត្ថុច្រើនបំផុត និងកម្រិតបើកទូលាយខ្ពស់បំផុតនៅតំបន់ភាគខាងលិចប្រទេសចិន ។

បើចង់បណ្ដាក់ទុននៅប្រទេសចិន ត្រូវតែយកតំបន់ភាគខាងលិចជាអាទិភាព បើបណ្ដាក់ទុននៅតំបន់ភាគខាងលិចត្រូវតែយកក្រុងឆឹងទូជាអាទិភាព ។ មានផ្នែកឧស្សាហកម្មជាច្រើនបានផ្ដោតការយកចិត្តទុកដាក់ថា ក្រុងឆឹងទូជាតំបន់សម្បូរទ្រព្យសម្បត្តិ មានហានិភ័យទាប និងសមត្ថភាពចំណាយខ្លាំង ដូច្នេះបានដណ្ដើមគ្នាចូលក្នុងទីផ្សារក្រុងឆឹងទូ ។ ធនាគារ Wooribank របស់កូរ៉េខាងត្បូងបានធ្វើការបង្ហាញដូចខាងលើនេះ ។ ធនាគារនេះបានចូលក្នុងទីផ្សារចិននាឆ្នាំ ១៩៩២ គឺដោយមកពីមានសហគ្រាសទុនកូរ៉េខាងត្បូងជាច្រើនមកបណ្ដាក់ទុននៅប្រទេសចិន និងមានអាណិកជនចិនសញ្ជាតិកូរ៉េខាងត្បូងជាច្រើនមកធ្វើការនិងរស់នៅក្នុងប្រទេសចិន ក៏បានក្លាយជាតម្រូវការជាច្រើន ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុងឆឹងទូមានធនធានមនុស្សខាងហិរញ្ញវត្ថុហូរចូលច្រើន មានមនុស្សច្រើនស្រឡាញ់ចូលចិត្តទីក្រុងនេះក្រោយពីមកដល់ទីក្រុងនេះ និងស្នាក់នៅទីក្រុងនេះ ។ តាមដំណឹងនៃការិយាល័យហិរញ្ញវត្ថុក្រុងឆឹងទូបានឱ្យដឹងថា មានធនធានមនុស្សផ្នែកហិរញ្ញវត្ថុនៃអង្គការទុនបរទេសច្រើន ដែលលាលែងពីតួនាទីរបស់ខ្លួននៅក្រុមហ៊ុនពីដើមដោយសារផ្លាស់ប្ដូរការងារជាដើម ហើយបានសម្រេចចិត្តទៅធ្វើការមួយទៀតនៅក្រុងឆឹងទូ ដោយមិនចង់ចាកចេញពីទីក្រុងនេះ តើមកពីមូលហេតុអ្វី? គឺដោយមកពីក្រុងឆឹងទូជាទីក្រុង ដែលធនធានមនុស្សនៃអង្គការហិរញ្ញវត្ថុទុនបរទេសទាំងនេះស្រឡាញ់ចូលចិត្ត ។

កម្លាំងទាក់ទាញបែបនេះមិនអាចខ្វះបាននូវការគាំទ្ររបស់រដ្ឋាភិបាលនោះទេ ។ កាលពីឆ្នាំទៅ តម្លៃបន្ថែមខាងហិរញ្ញវត្ថុនៃក្រុងឆឹងទូមាន ៨៩.៣០០ លានយ៉ាន់ ត្រូវជា ៩,៨% នៃ GDP ជាមុខរបរសសរទ្រូងយ៉ាងពិតប្រាកដ ។

ក្រុងឆឹងទូនៅបានប្រកាន់ខ្ជាប់ការធ្វើកិច្ចប្រជុំសន្ទនានៃសហគ្រាសទុនបរទេសទៀតផង ។ កិច្ចប្រជុំនោះបានប្រារព្ធនៅរាល់ត្រីមាស ហើយអភិបាលក្រុងឆឹងទូបានចូលរួមនិងបំពេញកិច្ចការក្នុងកិច្ចប្រជុំរាល់លើក ។ ឆ្នាំ ២០០៨ ក្រុមហ៊ុន Fullerton Credit បានចាប់ផ្ដើមបង្កើតសាខាក្រុមហ៊ុននៅក្រុងឆឹងទូរហូតដល់បច្ចុប្បន្ន ក្រុមហ៊ុននេះមានសាខាក្រុមហ៊ុនចំនួន ៣០ នៅប្រទេសចិន ។ សាខាក្រុមហ៊ុនទាំងនេះទទួលការរីកចម្រើនយ៉ាងឆាប់រហ័សនៅប្រទេសចិន និងបានទាក់ទាញក្រុមហ៊ុនមីក្រូហិរញ្ញប្បទានទុនបរទេសចំនួន ៧ បង្កើតសាខាក្រុមហ៊ុននៅក្រុងឆឹងទូ តួលេខនេះជាតួលេខធំបំផុតក្នុងប្រទេសចិន ។

រីឯគោលនយោបាយក៏បានដើរតួនាទីជាក់ស្ដែងដែរ ។ ក្នុងដំណើរកសាងទីក្រុងទំនើបភាវូបនីយកម្មអន្តរជាតិដ៏ធំ ក្រុងឆឹងទូបានទទួលគោលនយោបាយកាន់តែច្រើនជាបន្តបន្ទាប់ដែលមានអំណោយផលដល់ការអភិវឌ្ឍន៍នៃអង្គការហិរញ្ញវត្ថុទុនបរទេស ដូចជាក្រុងពិសោធន៍ទូទាត់ប្រាក់យ៉ាន់ចិនដោយឆ្លងដែន ក្រុងពិសោធន៍ប្រកបអាជីវកម្មនិងគ្រប់គ្រងប្រាក់ទុនរូបិយប័ណ្ណបរទេសនៃទីចាត់ការទូទៅនៃក្រុមហ៊ុនឆ្លងប្រទេស ក្រុងពិសោធន៍ការប្ដូរប្រាក់ផ្នែកឯកជនដោយអង្គការមិនមែនហិរញ្ញវត្ថុ និងក្រុងពិសោធន៍ធ្វើការច្នៃប្រឌិតថ្មីផ្នែកសេវាកម្មបច្ចេកទេសហិរញ្ញវត្ថុខាងធុរកិច្ចអេឡិចត្រូនិចចល័តជាដើម ។ ឧទាហរណ៍ដូចជា ក្នុងការទូទាត់ដោយប្រាក់យ៉ាន់ចិនឆ្លងដែន ធនាគារទុនបរទេសមានឧត្តមានុភាពច្រើន ទោះបីជាឆ្នាំនេះបានកន្លងផុតទៅពាក់កណ្ដាលឆ្នាំហើយក្ដី តែភារកិច្ចនៃក្រុងឆឹងទូនៅទូទាំងឆ្នាំគឺជិតបានបញ្ចប់ហើយ ។

បច្ចុប្បន្ននេះ ក្រុងឆឹងទូមានគោលនយោបាយសម្រាប់ផ្ដល់ការគាំទ្រជាពិសេសដល់អង្គការហិរញ្ញវត្ថុទុនបរទេសដែលសកម្មលើកឡើងនូវវិធានការច្នៃប្រឌិតថ្មី មិនថាខាងរបៀបផ្ដល់សេវាកម្មឬក៏ធ្វើការច្នៃប្រឌិតថ្មីចំពោះផលិតផលក្ដី គឺសុទ្ធតែអាចទទួលបានគោលនយោបាយអនុគ្រោះ ។ រីឯវិស័យហិរញ្ញវត្ថុតាមបណ្ដាញអ៊ីនធើណេតដែលទើបតែរីកចម្រើនកាន់តែមានការស្វាគមន៍ចំពោះទុនបរទេសទៀតផង ។




មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិឈឹងទូ

成都国际金融中心 cnsphoto

# ច្រកអន្តរជាតិអឺលានហោធី




អ្នកដំណើរឆ្លងដែនចូលប្រទេសចិនតាមច្រកអន្តរជាតិអឺលានហោធី

二连浩特口岸入境旅客顺利通关　cnsphoto

## 二连浩特口岸

文/岚　筱

二连浩特口岸位于内蒙古自治区锡林郭勒盟西部，东西南三面与美丽富饶的苏尼特草原相邻，北与蒙古国扎门乌德隔界相望，是欧亚大路桥中的重要战略枢纽。

ច្រកអន្តរជាតិអឺលានហោធី មានទីតាំងស្ថិតនៅភាគខាងលិចនៃស្រុកស៊ីលីនគួលី តំបន់ស្វយ័តម៉ុងហ្គោលីក្នុងដែលព័ទ្ធជុំវិញទៅដោយវាលស្មៅស៊ូនីធីនៅទិសខាងកើត លិច និងត្បូង ដែលជាវាលស្មៅមានទេសភាពស្រស់ស្អាតនិងធនធានធម្មជាតិសម្បូរបែប ។ ច្រកអន្តរជាតិអឺលានហោធីគឺជាច្រកយុទ្ធសាស្ត្រដ៏សំខាន់មួយសម្រាប់តភ្ជាប់ដីគោកអាស៊ីនិងអឺរ៉ុបដែលជាប់នឹងច្រកអន្តរជាតិហ្សាមីនអ៊ូឌី ( Dzamiin-Üüd )នៃប្រទេសម៉ុងហ្គោលី ។

ទីក្រុងអឺលានហោធីមានចម្ងាយត្រឹមតែ ៩ គីឡូម៉ែត្រប៉ុណ្ណោះពីទីក្រុងហ្សាមិនអ៊ូឌីដែលជាទីក្រុងច្រកអន្តរជាតិធំជាងគេរបស់ម៉ុងហ្គោលី ។ ចំណែកច្រកអន្តរជាតិអឺលានហោធីគឺជាច្រកផ្លូវថ្នល់និងផ្លូវដែកដែលធំជាងគេរបស់ប្រទេសចិន ហើយមានភាពងាយស្រួលក្នុងការធ្វើដំណើរទាំងក្នុងនិងក្រៅប្រទេសចិន ។ នៅខែ មករា ឆ្នាំ ១៩៥៦ ស្រុកអឺលានហោធីត្រូវបានបង្កើតឡើងជាផ្លូវការ ហើយផ្លូវដែកអន្តរជាតិប៉េកាំង-អ៊ូឡង់បាទ័រ-មូស្គូក៏បានដាក់ឱ្យប្រើប្រាស់ផងដែរ ។ នៅខែ មករា ឆ្នាំ ១៩៦៦ ក្រុមប្រឹក្សាកិច្ចការរដ្ឋចិនបានអនុម័តឱ្យបង្កើតទីក្រុងអឺលានហោធី ។ នៅខែ កក្កដា ឆ្នាំ ១៩៩២ ក្រុមប្រឹក្សាកិច្ចការរដ្ឋចិនបានអនុម័តឱ្យដាក់បញ្ចូលទីក្រុងអឺលានហោធីក្នុងបញ្ជីទីក្រុងបើកទូលាយតាមព្រំដែនទាំង ១៣ ក្នុងប្រទេសចិន ។

ច្រកអន្តរជាតិអឺលានហោធីមានឧត្តមភាពខាងទីតាំងភូមិសាស្ត្រ ដែលជាទីចាប់ផ្តើមនៃផ្លូវជាតិលេខ ២០៨ និងផ្លូវដែកជីនីង-អឺលានហោធីដែលមានចម្ងាយ ៧ ៦២៣ គីឡូម៉ែត្រពីរដ្ឋធានីមូស្គូនៃប្រទេសរុស្ស៊ី ចម្ងាយ ៧២០ គីឡូម៉ែត្រពីរដ្ឋធានីអ៊ូឡង់បាទ័រនៃប្រទេសម៉ុងហ្គោលី ចម្ងាយ ៦៨០ គីឡូម៉ែត្រពីក្រុងប៉េកាំង និងមានចម្ងាយ ៣៨០ គីឡូម៉ែត្រពីក្រុងហ៊ូហ៊ីហោធី ។ ច្រកអន្តរជាតិនេះគឺជាច្រកអន្តរជាតិដីគោក ដែលនៅជិតនឹងក្រុងប៉េកាំងជាងគេក្នុងប្រទេសចិន និងជាច្រកផ្លូវសម្រាប់តភ្ជាប់ទ្វីបអឺរ៉ុបនិងអាស៊ី ដែលមានភាពងាយស្រួលបំផុតក្នុងការធ្វើដំណើរទៅមក ។

ច្រកអន្តរជាតិអឺលានហោធី ដែលជាទីចាប់ផ្តើមនៃផ្លូវដែកជីនីង-អឺលានហោធីនោះ គឺជាច្រកអន្តរជាតិផ្លូវដែកតែមួយគត់សម្រាប់ធ្វើដំណើរពីប្រទេសចិនទៅកាន់ប្រទេសម៉ុងហ្គោលី ។ សព្វថ្ងៃ នៅច្រកអន្តរជាតិនេះមានផ្លូវដែកស្តង់ដារនិងផ្លូវដែកមានទទឹងធំសរុប ១១៧ ខ្សែ ក្នុងនោះមានផ្លូវដែកមានទទឹងធំចំនួន ៥២ ខ្សែ និងផ្លូវដែកស្តង់ដារ ៦៥ ខ្សែ ហើយមានឃ្លាំងនិងទីលានស្តុកទំនិញ ៥ កន្លែង ដែលអាចស្តុក ផ្ទេរនិងវេចខ្ចប់ទំនិញបាន ។ គួរបញ្ជាក់ថា ច្រកអន្តរជាតិផ្លូវដែកនេះមានទីលានស្តុក និងលើកដាក់ទំនិញធំជាងគេក្នុងទ្វីបអាស៊ីព្រមទាំងប្រព័ន្ធត្រួតពិនិត្យរទេះភ្លើង H៩៨៦ ដ៏ជឿនលឿនលើពិភពលោក ។

ផ្លូវថ្នល់នៃច្រកអន្តរជាតិអឺលានហោធីចាប់ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ ១៩៩២ ដែលសាងសង់លើមូលដ្ឋាននៃច្រកផ្លូវចេញចូលរបស់បុគ្គលិកការងារ ផ្នែករទេះភ្លើងនៃប្រទេសទាំងពីរចិននិងម៉ុងហ្គោលី ។ ច្រកឆ្លងដែនថ្មីតាមផ្លូវថ្នល់ស្ថិតនៅភាគខាងលិចនៃខ្លោងទ្វារប្រទេស ដែលមានទំហំ ៣៤,៣ ម៉ឺនម៉ែត្រការ៉េ ។ គ្រឿងបរិក្ខារនៅទីនេះសំខាន់មានអគារការិយាល័យទំហំ ៣ ៨៨៩ ម៉ែត្រការ៉េ អគារគយទំហំ ២៧៤ ម៉ែត្រការ៉េ អគារប្រកាសបញ្ជីទំនិញទំហំ ៥៣៤ ម៉ែត្រការ៉េ បន្ទប់ស្នាក់នៅរបស់បុគ្គលិកការងារទំហំ ២ ១០០ ម៉ែត្រការ៉េ និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធមួយចំនួនទៀត ។ ខាងជើងនៃច្រកអន្តរជាតិតភ្ជាប់នឹងប្រទេសម៉ុងហ្គោលី ឯខាងត្បូងជាប់ជាមួយផ្លូវជាតិលេខ ២០៨ របស់ប្រទេសចិន ។ តំបន់ត្រួតពិនិត្យនិងឆ្លងដែននៃច្រកអន្តរជាតិតាមផ្លូវថ្នល់នេះ គឺជាច្រកមួយដែលបានប្រមូលផ្តុំនូវមុខងារចម្រុះ ដោយអាចធ្វើការត្រួតពិនិត្យ ស្តុកនិងដឹកជញ្ជូនទំនិញ ហើយក៏អាចផ្តល់សេវាកម្មខាងការរស់នៅដល់បុគ្គលិកការងារផងដែរ ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ សាលាក្រុងអឺលានហោធីបានខិតខំប្រឹងប្រែងដើម្បីបំពេញបន្ថែមមុខងារទាំង ៣ គឺត្រួតពិនិត្យនិងឆ្លងដែន ពាណិជ្ជកម្មចរាចរណ៍ទំនិញ ផលិតនិងកែច្នៃទំនិញ តាមរយៈការផ្លាស់ទម្រង់ កែសម្រួលរចនាសម្ព័ន្ធ បើកទូលាយ និងលើកកម្ពស់គុណភាពនៃច្រកអន្តរជាតិអឺលានហោធី ដែលបានធ្វើឱ្យក្រុងនេះទទួលបានការរីកចម្រើនយ៉ាងឆាប់រហ័ស និងការកែលម្អបរិស្ថានថែមទៀតផង ជាពិសេសបានកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់បង្កើតច្រកអន្តរជាតិអឺរ៉ុប-អាស៊ីទៀតផង ។



រថយន្តដឹកទំនិញចិនឆ្លងដែនចូលប្រទេសម៉ុងហ្គោលីតាមច្រកអន្តរជាតិអឺលានហោធី

满载中国货物的车队通过二连浩特口岸驶往蒙古国　cfp 图

# ស្រុកអ៊ីយាន់ដ៏ស្រស់ស្អាតពិពណ៌នានូវសុបិនដ៏អស្ចារ្យ

## 美丽沂源绘就跨越梦

山东省沂源县是“牛郎织女传说之乡”。千百年来，“牛郎织女”的故事在这里代代流传。如今，在中华大地同心共筑“中国梦”时，“牛郎织女故里”再书发展传奇——沂源儿女齐力共绘“跨越梦”。

（翟茜茜 译）



កម្មករកំពុងកែច្នៃទ្រនាប់ស្បែកជើងនៅក្នុងសហគ្រាសផលិតទ្រនាប់ស្បែកជើងមួយនៅស្រុកអ៊ីយាន់

沂源县一鞋垫加工企业，工人在加工工艺鞋垫　新华社 图

បើបើកមើលផែនទីនៃខេត្តសានតុង អ្នកនឹងអាចឃើញស្រុកសម្បូរដោយភ្នំបៃតងមួយដែលឋិតនៅចំកណ្ដាលខេត្តសានតុង វាគឺជាស្រុកអ៊ីយាន់ក្រុងជឺបូ ដែលត្រូវបានគេសន្មតថា “ខ្នងនៃខេត្តសានតុង” ។

ស្រុកអ៊ីយាន់គឺជា “ស្រុកនៃប្រភពរឿងនិទានបុរសគង្វាលនិងនារីតម្បាញ” ។ រាប់រយពាន់ឆ្នាំកន្លងទៅ រឿងនិទាននេះបានតំណាលតៗគ្នាពីមួយជំនាន់ទៅមួយជំនាន់ ។ បច្ចុប្បន្ន នៅពេលបងប្អូនជនជាតិចិនរួមចិត្តរួមថ្លើមពួតដៃជាមួយគ្នា ដើម្បីកសាង“សុបិនរបស់ប្រទេសចិន” ស្រុកកំណើតនៃរឿងព្រេងនិទាននេះបានបង្កើតរឿងអច្ឆរិយៈថ្មីមួយ ពោលថាស្រុកអ៊ីយាន់ដ៏ស្រស់ស្អាតកំពុងតែពិពណ៌នាអំពីសុបិនដ៏អស្ចារ្យ ។

សុបិនរបស់អ៊ីយាន់គឺពន្លឿនដំណើរនៃការសម្រេចទំនើបភាវូបនីយកម្ម ចូលរួមក្នុងជួរមុខក្នុងការអភិវឌ្ឍន៍នៃខេត្តសានតុង ។ ដើម្បីសម្រេចសុបិននេះ ស្រុកអ៊ីយាន់បានពង្រឹងដោយឥតឈប់ឈរនូវគំនិតទស្សនៈ ដែលចាត់ទុកការរស់នៅរបស់ប្រជាជនជាវិស័យអាទិភាព កសាងអេកូ-អរិយធម៌ អភិវឌ្ឍន៍ខ្លឹមសារ និងសម្រួលការអភិវឌ្ឍន៍ទីក្រុងនិងជនបទដោយព្រមពេលជាមួយគ្នា ផ្ដោតសំខាន់ទៅលើការអនុវត្តការងារមូលដ្ឋានកសាងមូលដ្ឋានគ្រឹះយ៉ាងរឹងមាំ និងកំណត់ផែនការរយៈពេលវែង ហើយយកចិត្តទុកដាក់លើការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ មានលក្ខណៈសម្របសម្រួលនិងនិរន្តរភាព ដើម្បីពន្លឿនដំណើរអភិវឌ្ឍន៍ដោយលោតផ្លោះ និងធ្វើឱ្យសុបិនអ៊ីយាន់ក្លាយជាការពិតលើទឹកដីដ៏ចំណាស់និងអាថ៌កំបាំងមួយនេះ ។

ដោយឈរលើស្ថានភាពជាក់ស្ដែង ស្រុកអ៊ីយាន់បានលើកឡើងនូវទស្សនៈ“កសាងជាថ្មីចំនួនពីរចំណុច”សម្រាប់ជាកម្លាំងចលករនៃការអភិវឌ្ឍន៍ដោយលោតផ្លោះ ។ ធ្វើការងារជុំវិញផែនការ“កសាងទីរួមស្រុកថ្មីមួយទៀត” ព្រមទាំងប្រកាន់ខ្ជាប់នូវការ“ពង្រីកឱ្យទូលំទូលាយ ធ្វើឱ្យមានគុណភាពខ្ពស់ និងបង្កើតលក្ខណៈពិសេសផ្ទាល់ខ្លួន” ពន្លឿនការពង្រីកទ្រង់ទ្រាយទីក្រុងឱ្យកាន់តែធំ លើកកម្ពស់នូវមុខងារនិងខ្លឹមសារដើម្បីកសាងទីក្រុងពិសេស ដែលមានទឹកដីអេកូឡូស៊ីដ៏ស្រស់ស្អាត ស័ក្ដិសមនឹងការរស់នៅនិងការធ្វើវិនិយោគ ។ ធ្វើការងារជុំវិញផែនការ“កសាងតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចថ្មីមួយទៀត” សម្រាប់កំណត់ផែនការបង្កើតតំបន់ឧស្សាហកម្មបច្ចេកទេសថ្មីនិងកម្រិតខ្ពស់ ដែលមានផ្ទៃក្រឡា ១៤,៧ គីឡូម៉ែត្រការ៉េ បង្កើតជាតំបន់ប្រមូលផ្ដុំនូវឧស្សាហកម្មបច្ចេកទេសកម្រិតខ្ពស់ និងតំបន់នាំមុខខាងបច្ចេកទេសនិងវិទ្យាសាស្ត្រក្នុងស្រុក ។ បច្ចុប្បន្ន បើសម្លឹងមើលទៅស្រុកអ៊ីយាន់ ការកសាងស្រុកឧស្សាហកម្មថ្មីនៅភាគខាងកើតបានទទួលស្នាដៃគួរឱ្យកត់សម្គាល់ ឯការកសាងតំបន់ថ្មីនៅតាមមាត់ទន្លេនិងបឹងក៏មានភាពកាន់តែល្អប្រសើរ ការកែលម្អតំបន់ចាស់កំពុងតែដំណើរការយ៉ាងរលូន ដែលនឹងអាចបង្កើតជាស្រុកទំនើបកម្មថ្មីមួយ



នារីដែលជាប្រជាកសិករមួយម៉ឺននាក់កំពុងធ្វើការងារផ្សេងៗ ដើម្បីបង្កើនចំណូលនៅរដូវរងាដែលជារដូវមិនបាច់ធ្វើស្រែ

山东沂源万名农家女冬闲创业忙增收　新华社 图

ដែលមានទឹកដីស្រស់ស្អាត ស័ក្ដិសមនឹងការរស់នៅ ។

នៅស្រុកអ៊ីយាន់ ទោះបីជាលោកអ្នកដើរចូលក្នុងភូមិ ឬក្នុងទីរួមស្រុកក៏ដោយ នៅទីណាៗក៏អាចឃើញភ្នំខ្ពស់សន្ធឹមព្រៃឈើខៀវស្រងាត់និងទឹកទន្លេថ្លាឆ្វង់ ។ ប៉ុន្មានឆ្នាំកន្លងទៅនេះ ស្រុកអ៊ីយាន់ប្រកាន់ខ្ជាប់នូវការកសាងស្រុកដោយអាស្រ័យលើកិច្ចស្ដារប្រព័ន្ធអេកូឡូស៊ី ហាមមិនឱ្យជីកយកដីភ្នំ កាប់ឈើលើភ្នំ និងចាក់បំពេញចង្អូរតាមជើងភ្នំ ដើម្បីច្របាច់បញ្ចូលនូវទស្សនៈអេកូ-អរិយធម៌ទៅក្នុងការអភិវឌ្ឍន៍លើគ្រប់វិស័យក្នុងសង្គម ព្រមនិងបានចាត់ទុកចំណុចនេះជាគោលការណ៍ ដែលត្រូវគោរពនិងអនុវត្តក្នុងរយៈពេលយូរ ។

“អេកូ-អរិយធម៌”មិនគ្រាន់តែបាននាំមកនូវភ្នំស្អាត ទឹកថ្លា និងព្រៃបៃតងជូនដល់ស្រុកអ៊ីយាន់ប៉ុណ្ណោះទេ ហើយថែមទាំងបានបង្កើតឱ្យមានការផ្លាស់ប្ដូរនៃរបៀបអភិវឌ្ឍន៍ទៀតផង ។ “ភ្នំស្អាតនិងទឹកថ្លា” បាននាំមកនូវទ្រព្យសម្បត្តិ ។ ស្រុកអ៊ីយាន់ខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍន៍វិស័យសេវាកម្មទេសចរណ៍ និងកសិកម្មទំនើប ដោយអាស្រ័យលើអេកូ-បរិស្ថានដ៏ល្អប្រសើរដែលបានលើកកម្ពស់ប្រាក់ចំណូលរបស់ប្រជាកសិករ ។ ជាពិសេស ពូជផ្លែប៉ោមឈ្មោះ“ក្រហមអ៊ីយាន់” ដែលបង្កាត់នៅទីនេះ បានឆ្លងកាត់ការវាយតម្លៃ និងការទទួលស្គាល់ពីគណៈកម្មការវាយតម្លៃកសិផលថ្នាក់ខេត្ត និងបានត្រូវគេប្រសិទ្ធនាមថា“ប្រភេទប៉ោមថ្មីរបស់ជនជាតិចិន” ។ សព្វថ្ងៃស្រុកអ៊ីយាន់អាចដាំបានផ្លែប៉ោមពូជ“ក្រហមអ៊ីយាន់”ចំនួន ៦០០ លានគីឡូក្រាមក្នុងមួយឆ្នាំ ដែលមានតម្លៃសរុបជាង ៣ ០០០ លានយ៉ាន់ប្រាក់ចិន ហើយបានជំរុញដល់ការអភិវឌ្ឍន៍លើវិស័យអេកូ-ទេសចរណ៍ ឧស្សាហកម្មកែច្នៃនិងវេចខ្ចប់ ការចរាចរណ៍ទំនិញ ព្រមនិងវិស័យផ្សេងៗជាង ១០ ទៀត ដែលបានក្លាយជាសសរទ្រូងសម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅតាមតំបន់ជនបទ ។

# រួមគ្នាស្ថាបនាផ្លូវសូត្រលើសមុទ្រ តភ្ជាប់សុបិនអាស៊ីប៉ាស៊ីហ្វិក សិក្ខាសាលាស្ដីពីកិច្ចសហប្រតិបត្តិការប្រព័ន្ធផ្សព្វផ្សាយអាស៊ាននិងចិន ជប៉ុន កូរ៉េខាងត្បូង(១០+៣) លើកទី ៧ ប្រារព្ធធ្វើនៅក្រុងប៉េកាំង

## 共建海上丝路　联通亚太梦想
## ——第七届东盟与中日韩（10+3）媒体合作研讨会在北京举行

2014年12月16日，以“共建海上丝路，联通亚太梦想”为主题的第七届东盟与中日韩（10+3）媒体合作研讨会在北京举行。

នាថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤ សិក្ខាសាលាស្ដីពីកិច្ចសហប្រតិបត្តិការប្រព័ន្ធផ្សព្វផ្សាយអាស៊ាន និងចិន ជប៉ុន កូរ៉េខាងត្បូង(១០+៣)លើកទី ៧ បានប្រារព្ធធ្វើនៅក្រុងប៉េកាំង ក្រោមប្រធានបទ“រួមគ្នាស្ថាបនាផ្លូវសូត្រលើសមុទ្រ តភ្ជាប់សុបិនអាស៊ីប៉ាស៊ីហ្វិក” ។

លោក យ៉ាង ជីនអ៊ូ ចាងហ្វាងទីភ្នាក់ងារកាសែតប្រជាជនដេលីរបស់ចិន បានថ្លែងសុន្ទរកថាក្នុងពិធីសម្ពោធបើកថា ឆ្នាំទៅ ឯកឧត្តមប្រធានាធិបតី ស៊ី ជីនភីង បានលើកឡើងពីយុទ្ធសាស្ត្រ“រួមគ្នាស្ថាបនាផ្លូវសូត្រលើសមុទ្រប្រចាំសតវត្សរ៍ទី ២១”ក្នុងឱកាសឯកឧត្តមអញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសឥណ្ឌូនេស៊ី ។ ផ្លូវសូត្រលើសមុទ្រសម្រាប់សតវត្សរ៍ទី ២១ គឺជាផ្លូវសន្តិភាពនិងអភិវឌ្ឍន៍ ផ្លូវផ្ដល់ផលប្រយោជន៍ទៅវិញទៅមកនិងឈ្នះ-ឈ្នះ ផ្លូវបើកចំហនិងមានស្មារតីយោគយល់និងបង្រួបបង្រួម ។ គោលបំណងនៃការរៀបចំសិក្ខាសាលាលើកនេះ គឺបន្តនិងផ្សព្វផ្សាយពីស្មារតីសន្តិភាពកិច្ចសហប្រតិបត្តិការ ផ្ដល់ផលប្រយោជន៍គ្នាទៅវិញទៅមកឈ្នះ-ឈ្នះ បើកចំហនិងមានអធ្យាស្រ័យដែលតំណាងដោយផ្លូវសូត្រលើសមុទ្រ ដើម្បីឱ្យបណ្ដាញសារព័ត៌មានចូលរួមចំណែកកាន់តែច្រើនក្នុងការរួមគ្នាស្ថាបនាផ្លូវសូត្រលើសមុទ្រប្រចាំសតវត្សរ៍ទី ២១ និងជំរុញកិច្ចសហប្រតិបត្តិការនៅតំបន់អាស៊ីបូព៌ា ។



ឯកឧត្តម លីវ យូនសាន សមាជិកអចិន្ត្រៃយ៍នៃការិយាល័យនយោបាយមជ្ឈិមបក្សកុម្មុយនិស្តចិន និងជាលេខាធិការនៃលេខាធិការដ្ឋានមជ្ឈិមបក្សកុម្មុយនិស្តចិន ជួបជាមួយតំណាងនៃប្រទេសផ្សេងៗដែលអញ្ជើញមកចូលរួមសិក្ខាសាលាស្ដីពីកិច្ចសហប្រតិបត្តិការប្រព័ន្ធផ្សព្វផ្សាយអាស៊ាន និងចិន ជប៉ុន កូរ៉េខាងត្បូង(១០+ ៣)លើកទី ៧ នៅក្រុងប៉េកាំង

中共中央政治局常委、中央书记处书记刘云山在北京会见来华参加第七届东盟与中日韩（10+3）媒体合作研讨会的外方代表　新华社 图



លោកបន្តថា នេះជាលើកទី ៧ ហើយ ដែលរៀបចំសិក្ខាសាលាស្ដីពីកិច្ចសហប្រតិបត្តិការប្រព័ន្ធផ្សព្វផ្សាយ ១០+៣ ដែលបានទទួលនូវសមិទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ និងបានបង្កើតជាវេទិកាផ្លាស់ប្ដូរប្រព័ន្ធផ្សព្វផ្សាយដែលមានលក្ខណៈតំណាងជាងគេក្នុងតំបន់ ។ អ្នកសារព័ត៌មាននៃបណ្ដាប្រទេសនានាមិនគ្រាន់តែត្រូវធ្វើជាសាក្សី និងអ្នកកត់ត្រានូវកិច្ចសហប្រតិបត្តិការ១០+៣ប៉ុណ្ណោះទេ ហើយក៏ត្រូវធ្វើជាអ្នកត្រួសត្រាយផ្លូវសម្រាប់តភ្ជាប់ដួងចិត្តរបស់ប្រជាជននៃប្រទេសផ្សេងៗផងដែរ ។ បណ្ដាញសារព័ត៌មានសំខាន់ៗ និងអ្នកប្រកបអាជីពសារព័ត៌មាននៃប្រទេសនានាត្រូវតែមានទស្សនៈទូទៅ និងទំនួលខុសត្រូវកម្រិតខ្ពស់ សកម្មផ្សព្វផ្សាយពីព័ត៌មានអំពីផលប្រយោជន៍រួម និងចំណុចយុទ្ធសាស្ត្រដែលប្រទាក់ក្រឡាគ្នា រាយការណ៍ពីការខ្វែងគំនិតនិងជម្លោះរវាងគ្នាដោយសត្យានុម័តនិងសមហេតុផល ដើម្បីកាត់បន្ថយនូវភាពភាន់ច្រឡំគ្នា និងពង្រីកចំណុចឯកភាពគ្នា ។

លោក ចាំង តាហ្វូន ចាងហ្វាងទីភ្នាក់ងារព័ត៌មានសេដ្ឋកិច្ចដេលីនៃប្រទេសកូរ៉េខាងត្បូង ឯកឧត្តម Soegeng Rahardjo ឯកអគ្គរដ្ឋទូតប្រទេសឥណ្ឌូនេស៊ីប្រចាំនៅប្រទេសចិន លោក Thongsavath Chansombath និពន្ធនាយកនៃកាសែតវៀងចន្ទន៍ថៃមប្រទេសឡាវ បានថ្លែងសុន្ទរកថាក្នុងពិធីសម្ពោធបើកលើកនេះ ។ ឯកឧត្តម យ៉ាង ជីជីន អនុរដ្ឋមន្ត្រីក្រសួងវប្បធម៌ចិន ឯកឧត្តម លីវ ជៀនឆាវ ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសចិន ឯកឧត្តម លី ជូន ឧបការីរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងគណបក្សចិន បានថ្លែងសុន្ទរកថាគន្លឹះ ។




សិក្ខាសាលាលើកនេះរៀបចំដោយទីភ្នាក់ងារកាសែតប្រជាជនដេលីរបស់ចិន និងមានការចូលរួមពីតំណាងបណ្ដាញសារព័ត៌មាន និងមន្ត្រីការទូត ៩៦ រូបនៃប្រទេសចំនួន ១៧ ដូចជាប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង បង់ក្លាដែស ឥណ្ឌា បាគីស្ថាន និងស្រីលង្កាជាដើម ។ តំណាងគ្រប់រូបបានពិគ្រោះពិភាក្សាគ្នាជុំវិញការរួមគ្នាធ្វើកិច្ចសហប្រតិបត្តិការ ស្វែងរកអនាគតភ្លឺស្វាងរបស់អាស៊ី បង្កើនការតភ្ជាប់គ្នា ជំរុញកិច្ចសហប្រតិបត្តិការផ្ដល់ផលប្រយោជន៍គ្នាទៅវិញទៅមក ពង្រីកការសហការគ្នាផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងជំរុញការតភ្ជាប់ដួងចិត្តនៃប្រជាជននៅបណ្ដាប្រទេសជាដើម និងបានឈានដល់មតិឯកភាពលើវិស័យជាច្រើន ។









# ឆ្នាំផ្លាស់ប្តូរវប្បធម៌ចិន-អាស៊ាន ២០១៤ ទទួលបានសមិទ្ធផលជាផ្លែផ្កាដ៏ច្រើន

## 2014中国—东盟文化交流年硕果累累

中国—东盟文化交流年于2014年12月16日闭幕。中国与东盟轮值主席国缅甸在内比都举行了隆重的闭幕式，向世界展示了中国与东盟国家人文交流与合作的丰硕成果。

សកម្មភាពឆ្នាំផ្លាស់ប្តូរវប្បធម៌ចិន-អាស៊ានបិទបញ្ចប់នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤ ។ ប្រទេសចិននិងប្រទេសមីយ៉ាន់ម៉ាដែលជាប្រទេសជាប្រធានផ្លាស់វេនអាស៊ានបានរៀបចំពិធីបិទបញ្ចប់យ៉ាងអធិកអធមនៅរដ្ឋធានីណៃពីដោប្រទេសមីយ៉ាន់ម៉ា និងបានបង្ហាញជូនដល់ពិភពលោកទាំងមូលនូវលទ្ធផលជាផ្លែផ្កានៃការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការវប្បធម៌រវាងប្រទេសចិននិងអាស៊ាន ។

ឆ្នាំផ្លាស់ប្តូរវប្បធម៌ចិន-អាស៊ានគឺជាឆ្នាំផ្លាស់ប្តូរវប្បធម៌ទីមួយដែលរៀបចំដោយភាគីចិននិងប្រទេសក្នុងតំបន់ ។ ចាប់ពីខែ មេសា ឆ្នាំ ២០១៤ រៀងមក ដើម្បីសម្រេចបាននូវការ“ចែករំលែកគ្នាអំពីវប្បធម៌ រួមគ្នាកសាងអនាគតភ្លឺស្វាង” ប្រទេសចិននិងអាស៊ានបានសហការគ្នាក្នុងការរៀបចំវេទិកាវប្បធម៌ សកម្មភាពសប្តាហ៍ភាពយន្ត ពិព័រណ៍អក្សរផ្ចង់និងគំនូរចិន ទិវាវប្បធម៌សមុទ្រខាងត្បូង និងការប្រកួតរថយន្តអន្តរជាតិរវាងប្រទេសចិននិងអាស៊ានជាដើម សរុបមានសកម្មភាពជាង ១០០ ដែលទាក់ទិនទៅនឹងការសម្តែងកម្មវិធីសិល្បៈ ការតាំងពិព័រណ៍ ការបណ្តុះបណ្តាលនិងផ្លាស់ប្តូរធនធានមនុស្ស ព័ត៌មាន ខ្សែភាពយន្ត ការបោះពុម្ពផ្សាយ កីឡា ទេសចរណ៍ សាសនា និងការផ្លាស់ប្តូរផ្នែកស្រទាប់យុវជន ។ល។ ភាគីទាំងពីរក៏បានរៀបចំសកម្មភាពវប្បធម៌ជាច្រើនទៀត ដោយគួបផ្សំជាមួយការស្ថាបនាផ្លូវសូត្រលើសមុទ្រប្រចាំសតវត្សរ៍ទី ២១ មជ្ឈមណ្ឌលវប្បធម៌ចិននៅឯនាយសមុទ្រ ការអបអរបុណ្យចូលឆ្នាំថ្មីចិន និងការអបអរខួបអនុស្សាវរីយ៍ទី ៤០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសចិននិងម៉ាឡេស៊ីជាដើម ។


របាំខ្នាតធំ“សុបិនផ្លូវសូត្រលើសមុទ្រ” ការសម្តែងកម្មវិធីសិល្បៈនៃសកម្មភាព“ឆ្នាំផ្លាស់ប្តូរវប្បធម៌ចិន-អាស៊ាន”
“中国—东盟文化交流年”文艺演出——大型原创舞剧《丝海梦寻》 cnsphoto


“រូបថៃជី” ការសម្តែងកម្មវិធីសិល្បៈខ្នាតធំនៃសកម្មភាព“ឆ្នាំផ្លាស់ប្តូរវប្បធម៌ចិន-អាស៊ាន”
中国—东盟文化交流年大型舞台秀《太极图》 cnsphoto

សកម្មភាពឆ្នាំផ្លាស់ប្តូរវប្បធម៌បានទទួលនូវការស្វាគមន៍ជាទូទៅពីសំណាក់ប្រជាជននៃបណ្តាប្រទេសនានា ។ សិល្បករទាំងឡាយបានថ្លែងថា សកម្មភាពនេះបានជំរុញទំនាក់ទំនងរវាងប្រជាជនចិននិងអាស៊ាន បង្កើនការស្វែងយល់ពីគ្នានិងចំណងមិត្តភាព ។ តំណាងនៃប្រទេសនានាជួបជុំជាមួយគ្នារំលឹកឡើងវិញនូវដំណើរវិវត្តន៍ដ៏ត្រចះត្រចង់នៃចំណងមិត្តភាពចិននិងអាស៊ាន ហើយនិងសម្លឹងមើលទៅអនាគតនៃទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្រ្តចិន-អាស៊ាន និងកិច្ចសហប្រតិបត្តិការក្នុងកម្រិតតំបន់ ។

ក្នុងនាមជាអរិយប្រទេសបុរាណមួយ ប្រទេសចិនមានបុរាណដ្ឋាន និងកេរដំណែលវប្បធម៌អរូបីដ៏សម្បូរបែប ។ នៅឆ្នាំ ២០១៤ ប្រទេសចិននិងអាស៊ានបានសហការគ្នាក្នុងការរៀបចំសកម្មភាពពិព័រណ៍ ដែលបានធ្វើឱ្យប្រជាជនអាស៊ានមានឱកាសខិតចូលទៅជិត និងស្វែងយល់អំពីកេរដំណែលវប្បធម៌ដ៏មានតម្លៃរបស់ចិន ។

នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ផ្ទះវប្បធម៌ចិនទី ១ នៅឯនាយសមុទ្រត្រូវបានបង្កើតឡើងនៅរាជធានីភ្នំពេញ ហើយឯកឧត្តម តុង វ៉ី អនុរដ្ឋមន្រ្តីក្រសួងវប្បធម៌ចិនបានអញ្ជើញចូលរួមពិធីបើកស្លាក ។ ផ្ទះវប្បធម៌នេះមានផ្ទៃក្រឡាសរុប ៥ ០០០ ម៉ែត្រការ៉េ ដែលមានសាលពិព័រណ៍ បន្ទប់រៀន ឆាកសម្តែង បន្ទប់អានសៀវភៅ និងកន្លែងសម្រាប់ផ្លាស់ប្តូរវប្បធម៌គ្រប់ប្រភេទ ។ នេះគឺជាស្នាដៃរបស់ក្រុមហ៊ុនស៊ីនជីយូណានគ្រុបក្នុងការជំរុញវប្បធម៌ចិនឱ្យដើរចេញទៅក្រៅ ក្រោមការគាំទ្រពីក្រសួងវប្បធម៌ចិន សាលាខេត្តយូណាននិងស្ថានទូតចិនប្រចាំនៅប្រទេសកម្ពុជា ។ លោកជំទាវ ពូ ជៀនគួ ឯកអគ្គរដ្ឋទូតចិនប្រចាំនៅប្រទេសកម្ពុជា បានវាយតម្លៃខ្ពស់ចំពោះផ្ទះវប្បធម៌ចិននេះ ហើយបានលើកឡើងថា សកម្មភាពដែលរៀបចំនៅទីនេះមុខជានឹងអាចក្លាយជាមធ្យោបាយដ៏សំខាន់មួយសម្រាប់ឱ្យប្រជាជនកម្ពុជាស្វែងយល់អំពីវប្បធម៌ចិនដ៏ល្អបវរជាមិនខាន ។

# មានមេត្រីភាពជាមួយប្រទេសជិតខាង រួមគ្នាស្វែងរកភាពរុងរឿងចុំចើ្រង

# ទិវាវប្បធម៌និងសិល្បៈប្រទេសតាមដងទន្លេឡានឆាង-មេគង្គ ២០១៤ រៀបចំដោយជោគជ័យ





កញ្ញា សា ទីងទីង អ្នកចម្រៀងល្បីឈ្មោះក្នុងប្រទេសចិន

中国著名歌手萨顶顶

## 睦邻友好　共创繁荣
## ——2014年澜沧江·湄公河流域国家文化艺术节成功举办

文、图/刘　蓉

“2014年澜沧江·湄公河流域国家文化艺术节”于2014年12月18日在西双版纳景洪市举行。此次文化艺术节以“睦邻友好，共创繁荣”为主题，来自中国、柬埔寨、泰国、老挝、缅甸、越南等国家的艺术家们通过精彩的演出，展示流域各国的特色文化艺术魅力，增进各国人民友谊。



“របាំកាយវិការដៃរយនាក់របស់ជនជាតិតៃ”

《傣族百人手势舞》

នាថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ “ទិវាវប្បធម៌និងសិល្បៈប្រទេសតាមដងទន្លេឡានឆាង-មេគង្គ ២០១៤”បានប្រារព្ធធ្វើឡើងនៅក្រុងជីងហុងមណ្ឌលស៊ីសាំងប៉ាន់ណា ។ ទិវាវប្បធម៌និងសិល្បៈលើកនេះរៀបចំក្រោមប្រធានបទ“មានមេត្រីភាពជាមួយប្រទេសជិតខាង រួមគ្នាស្វែងរកភាពរុងរឿងចុំចើ្រងហើយមានការចូលរួមនិងការសម្តែងដ៏អស្ចារ្យពីសំណាក់សិល្បករចិន កម្ពុជា ថៃ ឡាវ មីយ៉ាន់ម៉ា និងវៀតណាមជាដើម ដែលបានបង្ហាញឱ្យឃើញពីកម្លាំងទាក់ទាញនៃវប្បធម៌និងសិល្បៈប្រទេសនានា និងបានជួយបង្កើនចំណងមិត្តភាពរវាងប្រជាជននៃបណ្តាប្រទេសផ្សេងៗផងដែរ ។

លោក តាន ជីង អនុប្រធានសមាគមវប្បធម៌ចិន លោក ចាវ ជីន សមាជិកអចិន្ត្រៃយ៍និងជាប្រធានផ្នែកឃោសនាការនៃគណៈកម្មាធិការគណបក្សកុម្មុយនិស្តចិននៃខេត្តយូណាន លោក លួ ហុងជាំង ប្រធានមណ្ឌលស៊ីសាំងប៉ាន់ណា លោក ម៉ាន សួនវ៉ុឡី សមាជិកអចិន្ត្រៃយ៍មជ្ឈិមជាតិឡាវ លេខាបក្សនិងជាអភិបាលខេត្តបូឈាវប្រទេសឡាវ និងភ្ញៀវកិត្តិយសជាច្រើនរូបទៀត បានអញ្ជើញចូលរួមក្នុងពិធីបើកសម្ពោធ ។

សកម្មភាពទិវាវប្បធម៌និងសិល្បៈលើកនេះចែកជាបីផ្នែក គឺរាត្រីសមោសរបើកសម្ពោធក្រោមប្រធានបទ“ណាត់គ្នា ២០១៤” សមោសរតន្ត្រីព្រៃឈើជនជាតិ” និងរាត្រីសមោសរបិទបញ្ចប់ក្រោមប្រធានបទ“ស្រុកកំណើតដួងចិត្ត ការសម្តែងកម្មវិធីសិល្បៈនៅតាមតំបន់ជនបទស៊ីសាំងប៉ាន់ណា” ។ សិល្បករនៃបណ្តាប្រទេសតាមដងទន្លេឡានឆាង-មេគង្គបានសម្តែងកម្មវិធីសិល្បៈរៀងៗខ្លួន ក្នុងនោះសិល្បករខ្មែរបានរាំរបាំប្រពៃណីខ្មែរ ដែលបានបង្ហាញពីវប្បធម៌ជនជាតិខ្មែរដ៏មានលក្ខណៈពិសេស និងបានធ្វើឱ្យអ្នកទស្សនាចាប់អារម្មណ៍យ៉ាងខ្លាំង ។

វប្បធម៌និងសិល្បៈគឺជាស្ពានដៃរបស់មនុស្សជាតិ គោលបំណងនៃ“ទិវាវប្បធម៌និងសិល្បៈប្រទេសតាមដងទន្លេឡានឆាង-មេគង្គ”នេះ គឺសង្ឃឹមអាចឆ្លងតាមរយៈវប្បធម៌និងសិល្បៈ ជំរុញឱ្យបណ្តាប្រទេសនៅតាមដងទន្លេឡានឆាង-មេគង្គរួមគ្នាបង្ហាញពីវប្បធម៌និងសិល្បៈចម្រុះពណ៌ជូនដល់ពិភពលោកទាំងមូល ព្រមទាំងបង្ហាញពីប្រពៃណីស្រឡាញ់សន្តិភាព និងរាប់អានមានមេត្រីភាពជាមួយប្រទេសជិតខាងរបស់ប្រជាជននៃប្រទេសផ្សេងៗ ។ “ទិវាវប្បធម៌និងសិល្បៈប្រទេសតាមដងទន្លេឡានឆាង-មេគង្គ”មានឥទ្ធិពលកាន់តែខ្លាំងៗនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជានៅពិភពលោកទាំងមូលផងដែរ និងបានក្លាយជាម៉ាកល្បីមួយក្នុងមហាអនុតំបន់ទន្លេមេគង្គ ។

ទន្ទឹមនឹងការអនុវត្តយុទ្ធសាស្ត្រ“ខ្សែក្រវាត់មួយនិងផ្លូវមួយ” ការធ្វើកិច្ចសហប្រតិបត្តិការក្នុងមហាអនុតំបន់ទន្លេមេគង្គ និងការជំរុញការអភិវឌ្ឍន៍តំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន ប្រជាជននៃបណ្តាប្រទេសនានានៅក្នុងតំបន់មានទំនាក់ទំនងកាន់តែជិតស្និទ្ធ ការផ្លាស់ប្តូរផ្នែកវប្បធម៌និងសិល្បៈកាន់តែទូលំទូលាយ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្មកាន់តែស្អិតល្មួត ។ ការរាប់អានជាមួយប្រទេសជិតខាង ផ្តល់ផលប្រយោជន៍ទៅវិញទៅមក ឈ្នះ-ឈ្នះ និងរួមគ្នាស្វែងរកភាពរុងរឿងចុំចើ្រង បានក្លាយជាក្តីសង្ឃឹមរួមរបស់ប្រជាជននៃបណ្តាប្រទេសនានា ហើយតាមរយៈការផ្លាស់ប្តូរក្នុងឱកាសទិវាវប្បធម៌និងសិល្បៈលើកនេះ នឹងអាចជួយជំរុញថែមទៀតនូវការស្វែងរកភាពរុងរឿងចុំចើ្រង និងការអភិវឌ្ឍន៍នៃបណ្តាប្រទេសផ្សេងៗ ។



អ្នកដឹកនាំនិងភ្ញៀវកិត្តិយសដែលអញ្ជើញចូលរួមក្នុងពិធីសម្ពោធបើក

出席开幕式的领导及嘉宾

# ស្តារផ្លូវសូត្រនៅភាគខាងត្បូងឱ្យមានភាពរុងរឿងឡើងវិញ ផ្តល់កម្លាំងជំរុញសម្រាប់ការអភិវឌ្ឍន៍យូណានដោយលោតផ្លោះ



លោក ស៊ីន មីន ជំនួយការនៃប្រធានអង្គភាពកាសែតតាកុង ហុងកុង និងជាប្រធានសាខាប្រចាំខេត្តយូណាននៃកាសែតតាកុង ហុងកុង ថ្លែងសុន្ទរកថា

香港大公报社长助理、云南分社社长辛民致辞



ឯកឧត្តមឧត្តមសេនីយឯក ឆាទី ផាតាណាបាន អនុប្រធានមូលនិធិអភិវឌ្ឍន៍ជនបទនិងទីក្រុងប្រទេសថៃ ថ្លែងសុន្ទរកថា

泰国城乡发展基金会副主席查迪・帕塔纳攀上将致辞

## 复兴南方丝绸之路　助力云南跨越发展

文、图/沈　燕

由香港大公报、云南省东南亚南亚经贸合作发展联合会联合主办，以“互联互通互信——复兴南方丝绸之路的机遇与挑战”为主题的“2014年复兴南方丝绸之路国际研讨会”于2014年12月26日在昆明举行。

“សិក្ខាសាលាអន្តរជាតិស្តីពីការស្តារផ្លូវសូត្រភាគខាងត្បូងឱ្យមានភាពរុងរឿងថ្មីថ្មោង ២០១៤” ដែលរៀបចំដោយកាសែតតាកុង ហុងកុង និងសមាគមអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្មអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូងខេត្តយូណាន បានប្រារព្ធធ្វើឡើងនៅក្រុងគុនមីងនាថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ក្រោមប្រធានបទ“ការតភ្ជាប់គ្នានិងការកសាងទំនុកចិត្តលើគ្នា កាលានុវត្តភាពនិងបញ្ហាប្រឈមនៃការស្តារផ្លូវសូត្រភាគខាងត្បូងឱ្យមានភាពរុងរឿងឡើងវិញ” ។

លោកស្រី វ៉ាង អ៊ីម៉េង ប្រធានសមាគមអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្មអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូងខេត្តយូណាន លោក ស៊ីន មីន ប្រធានសាខាប្រចាំខេត្តយូណាននៃកាសែតតាកុង ហុងកុង ឯកឧត្តម U Aung Kyaw Oo អគ្គកុងស៊ុលប្រទេសមីយ៉ាន់ម៉ាប្រចាំនៅក្រុងគុនមីង ឯកឧត្តមSuchart Liengsaengthong អគ្គកុងស៊ុលប្រទេសថៃប្រចាំនៅក្រុងគុនមីង លោកជំទាវ SHAHNAZ GAZI អគ្គកុងស៊ុលប្រទេសបង់ក្លាដែសប្រចាំនៅក្រុងគុនមីង ឯកឧត្តមឧត្តមសេនីយឯក ឆាទី ផាតាណាបាន អនុប្រធានមូលនិធិអភិវឌ្ឍន៍ជនបទនិងទីក្រុងប្រទេសថៃ លោកស្រី សៀ លីណា ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនទូរទស្សន៍MV ប្រទេសឡាវ ឯកឧត្តម លីន វិនសៀន សកលវិទ្យាធិការនៃសកលវិទ្យាល័យយូណាន ព្រមទាំងភ្ញៀវកិត្តិយស និងអ្នកជំនាញការជាតិនិងអន្តរជាតិជាច្រើនរូបទៀត បានជួបជុំគ្នា បកស្រាយនិងពិគ្រោះពិភាក្សាគ្នាអំពីការស្តារផ្លូវសូត្រភាគខាងត្បូងឱ្យមានភាពរុងរឿងឡើងវិញ ដើម្បីផ្តល់ជាអនុសាសន៍ដ៏មានតម្លៃក្នុងការជំរុញខេត្តយូណានឱ្យចូលរួមកាន់តែស៊ីជម្រៅក្នុងការអនុវត្តយុទ្ធសាស្ត្រ “ខ្សែក្រវាត់មួយនិងផ្លូវមួយ” ។

ក្នុងកិច្ចប្រជុំលើកនេះ លោកស្រី វ៉ាង អ៊ីម៉េង លោក ស៊ីន មីន និងតំណាងនៃប្រទេសនានាបានថ្លែងសុន្ទរកថាគន្លឹះដោយបានគូសបញ្ជាក់ថា “ខ្សែក្រវាត់មួយនិងផ្លូវមួយ”មិនត្រឹមតែជាយុទ្ធសាស្ត្ររបស់ចិនទេ ហើយក៏ជាយុទ្ធសាស្ត្ររបស់ពិភពលោកផងដែរ ។ មិនតែប៉ុណ្ណោះ វាមិនត្រឹមតែជាយុទ្ធសាស្ត្រពេលបច្ចុប្បន្នឡើយ ហើយក៏ជាយុទ្ធសាស្ត្រនាពេលអនាគតផងដែរ ។

លោក លីវ ជីនសៀន ប្រធានវិទ្យាស្ថានសិក្សាស្រាវជ្រាវអំពីប្រព័ន្ធគមនាគមន៍និងចរាចរណ៍ទំនិញ PAN -អាស៊ីនៅក្រុងគុនមីង បានមានប្រសាសន៍ថា គម្រោងសិក្សាស្រាវជ្រាវអំពីការជំរុញការកសាងរបៀងសេដ្ឋកិច្ចបង់ក្លាដែស ចិន ឥណ្ឌា និងមីយ៉ាន់ម៉ា ដែលជាគម្រោងសិក្សាស្រាវជ្រាវសម្រាប់ផ្តល់ជារបាយការណ៍ពិគ្រោះយោបល់ប្រចាំឆ្នាំ ២០១៤ របស់សាលាខេត្តយូណាន ត្រូវបានបញ្ចប់ជាស្ថាពរ ក្នុងនោះបានលើកមតិអំពីការគូរប្លង់ទូទៅចំពោះការកសាងច្រកដឹកជញ្ជូនតាមរបៀងសេដ្ឋកិច្ចបង់ក្លាដែស ចិន ឥណ្ឌា និងមីយ៉ាន់ម៉ា និងបានលើកឡើងឱ្យបង្កើតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍របៀងសេដ្ឋកិច្ចដែលមានផ្លូវផ្តេក ៣ ខ្សែ និងផ្លូវបញ្ឈរ ៥ ខ្សែដោយមានច្រកដឹកជញ្ជូនធំ ៨ ខ្សែ និងចំណុចប្រសព្វចម្រុះ ៣៣ កន្លែង ដើម្បីសម្រេចនូវការតភ្ជាប់គ្នារវាងឧបទ្វីបអាស៊ីខាងត្បូង ឈូងសមុទ្របង់ក្លាដែស ឧបទ្វីបឥណ្ឌូចិន និងភាគនិរតីនៃប្រទេសចិន ។ លោក លីវ ជីនសៀន បានថ្លែងថា ការកសាងផ្លូវសូត្រភាគខាងត្បូងនឹងអាចនាំមកនូវកាលានុវត្តភាពអភិវឌ្ឍន៍ថ្មីដល់សហគ្រាសដឹកជញ្ជូននិងចរាចរណ៍ទំនិញ ។

ឯកឧត្តម លីន វិនសៀន សកលវិទ្យាធិការនៃសកលវិទ្យាល័យយូណាន បានបញ្ជាក់ថា របៀងសេដ្ឋកិច្ចធំតាមផ្លូវសូត្រភាគខាងត្បូងមានមូលដ្ឋានប្រវត្តិសាស្ត្រដ៏រឹងមាំ ការកសាងរបៀងសេដ្ឋកិច្ចធំតាមផ្លូវសូត្រភាគខាងត្បូងមួយពីស៊ីអាន-ឈឹងទូ-គុនមីង រហូតដល់តំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង នឹងអាចតភ្ជាប់ឱ្យស្អិតល្មួតនូវខ្សែក្រវាត់មួយនិងផ្លូវមួយ តភ្ជាប់ឱ្យកាន់តែស៊ីជម្រៅនូវខេត្តយូណាននិងអាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង សម្រេចការអភិវឌ្ឍន៍ដោយឈ្នះ-ឈ្នះ និងផ្តល់ជាកម្លាំងជំរុញសម្រាប់ការអភិវឌ្ឍន៍យូណានដោយលោតផ្លោះ ។




ទិដ្ឋភាពនៃសិក្ខាសាលា

研讨会现场

# ឈរលើមូលដ្ឋានប៉ាវសាន បើកទូលាយចំពោះភាគខាងលិចខេត្តយូណាន ដើរឆ្ពោះទៅកាន់តំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង បុរីពាណិជ្ជកម្មអន្តរជាតិអ៊ីអ៊ូ ម៉ាវហួ ក្រុងប៉ាវសានចាប់ដំណើរការធ្វើអាជីវកម្ម



ពិធីចាប់ដំណើរការធ្វើអាជីវកម្មនៃបុរីពាណិជ្ជកម្មអន្តរជាតិអ៊ីអ៊ូ ម៉ាវហួ ក្រុងប៉ាវសាន
保山茂华义乌国际商贸城开业启动仪式

## 立足保山　面向滇西　走向东南亚南亚

### ——保山茂华义乌国际商贸城开业

文、图/刘　蓉

地处云南西部的保山，是中国通往南亚的最前沿地带和最佳陆路通道，是建设中国欧亚大陆桥的必经之地。近年来，保山市积极融入国家西部开发战略、云南省“一带一路”建设规划和孟中印缅经济走廊建设，发挥云南在国家向西南开放战略中的重要作用。



ក្រុងប៉ាវសានដែលស្ថិតនៅភាគខាងលិចខេត្តយូណាន គឺជាច្រកដីគោកល្អបំផុតសម្រាប់ធ្វើដំណើរទៅកាន់តំបន់អាស៊ីខាងត្បូង និងជាទីឆ្លងកាត់ដ៏ចាំបាច់នៃស្ពានដីគោកអាស៊ី-អឺរ៉ុប ។ ប៉ុន្មានឆ្នាំកន្លងទៅនេះ ក្រុងប៉ាវសានសកម្មចូលរួមការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ភាគខាងលិចប្រទេសចិន ផែនការកសាង“ខ្សែក្រវាត់មួយនិងផ្លូវមួយ”ខេត្តយូណាន និងការកសាងរបៀងសេដ្ឋកិច្ចបង់ក្លាដែស ចិន ឥណ្ឌា និងមីយ៉ាន់ម៉ា ព្រមនិងធ្វើឱ្យខេត្តយូណានដើរតួនាទីសំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្របើកទូលាយចំពោះភាគនិរតីរបស់ចិន ។

នាថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៤ បុរីពាណិជ្ជកម្មអន្តរជាតិអ៊ីអ៊ូ ម៉ាវហួ ក្រុងប៉ាវសាន បានបើកធ្វើអាជីវកម្មជាផ្លូវការ ។ កុងស៊ុលនៃប្រទេសឥណ្ឌា ថៃ មីយ៉ាន់ម៉ា និងបង់ក្លាដែសប្រចាំនៅប្រទេសចិន ប្រធានកិត្តិយសនៃសមាគមពាណិជ្ជកម្មចិន តំណាងនៃស្ថាប័ននិងសហគ្រាសផ្សេងៗនៅខេត្តជឺជាំងនិងយូណាន តំណាងអាណិកជនចិននិងពាណិជ្ជករចិននៅប្រទេសអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង និងភ្ញៀវកិត្តិយសជាច្រើនរូបទៀតបានអញ្ជើញចូលរួមក្នុងសកម្មភាពលើកនេះ ។

បុរីពាណិជ្ជកម្មអន្តរជាតិអ៊ីអ៊ូ ម៉ាវហួ ក្រុងប៉ាវសានជាគម្រោងទាក់ទាញអ្នកវិនិយោគសំខាន់ដែលរៀបចំដោយគណៈកម្មាធិការគណបក្សកុម្មុយនិស្តចិនក្រុងប៉ាវសាននិងខណ្ឌឡុងយ៉ាង សម្រាប់ជំរុញកិច្ចសហប្រតិបត្តិការ និងបំពេញបន្ថែមគ្នារវាងភាគខាងលិច និងតំបន់ឆ្នេរសមុទ្រខាងកើតរបស់ប្រទេសចិន ហើយក៏ជាគម្រោងសំខាន់មួយក្នុងចំណោមកម្មវិធី “មួយរយចំនួនបី” របស់ខេត្តយូណានផងដែរ ។ តាមផែនការវិនិយោគ គម្រោងនេះមានផ្ទៃក្រឡាជាង ៩០ ហិកតា និងមានទុនវិនិយោគសរុប ១០ ០០០ លានយាន់ប្រាក់ចិន បុរីនេះមានមុខងារធ្វើអាជីវកម្មលក់ដុំនិងលក់រាយ ព្រមនិងមានផ្សារលក់ដូរ ផ្លូវពាណិជ្ជកម្ម ភោជនីយដ្ឋាន ហិរញ្ញវត្ថុ កន្លែងលេងកម្សាន្ត និងផ្ទះស្នាក់នៅកម្រិតខ្ពស់ជាដើម ។ ការធ្វើអាជីវកម្មមានពាក់ព័ន្ធនឹងសម្លៀកបំពាក់ក្មេង ស្បែកជើង កាបូប គ្រឿងសង្ហារិម ក្រណាត់ សម្ភារៈសិក្សា និងកីឡា គ្រឿងសំអាង វត្ថុសិប្បកម្ម គ្រឿងតុបតែង គ្រឿងបន្លាស់ គ្រឿងចក្រ កង់អាគុយ ម៉ូតូ ថ្នាំចិនសែ ស្លឹកតែ កាហ្វេ ម្ហូបអាហារ ព្រមនិងមានភោជនីយដ្ឋាន ការិយាល័យកិច្ចការពាណិជ្ជកម្ម និងពាណិជ្ជកម្មអេឡិចត្រូនិចជាដើម ។ ក្នុងប្រទេសចិន បុរីពាណិជ្ជកម្មអន្តរជាតិនេះសំខាន់ គឺផ្តល់សេវាកម្មដល់ក្រុងនានានៅភាគខាងលិចខេត្តយូណានដូចជាប៉ាវសាន តាលីទួជាំង តឺហុង និងលីនឆាងជាដើម ហើយឈរលើទីផ្សារក្នុងស្រុកដើម្បីតភ្ជាប់ភាគខាងលិចខេត្តយូណានជាមួយទីផ្សារអាស៊ីខាងត្បូងនិងខេត្តក្រុងផ្សេងទៀតនៃប្រទេសចិន ។ ចំណែកនៅក្រៅប្រទេសចិនបុរីពាណិជ្ជកម្មអន្តរជាតិនេះសំខាន់ គឺដើរតួនាទីសម្រាប់តភ្ជាប់ជាមួយផ្សារឥណ្ឌា បង់ក្លាដែស មីយ៉ាន់ម៉ា និងប្រទេសអាស៊ីខាងត្បូងនិងអាស៊ី អាគ្នេយ៍ ត្រួសត្រាយឱ្យបានកាន់តែស្រួលនូវរបៀងសេដ្ឋកិច្ច បង់ក្លាដែស ចិន ឥណ្ឌា និងមីយ៉ាន់ម៉ា ហើយធ្វើឱ្យវាក្លាយទៅជាវេទិកាពាណិជ្ជកម្មដ៏សំខាន់សម្រាប់តភ្ជាប់តំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ។

ក្នុងដំណើរសាងសង់បុរីពាណិជ្ជកម្មអន្តរជាតិអ៊ីអ៊ូម៉ាវហួ ក្រុងប៉ាវសាន ភាគីអភិវឌ្ឍន៍បានសកម្មចាត់វិធានការមួយចំនួនធំដើម្បីទាក់ទាញអ្នកវិនិយោគជាតិនិងអន្តរជាតិ និងបានទទួលជោគជ័យក្នុងការទាក់ទាញពាណិជ្ជករធំៗដែលមកពីខេត្តជឺជាំង ហុកគៀន ក្វាងតុង ហ៊ូណាន និងស៊ីឈួនជាដើម ឱ្យចូលធ្វើអាជីវកម្មនៅក្នុងបុរីពាណិជ្ជកម្មអន្តរជាតិនេះ ។ ជាពិសេស បានទាក់ទាញសហគ្រាសកែច្នៃជាច្រើនឱ្យមកធ្វើវិនិយោគនៅក្រុងប៉ាវសាន ដោយមានសហគ្រាសជាង ៥០ មកវិនិយោគនៅប៉ាវសាន និងបានបង្កើតតំបន់វាយនភ័ណ្ឌធុនស្រាលក្នុងសួនឧស្សាហកម្មនិងពាណិជ្ជកម្មប៉ាវសាន ។ ក្រៅពីនេះ បុរីពាណិជ្ជកម្មអន្តរជាតិនេះនៅបានទាក់ទាញពាណិជ្ជករជាអាណិកជនចិនជាច្រើននៅប្រទេសមីយ៉ាន់ម៉ា ហើយមានផែនការនឹងបង្កើតទីផ្សារនៅប្រទេសមីយ៉ាន់ម៉ា ដើម្បីជំរុញផលិតផលចិនឱ្យចូលទីផ្សារអាស៊ីខាងត្បូងនិងអាស៊ីខាងកើតតាមរយៈប្រទេសមីយ៉ាន់ម៉ា ។



បុរីពាណិជ្ជកម្មអន្តរជាតិអ៊ីអ៊ូ ម៉ាវហួ ក្រុងប៉ាវសាន
保山茂华义乌国际商贸城

# សួនឧស្សាហកម្មនិងពាណិជ្ជកម្មប៉ាវសាន រៀបចំសិក្ខាសាលាស្តីពីការទាក់ទាញអ្នកវិនិយោគ



ទិដ្ឋភាពនៃសិក្ខាសាលា

推介会现场

## 保山工贸园区举行招商引资推介会

文、图/刘　蓉

2014年12月28日，保山工贸园区举行招商引资推介会，介绍保山市投资环境及重点招商引资项目。缅甸曼德勒华商代表团、缅甸密支那华商代表团、浙江考察团等共50多名企业家代表参加会议。

នាថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៤ សួនឧស្សាហកម្មនិងពាណិជ្ជកម្មប៉ាវសានបានរៀបចំសិក្ខាសាលាស្តីពីការទាក់ទាញអ្នកវិនិយោគ ដើម្បីផ្សព្វផ្សាយអំពីបរិយាកាសវិនិយោគ និងគម្រោងវិនិយោគសំខាន់ៗ ។ ក្រុមពាណិជ្ជករជាអាណិកជនចិនដែលមកពីម៉ាន់ដាឡេនិងមីតគីណានៃប្រទេសមីយ៉ាន់ម៉ា ក្រុមពាណិជ្ជករដែលមកពីខេត្តជឺជាំងប្រទេសចិន និងតំណាងសហគ្រាសផ្សេងៗ សរុបជាង ៥០ សហគ្រាសបានចូលរួមក្នុងសិក្ខាសាលាលើកនេះ ។

មុនកិច្ចចាប់ផ្តើម លោកស្រី ឌី ម៉ី អភិបាលរង និងជាលេខាបក្សខណ្ឌឡុងយ៉ាង និងសហគ្រិនជាង ៥០ រូប បានទៅទស្សនានៅសួនឧស្សាហកម្មនិងពាណិជ្ជកម្ម ហើយបានឧទ្ទេសនាមអំពីផែនការនិងទស្សនៈស្តីពីការអភិវឌ្ឍន៍សួនឧស្សាហកម្មនិងពាណិជ្ជកម្ម ។ សហគ្រិនទាំងឡាយក៏បានទៅទស្សនានៅរោងជាងវាយនភ័ណ្ឌធុនស្រាលដែរ ។

ក្នុងសិក្ខាសាលាលើកនេះ លោក ចាវ ប៉ាវគុយ សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សកុម្មុយនិស្តចិននៅខណ្ឌឡុងយ៉ាង និងជាអភិបាលរងខណ្ឌឡុងយ៉ាង បានឧទ្ទេសនាមថា សួនឧស្សាហកម្មនិងពាណិជ្ជកម្មប៉ាវសានគឺជាសួនឧស្សាហកម្មថ្នាក់ខេត្តមួយរបស់យូណាន និងជាសួនឧស្សាហកម្មដែលកសាងឡើងតាមគោលដៅយុទ្ធសាស្ត្រ "កសាងខេត្តយូណានដែលមានសេដ្ឋកិច្ចបៃតងដ៏ខ្លាំងក្លា និងវប្បធម៌ជនជាតិសម្បូរបែប ព្រមទាំងបើកទូលាយចំពោះភាគនិរតីចិន" និងអាស្រ័យលើរបៀងសេដ្ឋកិច្ចបង់ក្លាដែស-ចិន-ឥណ្ឌា-មីយ៉ាន់ម៉ា របៀងសេដ្ឋកិច្ចគុនមីង-ប៉ាវសាន-ជីវភីវនៃមីយ៉ាន់ម៉ា និងរបៀងសេដ្ឋកិច្ចគុនមីង-ប៉ាវសាន-ការគីតានៃឥណ្ឌា ។ សួនឧស្សាហកម្មនិងពាណិជ្ជកម្មនេះមានផ្ទៃក្រឡា ៥០ គីឡូម៉ែត្រការ៉េ ដោយបានច្របាច់បញ្ចូលនូវទស្សនៈអភិវឌ្ឍន៍ទំនើប និងយុទ្ធសាស្ត្រគួរបួង់សមហេតុផលព្រមនិងបានលើកឡើងនូវផែនការអភិវឌ្ឍន៍ដែលមានខ្សែស្នូលមួយខ្សែ ក្រុមធំចំនួន ៦ និងបង្កើតជាបណ្តាញប្រព័ន្ធអេកូឡូស៊ី ដោយបានផ្តោតសំខាន់ទៅលើឧស្សាហកម្មសំខាន់ ៤ គឺវាយនភ័ណ្ឌធុនស្រាល ការកែច្នៃឈើ ផលិតកម្មសម្ភារៈសំណង់និងព័ត៌មានអេឡិចត្រូនិច ។ អាស្រ័យលើប្រជាជនចំនួន ២ ២០០ លាននាក់នៅប្រទេសអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង និងប្រជាជន ១ ៣០០ លាននាក់នៅក្នុងប្រទេសចិន សួនឧស្សាហកម្មនិងពាណិជ្ជកម្មប៉ាវសានខិតខំទាក់ទាញឱ្យសហគ្រាសនៅភាគខាងកើតនៃប្រទេសចិនមកវិនិយោគនៅទីនេះ សម្រេចនូវការប្រែក្លាយពី "សួនឧស្សាហកម្មប្រពៃណី" ទៅជា "បុរីឧស្សាហកម្មនិងពាណិជ្ជកម្មថ្មី" ។ បច្ចុប្បន្ន មានសហគ្រាសចំនួន ៨២ បានបណ្តាក់ទុនវិនិយោគក្នុងសួនឧស្សាហកម្មនិងពាណិជ្ជកម្មនេះ ក្នុងចំណោមនោះ តំបន់វាយនភ័ណ្ឌធុនស្រាលបានមានទ្រង់ទ្រាយធំគួរសម ហើយត្រូវបានរដ្ឋាភិបាលចិនកំណត់ជាតំបន់គំរូសម្រាប់ការផ្ទេរឧស្សាហកម្មវាយនភ័ណ្ឌ និងត្រូវបានគេជ្រើសរើសជាមូលដ្ឋានគំរូនៃការធ្វើអាជីវកម្មសហគ្រាសធុនតូចក្រុមទី ១ ។ លោក ចាវ ប៉ាវគុយ សង្ឃឹមថា តាមរយៈសិក្ខាសាលាស្តីពីការទាក់ទាញអ្នកវិនិយោគលើកនេះ នឹងអាចទាក់ទាញសហគ្រិនកាន់តែច្រើនមកធ្វើការវិនិយោគនៅសួនឧស្សាហកម្មនិងពាណិជ្ជកម្មប៉ាវសាននេះ ។




មូលដ្ឋានផលិតកម្មក្នុងសួនឧស្សាហកម្មនិងពាណិជ្ជកម្មប៉ាវសាន

保山工贸园区工厂生产基地

# ជំរុញការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម ជួយស្រុកជនជាតិតៃឱ្យសម្រេចសុបិនចិន

## 助推贸易发展　圆傣乡中国梦

文、图/沈　燕　刘　蓉

为弘扬澜沧江·湄公河流域各国优秀民族文化，助推贸易交流与发展，积极构建睦邻友好、和谐共赢的战略合作关系，进一步加强中国与大湄公河次区域流域国家的文化与贸易交流，西双版纳于2014年12月18日至20日在景洪市举办了“2014年澜沧江·湄公河流域国家文化艺术节”。在此期间，同时举办了“2014年澜沧江·湄公河流域国家文化艺术节商品展销会”。

ដើម្បីផ្សព្វផ្សាយវប្បធម៌ដ៏វិសេសវិសាលរបស់ប្រជាជននៃបណ្តាប្រទេសនៅតាមដងទន្លេឡានឆាង-មេគង្គ ជំរុញការផ្លាស់ប្តូរនិងការអភិវឌ្ឍន៍ សកម្មបង្កើតកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រដែលគោរពរាប់អានជាមួយប្រទេសជិតខាងមានភាពចុះសម្រុងគ្នានិងឈ្នះ-ឈ្នះ បង្កើនការផ្លាស់ប្តូរវប្បធម៌និងការធ្វើពាណិជ្ជកម្មរវាងប្រទេសចិននិងប្រទេសមហាអនុតំបន់ទន្លេមេគង្គ មណ្ឌលស៊ីសាំងប៉ាន់ណាបានរៀបចំសកម្មភាព“ទិវាវប្បធម៌និងសិល្បៈប្រទេសតាមដងទន្លេឡានឆាង-មេគង្គ ២០១៤ ”នៅក្រុងជីងហុងកាលពីថ្ងៃទី ១៨ ដល់ទី ២០ ខែធ្នូ ឆ្នាំ ២០១៤ ។ ព្រមពេលជាមួយនោះ ក៏បានរៀបចំ“ពិព័រណ៍ពាណិជ្ជកម្មទិវាវប្បធម៌និងសិល្បៈប្រទេសតាមដងទន្លេឡានឆាង-មេគង្គ ២០១៤” ។

តាមបុគ្គលិកការងារនៃភាគីរៀបចំពិព័រណ៍លើកនេះបានឱ្យដឹងថា ពិព័រណ៍លើកនេះមានការចូលរួមពីពាណិជ្ជករបរទេសជាច្រើនដែលមកពីប្រទេសវៀតណាម មីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងប៉ាគីស្ថានជាដើម ព្រមនិងពាណិជ្ជករចិនមួយចំនួនដែលមកពីបណ្តាខេត្តផ្សេងៗ និងក្រុងនានាក្នុងខេត្តយូណាន ។ ពិព័រណ៍លើកនេះមិនគ្រាន់តែបានដាក់តាំង




ពិព័រណ៍ពាណិជ្ជកម្មក្នុងសកម្មភាព“ទិវាវប្បធម៌និងសិល្បៈប្រទេសតាមដងទន្លេឡានឆាង-មេគង្គ ២០១៤”

2014年澜沧江·湄公河流域国家文化艺术节商品展销




ការកែច្នៃវត្ថុសិប្បកម្មធ្វើអំពីឈើ

木制手工艺品现场加工



អ្នកក្រុងកំពុងជ្រើសរើសវត្ថុសិប្បកម្មក្នុងពិព័រណ៍ពាណិជ្ជកម្ម

市民在展销会上挑选手工艺品

នូវផលិតផលដែលមានលក្ខណៈពិសេសបរទេសប៉ុណ្ណោះទេ ហើយក៏បានប្រមូលនូវផលិតផលដែលមានលក្ខណៈពិសេសតាមតំបន់ក្នុងប្រទេសចិនផងដែរ ។ ពាណិជ្ជករដែលមកពីប្រទេសអាស៊ីអាគ្នេយ៍បាននាំមកនូវផលិតផលអាស៊ីអាគ្នេយ៍គ្រប់ប្រភេទ ដែលមានលក្ខណៈពិសេសជូនដល់ប្រជាជនស៊ីសាំងប៉ាន់ណា បានបំពេញតម្រូវការរបស់ប្រជាជននៅស៊ីសាំងប៉ាន់ណាចំពោះផលិតផលពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ ម្យ៉ាងទៀត ពិព័រណ៍លើកនេះក៏បានផ្តល់ឱកាសនិងវេទិកាពាណិជ្ជកម្មដ៏កម្រសំរាប់ពាណិជ្ជករទាំងឡាយធ្វើការផ្លាស់ប្តូរគ្នា ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា ជារៀងរាល់ឆ្នាំស៊ីសាំងប៉ាន់ណានឹងរៀបចំពិព័រណ៍បែបនេះជាច្រើនលើកច្រើនសា ហើយតាមរយៈការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មទាំងនេះ បានធ្វើឱ្យប្រជាជនអាស៊ីអាគ្នេយ៍កាន់តែស្វែងយល់អំពីស៊ីសាំងប៉ាន់ណា និងទទួលបានផលចំណេញជាក់ស្តែង ព្រមពេលជាមួយនោះក៏អាចជួយជំរុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងពាណិជ្ជកម្មរបស់ស៊ីសាំងប៉ាន់ណា ព្រមនិងធ្វើឱ្យប្រជាជននៅស្រុកជនជាតិតៃនេះទទួលបានផលប្រយោជន៍ជាក់ស្តែងពីការបើកចំហតាមតំបន់ព្រំដែននោះដែរ ។

ក្រោមបរិបទនៃការអនុវត្តយុទ្ធសាស្ត្រ“ខ្សែក្រវាត់មួយនិងផ្លូវមួយ” និងការពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេស GMS ទាំង ៦ មណ្ឌលស៊ីសាំងប៉ាន់ណាបានក្តាប់ជាប់នូវឧត្តមភាពទីតាំងភូមិសាស្ត្រសម្រាប់ធ្វើការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មជាមួយប្រទេសមហាអនុតំបន់ទន្លេមេគង្គ ប្រែក្លាយទៅជាច្រកបើកទូលាយ និងតំបន់ស្នូលនៃការអភិវឌ្ឍន៍តំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន ការធ្វើកិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គនិងការបើកចំហចំពោះអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង ដោយបានសម្រេចការធ្វើដំណើរពីស៊ីសាំងប៉ាន់ណាទៅប្រទេសឡាវ មីយ៉ាន់ម៉ា និងថៃដោយផ្ទាល់តាមរយៈផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ។ បច្ចុប្បន្នមណ្ឌលស៊ីសាំងប៉ាន់ណាបានបង្កើតប្រព័ន្ធគមនាគមន៍ ចម្រុះនិងរចនាសម្ព័ន្ធបើកទូលាយជាពហុវិស័យដែលបានបង្កបង្កើតលក្ខណៈសម្បត្តិសម្រាប់ការធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្មរវាងស៊ីសាំងប៉ាន់ណានិងប្រទេសអាស៊ីអាគ្នេយ៍ ហើយបានផ្តល់កម្លាំងចលករសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងការសម្រេចវិបុលភាពរបស់ស៊ីសាំងប៉ាន់ណា ដើម្បីជួយប្រជាជននៅទីនេះឱ្យសម្រេចនូវសុបិនចិន និងសុបិនដែលមានការរស់នៅប្រកបដោយភាពសុខសាន្តនិងធូរធារ ។



ចម្លាក់ឈើវៀតណាម

越南木雕

文、图/云南建工集团

# ក្រុមហ៊ុនស្ថាបនកម្មយូណាន បើកក្តោងឆ្ពោះទៅកាន់អនាគត



ថ្នាក់ដឹកនាំនៃក្រុមហ៊ុនស្ថាបនកម្មយូណានគ្រុប
云南建工集团领导班子

## 云南建工：扬帆远航

2014年，在云南建工集团有限公司（以下简称云南建工）的历史上是不平凡的一年，是值得铭记的一年，是走向辉煌的一年。

这一年，云南建工破解难题，挖掘新的市场经济增长点，进行发展质量的转型，发展效益的转型，发展稳健的转型，揭开了新的一页。

ឆ្នាំ ២០១៤ គឺជាឆ្នាំដែលពោរពេញទៅដោយស្នាដៃល្អៗរបស់ក្រុមហ៊ុនស្ថាបនកម្មយូណាន និងជាឆ្នាំដែលក្រុមហ៊ុនស្ថាបនកម្មយូណានបោះជំហានទៅភាពត្រចះត្រចង់និងមិនអាចបំភ្លេចបានក្នុងប្រវត្តិសាស្ត្រ ។

នៅឆ្នាំ ២០១៤ ក្រុមហ៊ុនស្ថាបនកម្មយូណានបានពុះពារគ្រប់ឧបសគ្គ ស្វែងរកចំណុចកំណើនសេដ្ឋកិច្ចទីផ្សារថ្មី ផ្លាស់ទម្រង់នៃគុណភាពអភិវឌ្ឍន៍ ប្រសិទ្ធផលអភិវឌ្ឍន៍ និងស្ថិរភាពនៃការអភិវឌ្ឍន៍ ដោយបានបើកទំព័រថ្មីនៃប្រវត្តិសាស្ត្រ ។

ទីផ្សារតែងតែផ្តល់អាទិភាពដល់សហគ្រាសដែលមានយុទ្ធសាស្ត្រច្បាស់លាស់ ការរំដោះស្មារតី និងក្តីក្លាហានក្នុងការធ្វើអាជីវកម្ម ។ លោក អ៊ឹន វិនសិន លេខាធិការគណបក្សនិងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនស្ថាបនកម្មយូណាន លោក លីវ យ៉ុង អនុលេខាធិការគណបក្សនិងជាអគ្គនាយកនៃក្រុមហ៊ុនស្ថាបនកម្មយូណាននិងថ្នាក់ដឹកនាំនៃ ក្រុមហ៊ុនបានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការគូរប្លង់ជាយុទ្ធសាស្ត្រទូទៅនៃការអភិវឌ្ឍន៍ក្រុមហ៊ុន ។ បុគ្គលិកការងារគ្រប់រូបរបស់ក្រុមហ៊ុនមានជំនឿចិត្តយ៉ាងមុតមាំថាមានតែប្រកបដោយក្តីក្លាហានក្នុងការប្រឈមមុខជាមួយការប្រកួតប្រជែងធ្វើការច្នៃប្រឌិតឥតឈប់នោះទេ ទើបអាចដំណើ្តមបានអាទិភាពក្នុងការប្រកួតប្រជែងដ៏ខ្លាំងក្លានោះបាន ។ ក្នុងដំណើរអភិវឌ្ឍន៍ដោយវិទ្យាសាស្ត្រ ពួកគេបានទទួលនូវស្នាដៃគួរឱ្យកត់សម្គាល់ដោយអាស្រ័យលើប្រាជ្ញា សម្ហូហភាព និងកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិកការងារគ្រប់ រូបដែលបានកត់ត្រានូវសមិទ្ធផលជាផ្លែផ្ការបស់ក្រុមហ៊ុនស្ថាបនកម្មយូណាន ។

បើកផ្ទាំងគំនូរដ៏ត្រចះត្រចង់នៃក្រុមហ៊ុនស្ថាបនកម្មយូណាន ម៉ាកល្បីរបស់ក្រុមហ៊ុនបានបញ្ចាំងនូវពន្លឺដ៏ភ្លឺចិញ្ចាច ។ នៅឆ្នាំ ២០១៤ ក្រោមស្ថានការណ៍ទូទៅដែលមានភាពតានតឹងក្រុមហ៊ុនស្ថាបនកម្មយូណានបានសម្រេចនូវសូចនាករសេដ្ឋកិច្ចកម្រិតថ្មីលើគ្រប់វិស័យ និងបានក្លាយទៅជាគជំដ៏ភ្លឺមួយគ្រាប់ក្នុងចំណោមសហគ្រាសស្ថាបនកម្មរដ្ឋខ្នាតធំនៅភាគខាងលិចប្រទេសចិន ។ ក្រោមការណែនាំនៃយុទ្ធសាស្ត្រផ្លាស់ទម្រង់និងលើកកម្ពស់កម្រិតថ្នាក់ ក្រុមហ៊ុនស្ថាបនកម្មយូណានមានសមត្ថភាពចម្រុះកាន់តែខ្លាំង និងមានឥទ្ធិពលនិងភាពល្បី-ល្បាញកាន់តែទូលំទូលាយ ។ ក្រុមហ៊ុនបានជាប់ឈ្មោះជាសហគ្រាសខ្លាំងទាំង ៥០០ នៅទូទាំងប្រទេសចំនួន ២៣ លើក ចំណាត់ថ្នាក់បានផ្លោះពីលេខ ២៩៥ មកដល់លេខ ២៣ ។ មិនតែប៉ុណ្ណោះទេ ក្រុមហ៊ុនបានជាប់ឈ្មោះជាសហគ្រាសម៉ៅការផ្នែកវិស្វកម្មធំជាងគេលើពិភពលោក ដែលជ្រើសរើសដោយទស្សនាវដ្តី"Engineering News-Record"របស់អាមេរិកក្នុងរយៈពេល ៥ ឆ្នាំជាប់ ស្ថិតនៅក្នុងចំណាត់ថ្នាក់លេខ ១៦៦ ហើយបានជាប់ចំណាត់ថ្នាក់លេខ ៧២ ក្នុងចំណោមក្រុមហ៊ុនអន្តរជាតិល្បីឈ្មោះទាំង ១០០ នៅប្រទេសចិន ។ ជាពិសេសក្រុមហ៊ុនស្ថាបនកម្មយូណានបានជាប់ចំណាត់ថ្នាក់លេខ ៩ ក្នុងចំណោមសហគ្រាសខ្លាំងទាំង ១០០ នៅខេត្តយូណាន ។

ពេលបើកមើលផ្ទាំងគំនូរនៃស្នាដៃដ៏ត្រចះត្រចង់របស់ក្រុមហ៊ុនស្ថាបនកម្មយូណាន យើងអាចឃើញនូវគម្រោងពាសពេញទីផ្សារជាតិនិងអន្តរជាតិ ដែលរួមមានវិស្វកម្មសាងសង់ព្រលានយន្តហោះ អគារខ្ពស់ មជ្ឈមណ្ឌលពិព័រណ៍ពហុកីឡដ្ឋាន រោងចក្រសម្អាតទឹកកខ្វក់ រោងចក្រប្រេងកាតនិងឧស្សាហកម្មគីមី និងវិស្វកម្មសាងសង់ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ សរុបមានរាប់សិបប្រភេទ ។ ក្នុងចំណោមនោះមានវិស្វកម្មជានិមិត្តសញ្ញានិងមានលក្ខណៈតំណាងដូចជាព្រលានយន្តហោះឆាងស្វួយគុនមីង អគារ សាលាខេត្តយូណាន គម្រោងផ្ទះស្នាក់នៅនៅស្រុកស្វួយជាំង ក្រុងសាវធុង វិស្វកម្មពង្រីកមជ្ឈមណ្ឌលពិព័រណ៍អាស៊ីខាងត្បូង វិស្វកម្មបំពង់បញ្ជូនប្រេងកាតនិងឧស្ម័នចិន-មីយ៉ាន់ម៉ា អគារការិយាល័យរដ្ឋាភិបាលកម្ពុជា អគារទីស្នាក់ការកណ្តាលនៃក្រុមហ៊ុនឧស្ម័នធម្មជាតិនៃប្រទេសហ្គីណេអេក្វាទ័រ គម្រោង សាងសង់សណ្ឋាគារអាស៊ី-អឺរ៉ុបនៅរដ្ឋធានីវៀងចន្ទន៍នៃប្រទេសឡាវ និងតំបន់អភិវឌ្ឍន៍សៃសាក់តានៅក្រុងវៀងចន្ទន៍ប្រទេសឡាវ ។ល។

ប៉ុន្មានឆ្នាំកន្លងទៅនេះ ក្រុមហ៊ុនស្ថាបត្យកម្មយូណាន បានអនុវត្តការសាងសង់សំណង់គ្រប់ប្រភេទមានទំហំសរុបជាង ៩៤ លានម៉ែត្រការ៉េដែលមានតម្លៃផលិតកម្មសរុបជាង ១៨០ ០០០ លានយាន់ប្រាក់ចិន ទទួលបានរង្វាន់វិស្វកម្ម"លូបាន" ចំនួន ២១លើករង្វាន់មេដាយប្រាក់នៃវិស្វកម្មគុណភាពខ្ពស់ថ្នាក់ជាតិចំនួន ៣០ រង្វាន់វិស្វកម្មសាងសង់"ចានធានយូ"ចំនួន ១ រង្វាន់វិស្វកម្មគួរឱ្យពេញចិត្តចំនួន ១៣ រង្វាន់ វីកចម្រើនខាងបច្ចេកវិទ្យាថ្នាក់ជាតិនិងថ្នាក់ក្រសួងជាង ៤០០ រង្វាន់និងរង្វាន់វិស្វកម្មគុណភាពខ្ពស់ថ្នាក់ក្រសួងចំនួន ៣៥៩ ។ បច្ចុប្បន្នក្រុមហ៊ុនស្ថាបនកម្មយូណានមានលក្ខណៈសម្បត្តិសំខាន់និងលក្ខណៈបន្ថែមខាងស្ថាបនកម្មចំនួន ៩១ ក្នុងនោះមានលក្ខណៈសម្បត្តិពិសេសនៃការម៉ៅការផ្នែកវិស្វកម្មរួមខាងស្ថាបនកម្មចំនួន ២ ព្រមទាំងលក្ខណៈសម្បត្តិម៉ៅការផ្នែកវិស្វកម្មរួមថ្នាក់លេខ ១ និងលក្ខណៈសម្បត្តិជំនាញថ្នាក់លេខ ១ ចំនួនជាង ៦០ ហើយមានមជ្ឈមណ្ឌលបច្ចេកទេសថ្នាក់ជាតិចំនួន ១ មជ្ឈម-ណ្ឌលបច្ចេកទេសថ្នាក់ខេត្តចំនួន ៧ និងបានបង្កើតស្ថានីយប្រចាំការនៃបណ្ឌិត្យសភា និងអ្នកបច្ចេកទេសបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតដែលជាប់លំដាប់ថ្នាក់លេខ ១ ក្នុងបណ្តាសហគ្រាស



តំបន់អភិវឌ្ឍន៍សៃសាក់តានៅក្រុងវៀងចន្ទន៍ប្រទេសឡាវ តំបន់ស្នូលនៅភូមិភាគខាងលិច
老挝赛色塔综合开发区——西部核心区

នានានៅភូមិភាគខាងលិចប្រទេសចិន ហើយក៏បានទទួលកម្មសិទ្ធិបញ្ញាជាច្រើនទៀតលើវិស័យស្ថាបនកម្មដែរ ។ គួរបញ្ជាក់ថាផលិតផលបេតុងបែតងរបស់ក្រុមហ៊ុនកំពុងស្ថិតនៅក្នុងជួរសហគ្រាសនាំមុខទាំង ១០ក្នុងប្រទេសចិន ។

នៅឆ្នាំ ២០១២ វិស្វកម្មផ្លាស់លំនៅដ្ឋានប្រជាពលរដ្ឋនៅក្រុងសាវធុងបានត្រូវបញ្ចប់ការសាងសង់ជាស្ថាពរ ។ ក្រុមហ៊ុនស្ថាបនកម្មយូណានបានប្រើប្រាស់រយៈពេលមិនដល់មួយឆ្នាំផងក្នុងការបង្កើតទីរួមស្រុកសួយជាំងថ្មីមួយធានាដល់ការផ្លាស់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋនៅឃុំ ៥ ក្នុងតំបន់អាងទឹកសៀងចា និងឃុំ ៦ នៅតំបន់អាងទឹកស៊ីល្វទូ និងបានបង្កលក្ខណៈងាយស្រួលដល់ការរស់នៅដោយសុខសាន្តរបស់ប្រជាជនចំនួន ៦ ម៉ឺននាក់ ធ្វើឱ្យសម្រេចការស្តុកទឹកបានតាមពេលកំណត់ និងបានបង្កើតល្បឿនបំបែកឯតទគ្គកម្មថ្មីមួយ ដែលជាអច្ឆរិយៈគួរឱ្យចាប់អារម្មណ៍ក្នុងវិស័យស្ថាបនកម្ម ។ នៅឆ្នាំ ២០១៤ ក្រោយពីការរញ្ជួយដី“៣ សីហា”នៅស្រុកលូទានខេត្តយូណាន ក្រុមហ៊ុនស្ថាបនកម្មយូណានបានបញ្ចប់ការសាងសង់ផ្ទះស្នាក់នៅបណ្តោះអាសន្នដែលមានផ្ទៃក្រឡា ១៦ ម៉ឺនម៉ែត្រការ៉េនៅមុនពេលកំណត់ ។ គិតពីឆ្នាំ ២០១២ មកដល់ពេលនេះ ក្រុមហ៊ុនស្ថាបនកម្មយូណានបានសម្រេចការសាងសង់ផ្ទះស្នាក់នៅជូនដល់ប្រជាជនក្រីក្រដែលមានទុនវិនិយោគលើសពី ១៥ ០០០ លានយាន់ប្រាក់ចិនដែលមានតម្លៃសរុបស្មើនឹង ១២ ៣៥០ លានយាន់ប្រាក់ចិននិងបានគ្របដណ្តប់នូវក្រុងនិងមណ្ឌលចំនួន ១០ នៅខេត្តយូណានរួមមានក្រុងគុនមីងដែលជាទីរួមខេត្តយូណានផងដែរ ។ ការសាងសង់បុរីថ្មីនៃក្រុមហ៊ុនស្ថាបនកម្មយូណាន បានជួយដោះស្រាយបញ្ហាដែល“គ្មានកន្លែងរស់នៅរបស់អ្នកសាងសង់ផ្ទះ” និងបានធ្វើឱ្យបុគ្គលិកការងារច្រើនជំនាន់របស់ក្រុមហ៊ុនស្ថាបនកម្មយូណានទទួលបានផលប្រយោជន៍ពីផ្ទះស្នាក់នៅថ្មីៗ និងចែករំលែកគ្នាអំពីសមិទ្ធផលនៃកំណែទម្រង់ក្រុមហ៊ុនព្រមនិងដឹកនាំកម្មករជាង ១០ ម៉ឺននាក់ដើរឆ្ពោះទៅកាន់ជីវភាពរស់នៅដែលពោរពេញទៅដោយភាពសុខសាន្ត ។



មជ្ឈមណ្ឌលវៀងចន្ទន៍នៅប្រទេសឡាវ

老挝万象中心

បច្ចុប្បន្ន ក្រុមហ៊ុនស្ថាបនកម្មយូណានកំពុងពន្លឿនដំណើរនៃការប្រែក្លាយពីក្រុមហ៊ុនធ្វើអាជីវកម្មតែលើការម៉ៅការផ្នែកវិស្វកម្មរួមទៅជាក្រុមហ៊ុនស្ថាបនកម្មគ្រុបខ្នាតធំ ដែលច្របាច់បញ្ចូលនូវការវិនិយោគនិងការរួមបញ្ចូលទុនការអភិវឌ្ឍន៍អចលនទ្រព្យ និងការម៉ៅការផ្នែកវិស្វកម្មរួម ។

ក្រុមហ៊ុនស្ថាបនកម្មយូណានបានលើកឡើងនូវទស្សនៈធ្វើអាជីវកម្មជាក្រុមហ៊ុនគ្រុប បង្ហាញពីឧត្តមភាពជាវេទិកាធំរបស់ក្រុមហ៊ុនគ្រុប បង្កើនកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រជាមួយសហគ្រាសធំៗ គ្រឹះស្ថានហិរញ្ញវត្ថុ និងស្ថាប័នរដ្ឋាភិបាលដើម្បីសម្រេចនូវការផ្លាស់ទម្រង់ពីការធ្វើអាជីវកម្មលើគម្រោងជាក់ស្តែងទៅជាការធ្វើអាជីវកម្មលើធនធាន ។ ក្រុមហ៊ុនគ្រុបទាំងមូលត្រូវបង្កើតជាកណ្តាប់ដៃដ៏ធំនិងមានកម្លាំងមួយ តាមរយៈការបង្ហាញពីឧត្តមភាពលើម៉ាកល្បី បច្ចេកទេស ការគ្រប់គ្រងធនធានមនុស្ស និងដើមទុន ពង្រីកទ្រង់ទ្រាយនិងក្របខ័ណ្ឌនៃការធ្វើអាជីវកម្ម លើកកម្ពស់កម្រិតថ្នាក់និងគុណភាពនៃការធ្វើអាជីវកម្ម បង្កើនសមត្ថភាពប្រកួតប្រជែងជាស្នូល និងសមត្ថភាពអភិវឌ្ឍន៍ដោយចីរភាពរបស់ក្រុមហ៊ុនគ្រុប សម្រេចនូវការបង្កើតក្រុមហ៊ុនគ្រុបទ្រង់ទ្រាយធំការធ្វើអាជីវកម្មខ្នាតធំ ការអភិវឌ្ឍន៍ដ៏ធំធេង និងការលោតផ្លោះ ។ បច្ចុប្បន្ន ចំនួន ៦០% នៃទំហំកិច្ចសន្យារបស់ក្រុមហ៊ុនយូណានគ្រុបគឺមានប្រភពពីសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រស្ថាបនកម្ម ។

ម្យ៉ាងទៀត ក្រុមហ៊ុនស្ថាបនកម្មយូណានបានក្តាប់ជាប់នូវកាលានុវត្តភាពទីផ្សារ ប្រកាន់ខ្ជាប់នូវការនាំផ្លូវដោយទុនវិនិយោគ សម្រេចនូវការផ្លាស់ទម្រង់និងលើកកម្ពស់កម្រិតថ្នាក់ដោយច្របាច់បញ្ចូលគ្នានូវការបង្កើតមុខរបរនិងប្រមូលទុន ។ ប៉ុន្មានឆ្នាំកន្លងទៅនេះ ក្រុមហ៊ុនស្ថាបនកម្មយូណានបានចាត់ទុកការប្រមូលទុនជាចំណុចស្នូលក្នុងការងារប្រចាំថ្ងៃ ។ តាមរយៈការបង្កើតវេទិកាវិនិយោគនិងប្រមូលទុនចំនួន ៥ ពោលគឺទីស្នាក់ការកណ្តាលនៃក្រុមហ៊ុនស្ថាបនកម្មយូណានគ្រុប ក្រុមហ៊ុនវិនិយោគលើការកសាងទីក្រុងនិងជនបទខេត្តយូណាន ក្រុមហ៊ុនអភិវឌ្ឍន៍និងធ្វើអាជីវកម្មផ្នែកអចលនទ្រព្យខេត្តយូណានក្រុមហ៊ុនវិនិយោគនៅបរទេសរបស់ខេត្តយូណាន និងក្រុមហ៊ុនមូលនិធិវិនិយោគកម្មសិទ្ធិភាគហ៊ុនសំណង់យូណានកំណត់ផ្នែកវិនិយោគសំខាន់ចំនួន ៧ ដែលរួមមានការសាងសង់ផ្ទះស្នាក់នៅជូនដល់ប្រជាជនក្រីក្រ ការជួសជុលផ្ទះចំណាស់ការអភិវឌ្ឍន៍អចលនទ្រព្យ ការវិនិយោគនៅឯបរទេសការធ្វើអាជីវកម្មលក់ដូរ ភាគហ៊ុន និងការវិនិយោគលើអចលនទ្រព្យសំខាន់ជាដើម ដែលបានបង្កើតជារចនាសម្ព័ន្ធអាជីវកម្មរបស់ក្រុមហ៊ុនស្ថាបនកម្មយូណានដែលមានលក្ខណៈច្របាច់បញ្ចូលគ្នានូវការបង្កើតមុខរបរនិងប្រមូលទុន ។

ការធ្វើអាជីវកម្មជាក្រុមហ៊ុនគ្រុប និងការច្របាច់បញ្ចូលគ្នានូវការបង្កើតមុខរបរនិងប្រមូលទុន ដែលជាកម្លាំងចលករពីរប្រភេទនោះ បានជួយពង្រីកនិងកែលម្អរចនាសម្ព័ន្ធអាជីវកម្មរបស់ក្រុមហ៊ុនស្ថាបនកម្មយូណាន និងបានធ្វើឱ្យក្រុមហ៊ុនប្រឈមនឹងការលើកកម្ពស់កម្រិតថ្នាក់នៃរចនាសម្ព័ន្ធអាជីវកម្មជាថ្មីម្តងទៀត ។ ក្នុងគម្រោងសាងសង់ផ្ទះស្នាក់នៅជូនដល់ប្រជាជនក្រីក្រ និងជួសជុលផ្ទះចំណាស់ ក្រុមហ៊ុនវិនិយោគលើការកសាងទីក្រុង និងជនបទខេត្តយូណាន ដែលនៅក្រោមឱវាទក្រុមហ៊ុនស្ថាបនកម្មយូណានបានសាងសង់ផ្ទះស្នាក់នៅជូនដល់ប្រជាជនក្រីក្រ (បែបខុនដូ) ចំនួន ១២,៥ ម៉ឺនបន្ទប់សម្រាប់ឆ្នាំ ២០១២ និងជាង ៦ ម៉ឺនបន្ទប់សម្រាប់ឆ្នាំ ២០១៣ ដែលប្រើទុនវិនិយោគសរុបជិត ១១ ៤៩៥ លាន

យាន់ប្រាក់ចិន ។ នៅឆ្នាំ ២០១៤ ក្រុមហ៊ុនមានគម្រោងសាងសង់ផ្ទះស្នាក់នៅជូនដល់ប្រជាជនក្រីក្រ ដែលប្រើទុនវិនិយោគប្រមាណ ២០ ០០០ លានយាន់ ហើយបច្ចុប្បន្នបានបើកការដ្ឋានសាងសង់នៅគ្រប់ទីកន្លែង ។ និយាយជារួម ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៤ ក្រុមហ៊ុនវិនិយោគលើការកសាងទីក្រុងនិងជនបទខេត្តយូណានបានបណ្តាក់ទុនវិនិយោគ ៤០ ០០០ លានយាន់ក្នុងការសាងសង់ផ្ទះស្នាក់នៅជូនដល់ប្រជាជនក្រីក្រ ។ គួរបញ្ជាក់ថា ក្រុមហ៊ុនស្ថាបនកម្មយូណានបានបង្ហាញម្តងទៀតអំពីកម្លាំងអភិវឌ្ឍន៍និងប្រមូលទុនដ៏ខ្លាំងក្លារបស់ខ្លួនក្នុងការជួសជុលផ្ទះចំណាស់ ដោយបានសម្រេចនូវការប្រមូលទុនចំនួន ៦០ ០០០ លានយាន់ ។ ទន្ទឹមនឹងនេះដែរ ក៏បានពង្រឹងមូលដ្ឋានគ្រឹះនៃអាជីវកម្មសំខាន់កសាងសមត្ថភាពលើមុខរបរជំនាញ កែលម្អរចនាសម្ព័ន្ធទីផ្សារនិងរចនាសម្ព័ន្ធអាជីវកម្ម ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ជាពហុវិស័យ ។ ក្រុមហ៊ុនស្ថាបនកម្មយូណានកំពុងតែសាកល្បងអនុវត្តជាក់ស្តែងតាមមាគ៌ាអភិវឌ្ឍន៍នេះ ។

ក្រុមហ៊ុនស្ថាបនកម្មយូណានបានលើកឡើងថា ត្រូវតែប្រែក្លាយពីក្រុមហ៊ុនដែលធ្វើអាជីវកម្មតែលើការម៉ៅការផ្នែកវិស្វកម្មរួមទៅជាក្រុមហ៊ុនដែលធ្វើអាជីវកម្មលើផ្នែកវិនិយោគទុននិងប្រមូលទុន ការអភិវឌ្ឍន៍អចលនទ្រព្យនិងការម៉ៅការផ្នែកវិស្វកម្មរួម ដើម្បីធ្វើឱ្យក្រុមហ៊ុនស្ថាបនកម្មយូណានក្លាយទៅជាក្រុមហ៊ុនគ្រុបទ្រង់ទ្រាយធំដែលមានសមត្ថភាពគូរប្លង់សិក្សាស្រាវជ្រាវ អនុវត្តការសាងសង់ ពិគ្រោះយោបល់វិនិយោគទុននិងប្រមូលទុន ព្រមនិងអភិវឌ្ឍន៍ជាក់ស្តែង ហើយមានរចនាសម្ព័ន្ធអាជីវកម្មគ្រប់ប្រភេទ សមត្ថភាព ប្រកួតប្រជែងចម្រុះនិងឥទ្ធិពលអន្តរជាតិខ្លាំងក្លា ។

ក្នុងវិស័យអភិវឌ្ឍន៍អចលនទ្រព្យដែលជាកម្មវត្ថុអាជីវកម្មសំខាន់ទី ២ របស់ក្រុមហ៊ុនស្ថាបនកម្មយូណាន ក្រុមហ៊ុនអភិវឌ្ឍន៍និងធ្វើអាជីវកម្មអចលនទ្រព្យខេត្តយូណាន ដែលជាក្រុមហ៊ុនចំណុះឱ្យក្រុមហ៊ុនស្ថាបនកម្មយូណានបានក្លាយជាក្រុមហ៊ុនធ្វើអាជីវកម្មអចលនទ្រព្យដែលមានលក្ខណៈសម្បត្តិលេខ ១ ក្នុងប្រទេសចិន ។ បច្ចុប្បន្ន ក្រុមហ៊ុនអភិវឌ្ឍន៍និងធ្វើអាជីវកម្មអចលនទ្រព្យខេត្តយូណានកំពុងពង្រីកកិច្ចការនៅក្នុងក្រុងគុនមីង និងមណ្ឌលផ្សេងៗនៅក្នុងខេត្តយូណានដែលមានគម្រោងអភិវឌ្ឍន៍ជាង ១០ គម្រោង ។

ដើម្បីបំពេញបន្ថែមនូវខ្សែសង្វាក់អាជីវកម្ម លើកកម្ពស់សមត្ថភាពប្រកួតប្រជែងចម្រុះ និងពន្លឿនដំណើរនៃការលើកកម្ពស់កម្រិតថ្នាក់ផ្លាស់ទម្រង់ ក្រុមហ៊ុនស្ថាបនកម្មយូណានខិតខំបង្កើតអាជីវកម្មលើផ្នែកធារាសាស្ត្រ វារីអគ្គិសនី ការដំឡើងគ្រឿងបរិក្ខារ គ្រោងដែក ស្ពាននិងផ្លូវថ្នល់ គ្រឹះផ្ទះ បេតុងការសិក្សានិងគូរប្លង់ ការពិគ្រោះយោបល់ខាងបច្ចេកទេសការសិក្សាស្រាវជ្រាវខាងស្ថាបនកម្ម បច្ចេកទេសនិងវិទ្យាសាស្ត្រខាងសម្ភារៈសំណង់ ពលករសំណង់ មូលនិធិកម្មសិទ្ធិភាគហ៊ុនជាដើម ។ រចនាសម្ព័ន្ធអាជីវកម្មបានគ្របដណ្តប់នូវគ្រប់ក្រុមខ័ណ្ឌខាងស្ថាបនកម្ម និងបានសម្រេចនូវការបន្ថែមខ្សែសង្វាក់ផលិតកម្ម និងទទួលបានផលចំណេញជាក់ស្តែង ។

ការដណ្តើមយកទីផ្សារតាមរយៈការបង្កើនការវិនិយោគការធ្វើអាជីវកម្មសំខាន់តាមរយៈការច្របាច់បញ្ចូលគ្នានូវការបង្កើតមុខរបរនិងប្រមូលទុន បានសម្រេចនូវការប្រើប្រាស់ទុនវិនិយោគនិងការអភិវឌ្ឍន៍មុខរបរជាក់ស្តែង ដោយបានបង្កើតជាប្រព័ន្ធអភិវឌ្ឍន៍ដែលមានលក្ខណៈពេញលេញនិងល្អប្រសើរ ។ សព្វថ្ងៃ ក្រុមហ៊ុនស្ថាបនកម្មយូណានបានដើរចេញពីរចនាសម្ព័ន្ធធ្វើអាជីវកម្មតែលើការម៉ៅការផ្នែកវិស្វកម្មរួមនិងបានបោះជំហានកាន់តែលឿននៅលើមាគ៌ាអភិវឌ្ឍន៍ដោយលោតផ្លោះក្នុងការវិនិយោគទុននិងប្រមូលទុន ការអភិវឌ្ឍន៍អចលនទ្រព្យនិងការម៉ៅការផ្នែកវិស្វកម្មរួម ។

ក្នុងដំណើរអនុវត្តយុទ្ធសាស្ត្រ“ដើរចេញទៅក្រៅ”របស់ប្រទេសចិន ក្រុមហ៊ុនស្ថាបនកម្មយូណានបានមានឈ្មោះបោះសំឡេងខ្ទរនិងដើរតួនាទីកាន់តែសំខាន់ក្នុងទីផ្សារអន្តរជាតិដែលបានបង្កើតជានាមប័ណ្ណអន្តរជាតិរបស់ខ្លួន ។

តាមរយៈកិច្ចខិតខំប្រឹងប្រែងជាច្រើនឆ្នាំ ក្រុមហ៊ុនស្ថាបនកម្មយូណានបានបង្កើតជារចនាសម្ព័ន្ធលើទីផ្សារអន្តរជាតិ ដែលរួមមានទីផ្សារអន្តរជាតិ ៣ គឺទីផ្សារប្រទេសអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូងដែលនៅជិតខាងប្រទេសចិន ទីផ្សារមជ្ឈិមបូព៌ា និងទីផ្សារអាហ្វ្រិក ព្រមនិងបានសម្រេចនូវគម្រោងគំរូជាច្រើននៅតំបន់អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូងមជ្ឈិមបូព៌ានិងទ្វីបអាហ្វ្រិក ។ ក្នុងរយៈពេល ៣ ឆ្នាំកន្លងទៅ ក្រុមហ៊ុនស្ថាបនកម្មយូណានបានឈ្នះការដេញថ្លៃនៃគម្រោងចំនួន ៤៩ នៅឯបរទេស ហើយទំហំអាជីវកម្មប្រចាំឆ្នាំ ២០១២ និង ២០១៣ គឺ ៤ ៥០០ លាន និង ៦ ០០០ លានយាន់ប្រាក់ចិននិងបានបញ្ចប់វិស្វកម្មសាងសង់រួចជាស្ថាពរដែលមានផ្ទៃក្រឡា ១៣ ម៉ឺនម៉ែត្រការ៉េ ។ បច្ចុប្បន្ន គម្រោងសាងសង់ដែលកំពុងដំណើរការរបស់ក្រុមហ៊ុនមានតម្លៃប្រមាណ ៧ ៥០០ លានយាន់ប្រាក់ចិន ក្នុងនោះកិច្ចការផ្នែកអាជីវកម្ម អន្តរជាតិមានអត្រាភាគរយកាន់តែខ្ពស់ទៅៗ ។ ក្រុមហ៊ុនស្ថាបនកម្មយូណានបានពង្រីកកិច្ចការពីការធ្វើគម្រោងតែមួយទៅជាការអភិវឌ្ឍន៍រួមពីការធ្វើកិច្ចសហប្រតិបត្តិការលើគម្រោងទៅជាការធ្វើកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រ ដែលមានអត្រាចុះហត្ថលេខាលើគម្រោងវិនិយោគ និងប្រមូលទុនកាន់តែខ្ពស់និងបានជំរុញដល់ការអភិវឌ្ឍន៍លើវិស័យសម្ភារៈសំណង់ ការគូរប្លង់បច្ចេកទេស និងបញ្ជូនពលករទៅបរទេសជាដើម ហើយក៏បាននាំមកនូវកិច្ចសន្យាមានគុណភាពខ្ពស់កាន់តែច្រើនដល់ក្រុមហ៊ុនស្ថាបនកម្មយូណានផងដែរ ។ ក្នុងដំណើរអនុវត្តជាក់ស្តែងនៅឯនាយសមុទ្រ ក្រុមហ៊ុនស្ថាបនកម្មយូណានបាននិងកំពុងខិតខំកសាងសមត្ថភាពម៉ៅការផ្នែកវិស្វកម្មរួម និងសមត្ថភាពគ្រប់គ្រងការធ្វើវិនិយោគនិងប្រមូលទុនអន្តរជាតិដោយមានសមត្ថភាពនៃការធ្វើអាជីវកម្ម ការគ្រប់គ្រងបច្ចេកទេស ប្រាក់ទុន និងធុរកិច្ចដ៏ខ្លាំងក្លាក្នុងវិស័យជាច្រើនដូចជាការគូរប្លង់ ការអនុវត្តការសាងសង់ ការផ្តល់សេវាកម្ម ការបញ្ជាទិញអន្តរជាតូបនីយកម្ម ការដំណើរការនៃអាជីវកម្មនិងការប្រមូលទុនជាដើម ។ ជាពិសេស ក្រុមហ៊ុនស្ថាបនកម្មយូណានបានធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគ្រាសនិងរដ្ឋាភិបាលនៃបណ្តាប្រទេសនានា និងបានបង្កើតចំណងមិត្តភាពដ៏ជ្រាលជ្រៅជាមួយប្រជាជននៃប្រទេសនានាផងដែរ ។



បុរីធំ ធួតុង
拓东大城

# “ភូមិអណ្តែតទឹកវៀតណាម”នៅលើបឹងទន្លេសាប

## 洞里萨湖上的“越南浮村”

文、图/刘　蓉

在柬埔寨暹粒以南十多公里处的洞里萨湖上，有数个水上村庄。这里的居民大部分都是越南移民，他们在这里主要从事渔业，房屋随着旱雨季水位的变化而不断移动，因而被称作“越南浮村”。

（SOPHAT 译）



អ្នកនេសាទដែលរកបានផលត្រីច្រើន

满载而归的渔民

នៅលើបឹងទន្លេសាបដែលស្ថិតនៅចម្ងាយ ១០ គីឡូម៉ែត្រ ខាងត្បូងខេត្តសៀមរាបនៃប្រទេសកម្ពុជា មានភូមិលើទឹកជាច្រើន ។ ប្រជាពលរដ្ឋដែលរស់នៅទីនេះ ភាគច្រើនគឺជាជនភៀសខ្លួនវៀតណាម ពួកគេប្រកបរបរនេសាទជាចម្បង ផ្ទះសម្បែងផ្លាស់ប្តូរឡើងចុះទៅតាមកម្ពស់ទឹកនារដូវវស្សានិងរដូវប្រាំង ហើយត្រូវបានហៅថា“ភូមិអណ្តែតទឹកវៀតណាម” ។

ផ្ទះអណ្តែតទឹករាប់រយផ្ទះនៃភូមិអណ្តែតទឹកសុទ្ធតែធ្វើឡើងអំពីឫស្សី ដោយប្រើប្រាស់យុត្តិការសម្រាប់ទប់លំនឹងផ្ទះ ។ ជាយូរឆ្នាំណាស់មកហើយ ប្រជាពលរដ្ឋដែលរស់នៅលើទឹកក្នុងភូមិអណ្តែតទឹកនេះ ប្រកបរបរនេសាទចិញ្ចឹមជីវិតជាមួយគ្នា ។ ច្រើនឆ្នាំមកនេះ ឧបករណ៍នេសាទរបស់ពួកគេក៏មានការប្រែប្រួលទៅតាមការអភិវឌ្ឍន៍នៃសម័យកាល ដែលធ្លាប់តែប្រើប្រាស់ទូកឈើ ច្បូក តែបច្ចុប្បន្នគឺប្រើប្រាស់ទូកម៉ាស៊ីននិងសំណាញ់ ។ សកម្មភាពនេសាទដ៏ប៉ិនប្រសប់របស់ប្រជា-នេសាទបានក្លាយជាទិដ្ឋភាពលើទឹកដ៏ស្រស់ស្អាត ។ នាពេលព្រឹកព្រលឹមរាល់ថ្ងៃ ច្រាំងបឹងភូមិអណ្តែតទឹកគឺជាទីផ្សារជួញដូរត្រីទៀងទាត់ ផ្សារតូចមួយនេះមានសភាពអ៊ូអរខុសពីធម្មតា ប្រជានេសាទបង្ហាញនូវទឹកមុខសប្បាយរីករាយក្នុងការទទួលបានផលនេសាទ ។ ពេលល្ងាច ព្រះអាទិត្យចែងចាំងពន្លឺពណ៌ក្រហមទៅលើបឹងទន្លេសាប ផ្លូវទឹកនៃភូមិអណ្តែតទឹកមានភាពអ៊ូអរមមាញឹកយ៉ាងខ្លាំង គ្រប់គ្រួសាររៀបចំទទួលទានអាហារពេលល្ងាច ផ្សែងចង្ក្រានហោះហើរនៅលើផ្ទៃបឹង សំឡេងស្ត្រីមេផ្ទះ ស្រែកហៅកូនៗដែលកំពុងតែអុំកាធុនដែកលេងទឹកបានបន្លឺឡើងបន្តគ្នា ។

ប្រជានេសាទនៃភូមិអណ្តែតទឹករស់នៅក្នុងជីវភាពបន្ទាស់ទីទៅតាមការឡើងនិងស្រករបស់ទឹកបឹង ។ ពេលរដូវប្រាំងមកដល់ ទឹកបឹងស្រកចុះ ហ្វូងមច្ឆាបង្ហាញខ្លួន អ្នកនេសាទចាប់ផ្តើមរំកិលទៅកណ្តាលបឹង ប្រមូលផលនេសាទពីក្នុងសំណាញ់ក្រោមពន្លឺព្រះអាទិត្យរបស់ពួកគេ ។ ជារៀងរាល់ឆ្នាំចាប់ពីខែមិថុនាដល់ខែតុលា រដូវវស្សាមកដល់កម្ពស់ទឹកចាប់ផ្តើមឡើងស្រើតៗ ពួកគេក៏ចាប់ផ្តើមឡើងដល់មាត់ច្រាំងទីតាំងផ្លាស់ប្តូរអាស្រ័យទៅលើកម្ពស់ទឹក ។ នៅពេលដែលទឹកស្រកចុះ ក៏ប្តូរទៅលើបឹងបន្តជីវភាពនេសាទរបស់ពួកគេ ។ ក្នុងរដូវទឹកឡើងដែលមិនអាចនេសាទបាន ពួកអ្នកនេសាទក៏អុំទូកតូចៗលក់ទំនិញតូចៗ ។ អ្នកភូមិទាំងអស់សប្បាយរីករាយ រួមសុខទុក្ខជាមួយគ្នា ផ្តល់នូវក្តីសង្ឃឹមដល់កូនចៅជំនាន់ក្រោយ ។

បឹងទន្លេសាបគឺជាទីលាននេសាទធម្មជាតិ ដែលធំបំផុតក្នុងដងទន្លេឡានឆាង-មេគង្គ គឺជាតំបន់ទឹកបឹងមាសនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានគេប្រសិទ្ធនាមថា “បឹងមាតា” របស់ប្រជាជនកម្ពុជា ។ ប្រាសាទអង្គរវត្តដ៏ល្បីរន្ទឺគឺស្ថិតនៅច្រាំងខាងជើងនៃបឹងទន្លេសាប ។ ជាច្រើនពាន់ឆ្នាំមកនេះ ធនធាននេសាទដែលមិនចេះរីងស្ងួតរបស់បឹងទន្លេសាប បានជួយថែរក្សាអារ្យធម៌ខ្មែរដ៏អស្ចារ្យ ។ បច្ចុប្បន្ននេះ“ភូមិអណ្តែតទឹកវៀតណាម”លើបឹងទន្លេសាបបានក្លាយជាតំបន់ទេសចរណ៍មួយដែលភ្ញៀវទេសចរណ៍មកពីគ្រប់តំបន់ក្នុងពិភពលោកមិនអាចមើលរំលងបានក្នុងខណៈពេលមកលេងកម្សាន្តនៅក្នុងប្រទេសកម្ពុជា ។ នៅទីនេះ អ្នកអាចជិះទូកទៅទស្សនាភូមិអណ្តែតទឹកទាំងនេះ មើលផ្ទះលើទឹក វិហារលើទឹក និងសាលាលើទឹកជាដើម ហើយនៅពេលល្ងាចក៏អាចគយគន់ទិដ្ឋភាពថ្ងៃលិចលើបឹង ដែលមានលក្ខណៈពិសេសដូចនៅប្រាសាទអង្គរវត្តដែរ ។




ភូមិអណ្តែតលើទឹក

浮村

# ក្រុមហ៊ុន សីហនុវីល ស្ពេសល អ៊ីខនណើមី ហ្សូន
## 西哈努克港经济特区有限公司
## Sihanoukville Special Economy Zone Co.,Ltd.



តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោម ដែលរួមគ្នាអភិ-វឌ្ឍន៍ដោយក្រុមហ៊ុនហុងដូ គ្រុប និងក្រុមហ៊ុនវិនិយោគទុនអន្តរជាតិគ្រុប កម្ពុជា គឺជាតំបន់សហប្រតិបត្តិការខាងសេដ្ឋកិច្ចនិងពាណិជ្ជកម្មមួយ ក្នុងចំណោមតំបន់សហប្រតិបត្តិការខាងសេដ្ឋកិច្ចនិងពាណិជ្ជកម្មក្រៅប្រទេសជើងទីមួយរបស់ប្រទេសចិន ដែលត្រូវបានអនុម័តនិងទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម និងក្រសួងហិរញ្ញវត្ថុប្រទេសចិន ហើយក៏ជាតំបន់សេដ្ឋកិច្ចពិសេសធំជាងគេបំផុតក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ ។ តំបន់សេដ្ឋកិច្ចពិសេសនេះមានផ្ទៃក្រឡាតាមការគូរប្លង់សរុប ១១,១៣ គីឡូម៉ែត្រក្រឡា និងចាត់ទុកឧស្សាហកម្មអំពីវាយនភណ្ឌ គ្រឿងបន្លាស់និងគ្រឿងចក្រ គ្រឿងអគ្គិសនីផុនស្រាដែលប្រើប្រាស់នៅក្នុងផ្ទះជាគោលណែនាំ ។ សព្វថ្ងៃ សហគ្រាសដែលចូលដំណើរការក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះមានចំនួនរាប់សិបសហគ្រាសហើយ ។

គម្រោងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោមបានទទួលនូវការយកចិត្តទុកដាក់កម្រិតខ្ពស់ពីអ្នកដឹកនាំនិងស្ថាប័នរដ្ឋ គ្រប់ជាន់ថ្នាក់នៃប្រទេសទាំងពីរចិន-កម្ពុជា ។ កាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១០ ប្រទេសចិននិងកម្ពុជាបានចុះហត្ថលេខាជាផ្លូវការនូវ "កិច្ចព្រមព្រៀងស្តីពីតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោមរវាងសាធារណរដ្ឋប្រជាមានិតចិននិងព្រះរាជាណាចក្រកម្ពុជា" ។ កិច្ចព្រមព្រៀងនេះ បានកំណត់ច្បាស់នូវតួនាទីខាងច្បាប់នៃតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោមនិងបានកំណត់ឱ្យច្បាស់ថា ភាគីទាំងពីរដែលបានចុះហត្ថលេខារួមគ្នា ផ្តល់ការគាំទ្រនិងការសម្រួលដល់ការស្ថាបនា គ្រប់គ្រងនិងដំណើរការនៃតំបន់សេដ្ឋកិច្ចនេះ ហើយក៏បានកំណត់ច្បាស់នូវការបង្កើតគណៈកម្មការសម្របសម្រួល ថ្នាក់ក្រសួងទ្វេភាគីនៃតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោម នៅក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀង ដើម្បីសិក្សាស្រាវជ្រាវអំពីបញ្ហាសំខាន់ៗដែលជួបប្រទះក្នុងការស្ថាបនា និងដំណើរការជាដើមនៃតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោម ។ កិច្ចព្រមព្រៀងទ្វេភាគីនេះបានបើកទំព័រថ្មីសម្រាប់តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោម !

សូមស្វាគមន៍ដោយក្តីស្មោះសរចំពោះបណ្តាអ្នកវិនិយោគទាំងអស់អញ្ជើញមកធ្វើការវិនិយោគ !

ទន្ទឹងរង់ចាំការចូលរួមពីសំណាក់លោកអ្នក !






1、坐拥优越的地理位置，交通便利

2、享受优惠的税收政策，低价运营

3、提供优质的配套服务，贴心周到

**期待您的加盟！**



SSEZ

**招商热线：** 00855-88-5678892、00855-16-391335

**地址：** 西哈努克市波雷诺区毕德朗分区布腾村和云壤分区斯马奇登村　**网址：** www.ssez.com

# ទីក្រុងបុរាណហ៊ុយចូវ

## 徽州古城

徽州古城坐落在国家历史文化名城歙县县城徽城镇中心，千年徽州府治所在地，内有许国石坊、许国相府、南谯楼、阳和门、徽州府衙、徽园以及斗山街等府城街巷，还有江南都江堰渔梁古坝，中国历史文化名街渔梁街等，是展示和体现徽州文化的重要实物建筑。歙县徽州古城与云南丽江、山西平遥、四川阆中并称为中国保存最完好的四大古城。

(SOPHAT 译)

ទីក្រុងបុរាណហ៊ុយចូវស្ថិតនៅចំកណ្តាលឃុំហ៊ុយឆឹងទីរួមស្រុកសឺសៀន ដែលជាទីក្រុងវប្បធម៌និងប្រវត្តិសាស្ត្រថ្នាក់ជាតិដ៏ល្បីឈ្មោះរបស់ចិន និងជាទីតាំងស្ថិតនៅនៃដំណាក់មន្ត្រីហ៊ុយចូវ ខាងក្នុងមានខ្លោងទ្វារវីរជន ដំណាក់វីរជន ដំណាក់ណានឈាវ ទ្វារយ៉ាងហឺ ដំណាក់មន្ត្រីហ៊ុយចូវ សួនហ៊ុយចូវ និងវិថីតូវសានជាដើម នៅមានទំនប់ទឹកបុរាណទូជាង និងវិថីយូលាងដែលជាវិថីវប្បធម៌ប្រវត្តិសាស្ត្រល្បីឈ្មោះមួយ ទាំងនេះសុទ្ធសឹងតែជាសំណង់ពិតៗ និងសំខាន់ដែលបង្ហាញអំពីវប្បធម៌របស់ហ៊ុយចូវ ។ ទីក្រុងបុរាណហ៊ុយចូវស្រុកសឺសៀនរួមជាមួយលីជាងខេត្តអ៊ីនណាន ភីងយ៉ាវខេត្តសានស៊ី និងឡាំងចុងខេត្តស៊ីឈួន ត្រូវបានចាត់ទុកថាជាទីក្រុងបុរាណបួនរបស់ចិន ដែលរក្សាទុកបានល្អបំផុត ។

ហ៊ុយចូវ ហៅកាត់ថា "ហ៊ុយ" កាលពីដើមហៅថា "សឺចូវ" ហើយមានឈ្មោះមួយទៀតគឺ ស៊ីនអាន គឺជាតំបន់មួយក្នុងខេត្តជឺជាំងតាំងពីដើមមក ហើយក៏ជាដើមកំណើតនៃឈ្មោះ "ហ៊ុយ" នៃខេត្តអានហ៊ុយដែលកាត់ចេញពីខេត្តជាំងណាន ។

ហ៊ុយចូវជាតំបន់ស័ក្តិសិទ្ធិ និងសម្បូរទៅដោយធនធានមនុស្ស មិនត្រឹមតែល្បីឈ្មោះទាំងក្នុងប្រទេសចិន និងបរទេសដោយសារទេសភាពធម្មជាតិដ៏ស្អាតអស្ចារ្យប៉ុណ្ណោះទេ ថែមទាំងល្បីឈ្មោះលើពិភពលោកដោយសារហ៊ុយចូវមានវប្បធម៌ត្រចះត្រចង់ទៀតផង ។ ហ៊ុយចូវតាំងពីដើមមកត្រូវបានគេហៅថា "តំបន់ដែលមានភ្នំ ៨,៥ ភាគ ទឹក ១ ភាគ និងស្រែចម្ការកន្លះភាគ" ។ នៅក្នុងតំបន់នេះ ជងភ្នំខ្ពស់ទល់មេឃតម្រៀបគ្នា ជ្រលងភ្នំខ្វាត់ខ្វែងគ្នា ហើយក៏មានបាតភ្នំ វាលទំនាប ទឹកហូរទៅវិញទៅមក ទឹករលកថ្លាឆ្វង់ ពោរពេញទៅដោយទេសភាពទឹកភ្នំដ៏ស្រស់ស្អាត ហាក់បីដូចជាផ្ទាំងគំនូរទេសភាពដ៏វិចិត្រមួយ ។ តំបន់ទេសភាពក្នុងស្រុកសំខាន់ៗមានដូចជា សួនហ៊ុយចូវ ខ្លោងទ្វារវីរជន វិថីយូលាង និងវិថីតូវសានជាដើម ។

សួនហ៊ុយចូវមានទ្រង់ទ្រាយធំអស្ចារ្យ មានលក្ខណៈបុរាណសាមញ្ញតែវិសេសវិសាល និងគួរឱ្យគយគន់រចនាសម្ព័ន្ធល្អឥតខ្ចោះ ។ ជញ្ជាំងឥដ្ឋឆ្លាស់គ្នា មានលំដាប់លំដោយល្អរៀបរយ ។ ចម្លាក់ដ៏ល្អប្រណីត ខាងលើបង្ហាញអំពីវប្បធម៌ហ៊ុយចូវបុរាណ ខាងក្រោមបង្ហាញអំពីភាពល្អឥតខ្ចោះនៃចម្លាក់លើសំណង់ ពោរពេញទៅដោយភាពទាក់ទាញ ។ ទីនោះមានភាពល្អឥតខ្ចោះនៃ"ចម្លាក់ ហ៊ុយចូវទាំងបី" គឺចម្លាក់ឥដ្ឋចម្លាក់ឈើនិងចម្លាក់ថ្ម ។

ខ្លោងទ្វារវីរជន ហៅថាខ្លោងទ្វារមហាបរិញ្ញា ដែលជាទូទៅហៅថាអគារវីរជនសសរ ៨ បានកសាងឡើងពីឆ្នាំ ១៥៨៤ មានសសរ ៨ ផ្ទៃរាបរាង ៤ ជ្រុង ពីត្បូងទៅជើងប្រវែង ១១,៥៦ ម៉ែត្រ ។ ខ្លោងទ្វារថ្មនេះត្រូវបានតុបតែងលម្អដោយចម្លាក់ឈើ រូបភាពពិសេសហើយស្អាត ថ្វីដែចម្លាក់ល្អឥតខ្ចោះ ។ ខ្លោងទ្វារវីរជនគឺជាស្នាដៃដ៏លេចធ្លោបំផុតក្នុងចំណោមខ្លោងទ្វារថ្មនៅហ៊ុយចូវទាំងអស់ ជារួមបានបង្ហាញអំពីកម្រិតខ្ពស់បំផុតនៃវិចិត្រសិល្បៈកសាងខ្លោងទ្វារថ្ម ក្នុងនោះរចនាម៉ូដខ្លោងទ្វារថ្មអគារ ៣ ជាន់ សសរ ៤ ទល់មេឃ មានប្រវត្តិកាលរាប់រយឆ្នាំ ហើយមានតួនាទីដ៏លេចធ្លោក្នុងប្រវត្តិសាស្ត្រសំណង់ខ្លោងទ្វារ ដែលនៅទូទាំងប្រទេសចិនគឺមានតែមួយគ្មានពីរ ។

វិថីយូលាងគឺជាវិថីវប្បធម៌និងប្រវត្តិសាស្ត្រជាតិដ៏ល្បីឈ្មោះមួយ យូលាងគឺជាកំពង់ផែផ្លូវទឹកដ៏សំខាន់ ដែលពួកពាណិជ្ជករហ៊ុយចូវប្រកបរបររកស៊ីបានប្រសើររាប់រយឆ្នាំមកហើយ រហូតមកដល់បច្ចុប្បន្នក៏នៅរក្សាទុកនូវទម្រង់ដើមនៃមហាវិថីបុរាណ ច្រាំងទន្លេនិងកំពង់ផែដដែល គឺជាផ្លូវឆ្លងកាត់ដ៏ចាំបាច់មួយសម្រាប់ក្រុមពាណិជ្ជករហ៊ុយចូវចេញចូលរកស៊ី ហើយក៏ជាផ្លូវដ៏សំខាន់សម្រាប់ពួកមន្ត្រីចេញបំពេញភារកិច្ចដែរត្រូវបានគេដាក់ឈ្មោះថា "ប្រភពពាណិជ្ជកម្មហ៊ុយចូវ" ។ វិថីបុរាណយូលាងនេះអមទៅដោយទឹកនិងភ្នំក្រាលថ្មក្រួសពណ៌តែមួយ មើលទៅហាក់ដូចជាស្រកាត្រី ហើយដោយសារវិថីនេះមានរាងដូចជាត្រីរស់ ដូច្នេះក៏ហៅថា"វិថីស្រកាត្រី" ។ វិថីស្រកាត្រីបត់បែន ១ គីឡូម៉ែត្រ សងខាងផ្លូវពាសពេញដោយហាងលក់ទំនិញ ។ មានវិហារបុរាណផ្ទះបុរាណ វត្តបុរាណជាច្រើននៅតាមដងផ្លូវដោយមានរបៀបរៀបរយ ដូច្នេះគេហៅថាវិថីទឹកទី ១ នៅតំបន់ជាំងណាន ។

វិថីតូវសានមានឈ្មោះដោយសារវាមានរាងដូចផ្កាយនង្គ័ល កសាងឡើងនៅសម័យម៉េងឆេង ប្រវែងផ្លូវជាង ៣០០ ម៉ែត្រ ផ្តុំទៅដោយផ្ទះសម្បែងបុរាណរបស់ប្រជាជន ផ្លូវបុរាណ ចម្លាក់បុរាណ អណ្តូងបុរាណ ខ្លោងទ្វារបុរាណ ហើយបានបណ្តុំនូវរចនាបថសំណង់ហ៊ុយចូវ ដោយយកគេហដ្ឋានគ្រួសារត្រកូលស៊ី វ៉ង់ យ៉ាង និងវ៉ាងជាតំណាងសំខាន់ មានលក្ខណៈធំធេង មានរូបរាងបុរាណសាមញ្ញ មានចម្លាក់ល្អប្រណីត មានលក្ខណៈដ៏វិសេសវិសាល គឺជាតំបន់ដែលពាណិជ្ជករហ៊ុយចូវកាលពីមុនប្រមូលផ្តុំគ្នារស់នៅ ។



ក្លោងទ្វារ ៨ ជ្រុងបណ្ឌិត្យសភាចារ្យ
大学士八角牌坊 cnsphoto


ក្លោងទ្វារដំណាក់ហួយចូវ
"徽州府"牌楼 cnsphoto

图/cfp

# វាលស្មៅអ៊ីលី

## 伊犁草原

伊犁草原发育于亚洲最大山系之一天山山脉的中天山及其山间盆地。其北、东、南三面环山，西部开口迎接西来湿润的气流，成为荒漠区中风景这边独好的“湿岛”，促成伊犁草原完整的垂直带谱发育。

（SOPHAT 译）

វាលស្មៅអ៊ីលីមានទីតាំងស្ថិតនៅភ្នំចុងធានសាន និងរណ្ដៅភ្នំរបស់វាក្នុងជួរភ្នំធានសាន ដែលជាជួរភ្នំមួយក្នុងចំណោម ជួរភ្នំធំជាងគេបំផុតនៅទ្វីបអាស៊ី ។ ផ្នែកខាងជើងកើត និងត្បូងរបស់វាព័ទ្ធជុំវិញទៅដោយភ្នំ មាត់ច្រកខាងលិចមានធាតុខ្យល់អាកាសសើមមកពីទិសខាងលិច ក្លាយជា“កោះសើម”ដែលមានទេសភាពស្រស់ស្អាតជាងគេក្នុងតំបន់ទីវាលនេះ ជំរុញឱ្យវាលស្មៅអ៊ីលីលូតលាស់បានយ៉ាងល្អ និងប្រកបដោយទេសភាពគ្រប់ប្រភេទ ។ តាំងពីទីខ្ពស់ដល់ទីទាបដុះពេញទៅដោយវាលស្មៅតូចៗធន់នឹងអាកាសធាតុត្រជាក់ខ្លាំង វាលស្មៅតូចៗតំបន់ភ្នំ វាលស្មៅតំបន់ភ្នំ វាលស្មៅទីវាលតំបន់ភ្នំ ទីវាលទំនាបវាលស្មៅតូចៗដងទន្លេដោយមានប្រភេទដីសម្បូរបែប ។

អាកាសធាតុនៅវាលស្មៅអ៊ីលីក្ដៅហើយសើម ដីមានជីជាតិ ។ ថ្វីត្បិតតែច្រាំងទាំងពីរនៃដងទន្លេមានភ្លៀងធ្លាក់តិច ប៉ុន្តែនៅលើភ្នំមានភ្លៀងធ្លាក់ច្រើន ។ នៅទីនេះមានលក្ខណៈធម្មជាតិល្អប្រសើរ សីតុណ្ហភាពប្រចាំឆ្នាំជាមធ្យមគឺក្នុងចន្លោះពី ៨ ទៅ ៩ អង្សា មានអំណោយផលចំពោះការចិញ្ចឹមសត្វ និងការប្រកបរបរកសិកម្ម ។ ពីវាលទំនាបដល់ដីភ្នំពោរពេញទៅដោយទីវាល វាលស្មៅ គុម្ពោត និងព្រៃឈើ ។ល។ វប្បធម៌គង្វាលសត្វនៅទីនេះមានភាពលេចធ្លោ ។ នៅរដូវរងា ប្រជាជនអ្នកគង្វាលធ្វើការគង្វាលសត្វនៅទីវាលទំនាប រដូវផ្ការីកគង្វាលនៅលើភ្នំ រដូវក្ដៅគង្វាលនៅវាលស្មៅលើភ្នំ ឯរដូវស្លឹកឈើជ្រុះក៏ចាប់ផ្តើមពីដើមមកវិញ ។

វាលស្មៅអ៊ីលីមានផ្លូវទឹកខ្វាត់ខ្វែង ព្រៃឈើញឹកស្អេកស្កះ វាលស្មៅក្រាស់ញឹក លាតសន្ធឹងខ្ពស់ទាបៗចុងដើមស្រល់ត្រៀបត្រាតាមដងព្រៃក នៅមានផ្ទះអ្នកគង្វាលមួយៗ ហ្វូងសត្វពពករសាត់ ដែលជាទីលានចិញ្ចឹមសត្វដ៏សំខាន់នារដូវក្ដៅនៃវាលស្មៅកុងណៃស៊ី ។ រុក្ខជាតិលើវាលស្មៅភ្នំយ៉ាកែវគឺរួមមានស្មៅប្រភេទចម្រុះដ៏ស្រស់ស្អាត និងស្មៅកស្អុះដែលមានកម្ពស់ពី ៥០ ទៅ ៦០ សង្ទីម៉ែត្រ អត្រាគ្របដណ្ដប់មានដល់ ៧៥% ដល់ ៩០% ។ នៅរដូវផ្ការីក ស្មៅដុះខ្ពស់ៗ ផ្ការីកស្គុះស្គាយមានពណ៌ខៀវស្រងាត់ មើលទៅពិតជាស្រស់ស្អាត ។ បរិមាណ ទឹកភ្លៀងប្រចាំឆ្នាំនៅណាឡាធីមានរហូតដល់ ៨០០ មីល្លីម៉ែត្រ ។ វាមានអំណោយទានដល់ការលូតលាស់របស់ស្មៅ ដែលអាចចិញ្ចឹមសត្វបានច្រើន ដូច្នេះវាលស្មៅណាឡាធីមានឈ្មោះជា “សួនចិញ្ចឹមប្រើស” នៅក្នុងប្រវត្តិសាស្ត្រ ។

ផ្លូវដីវាលស្មៅ គំនូរឆ្លាក់លើថ្មអ៊ីលី និងមនុស្សថ្មវាលស្មៅដែលមានពាសពេញនៅវាលស្មៅអ៊ីលីនោះត្រូវបានគេហៅថា “ទស្សនីយភាពវប្បធម៌ធំទាំងបី”នៃវាលស្មៅអ៊ីលី ។ ផ្លូវដីវាលស្មៅក៏ហៅថា“ផ្លូវដីអ៊ូស៊ុន”ដែលមានផ្លូវដីរាប់ម៉ឺនផ្លូវនៅលើវាលស្មៅអ៊ីលីដ៏ធំល្វឹងល្វើយ ផ្លូវដីទាំងនោះភាគច្រើនមានរាងជាពាក់កណ្ដាល ស៊ីឡាំង ហើយលាតសន្ធឹងពីត្បូងទៅជើងមានរាងជាច្រវាក់ ។ ផ្លូវដីនេះមានរាងធំ ហើយខ្ពស់អស្ចារ្យមានភាពទាក់ទាញយ៉ាងខ្លាំង ។ វាមិនគ្រាន់តែជាទស្សនីយភាពមនុស្សធម៌ដ៏វិសេសវិសាលលើវាលស្មៅអ៊ីលីប៉ុណ្ណោះទេ ហើយក៏ជារតនវត្ថុមួយសម្រាប់ស្វែងយល់អំពីវប្បធម៌ដ៏មានតម្លៃរបស់ប្រជាជាតិបុរាណអ៊ីលី ។ ម្យ៉ាងទៀត មនុស្សថ្មដ៏ធំដែលឈរលើវាលស្មៅដែលសម្បូរទៅដោយរុក្ខជាតិក្នុងទឹកនោះ ត្រូវបានគេប្រសិទ្ធនាមថា “មនុស្សថ្មវាលស្មៅ” ។ មនុស្សទាំងនេះ ភាគច្រើនគឺគេជ្រើសរើសយកថ្មទាំងមូលមកដាប់ឆ្លាក់ ។ មើលពីរូបរាងខាងក្រៅនៃមនុស្សថ្មនេះ មានខ្លះឆ្លាក់ជាតួខ្លួនទាំងមូល ក្បាល មុខ ដងខ្លួន ដែលសុទ្ធតែមានភាពរស់រវើក ខ្លួនប្រាណ ទាំងមូលតុបតែងលម្អដោយសម្លៀកបំពាក់ចម្លាក់ល្អប្រណីត មើលទៅហាក់បីដូចជារូបពិតអញ្ចឹង ។

ក្រោយខែមិថុនារៀងរាល់ឆ្នាំ ការគង្វាលជាលក្ខណៈធំបានចូលមកដល់ ដែលជារដូវដ៏សំខាន់បំផុតនៃវាលស្មៅ ពិធីបុណ្យគ្រប់ប្រភេទរបស់អ្នករស់នៅលើវាលស្មៅក៏ប្រារព្ធធ្វើឡើងនៅទីនេះ ។ ដល់ពេលរដូវរងា ព្រិលសមើលដាច់កន្ទុយភ្នែក ដងភ្នំខ្ពស់ទាបបន្តគ្នាវែងរហូតដល់ជើងមេឃ នាចន្លោះភ្នំនិងមេឃមានដើមស្រល់ដែលមានពណ៌បៃតងចាស់ ។ មើលពីចម្ងាយ មានអ្នកទេសចរណ៍ច្រើនកុះករកំពុងជិះស្គីលើទឹកកក ហើយនៅមានក្មេងៗជាច្រើនជិះលើរទេះព្រិលលេងកម្សាន្ត ។



图/新华社 cnsphoto

# ចម្លាក់ថ្មហួយអាន បុប្ផនៃសិល្បៈចម្លាក់ខាងត្បូង

## 惠安石雕：南派雕刻艺术之花

位于福建省东南沿海湄洲湾和泉州湾之间的惠安，依山临海。雕刻艺术产业是惠安的传统产业，也是惠安的支柱产业，同时又是惠安文化产业中的重要组成部分。（ZHONG YAOHUI 译）

ហួយអានស្ថិតនៅឈូងមីចូវនិងឈូងឈៀនចូវតំបន់ដងសមុទ្រអាគ្នេយ៍នៃខេត្តហុកគៀន ដែលជាកន្លែងជាប់នឹងភ្នំនិងសមុទ្រ ។ សិប្បកម្មចម្លាក់គឺជាមុខរបរប្រពៃណីនៅហួយអាន ហើយក៏ជាផ្នែកទ្រទ្រង់សេដ្ឋកិច្ចរបស់ហួយអានដែរ ព្រមនិងជាផ្នែកដ៏សំខាន់នៃឧស្សាហកម្មវប្បធម៌ហួយអានដែរ ។

ចម្លាក់ហួយអានមានប្រវត្តិយូរលង់មកហើយ ។ រាប់ពាន់ឆ្នាំមកនេះ បុព្វបុរសហួយអានបានគួបផ្សំវប្បធម៌ភូមិភាគកណ្ដាល វប្បធម៌មីនយៀក និងវប្បធម៌សមុទ្រជាមួយគ្នា ដោយរក្សានូវលក្ខណៈសិល្បៈសម័យជីនថាង សុងយាន និងម៉េងឆេង ធ្វើឱ្យសិល្បៈចម្លាក់ខាងជើងដែលមានប្រភពដើមពីទន្លេលឿង ក្បាច់រចនាកាន់តែមានភាពលម្អិត ក្លាយជាចម្លាក់សិល្បៈលក្ខណៈខាងត្បូង តាមការរីកចំរើននិងកាន់តែរុងរឿងនៃសិល្បៈសំណង់ វាបានក្លាយជាបុប្ផមួយទងនៃវប្បធម៌ប្រពៃណីចិន ។

កាលពីទសវត្សរ៍ឆ្នាំ ៥០ នៃសតវត្សរ៍មុន “ជីម៉ីអារយាន របស់ឆិនជាកិន” ដែលជាសួនរំលឹកគុណដល់អាណិកជនស្នេហាជាតិជនជាតិចិន នៅនាយសមុទ្រលោកឆិនជាកិន បានបង្ហាញឱ្យឃើញពីទឹកដៃសិល្បៈនៃចម្លាក់ថ្មសម័យទំនើបរបស់ហួយអាន ។ ក្នុងសួនមានចម្លាក់ថ្មខៀវចំនួន ៦៥០ ដែលមានអត្ថន័យបង្ហាញពីប្រវត្តិសាស្ត្របុរាណ ប្រវត្តិសាស្ត្របដិវត្តន៍ និងប្រវត្តិសាស្ត្រនៃការបង្កើតប្រទេសចិនថ្មី គឺជាអច្ឆរិយៈនៃសិល្បៈចម្លាក់ចិន និងត្រូវបានគេចាត់ទុកជាសួនល្បីឈ្មោះសម្រាប់ទស្សនាសិល្បៈចម្លាក់ចិន ។

ក្រៅពីនេះ អ្នកចម្លាក់ហួយអានបានចូលរួមកសាងតំបន់រមណីយដ្ឋានក្នុងនិងក្រៅប្រទេស បង្កើតនូវស្នាដៃដែលមានអត្ថន័យជាប្រវត្តិសាស្ត្រជាច្រើន ដូចជាសសរនៃសាលប្រជុំវិមានសភាប្រជាជនចិននៅក្រុងប៉េកាំង ចម្លាក់លើវិមានរំលឹកវិញ្ញាណក្ខន្ធវីរបុរសប្រជាជនចិន ចម្លាក់ថ្មនៃវិមានរំលឹកវិញ្ញាណក្ខន្ធលោកប្រធាន ម៉ៅ សេទុង ចម្លាក់រូបលោកម៉ៅ សេទុង ក្នុងវ័យក្មេងនៅក្រុងឆាងសាខេត្តហ៊ូណាម ចម្លាក់សួនទីស្មសានលោក ស៊ី ចុងស៊ីន នៅស្រុកហ្វូភីនខេត្តស្រាន់ស៊ី រូបចម្លាក់វិហារជីឡឹក្រុងផានណានប្រទេសម៉ាឡេស៊ី ។ល។







ចម្លាក់ហួយអានរួមមានចម្លាក់ថ្ម ចម្លាក់ឈើ ចម្លាក់ឥដ្ឋ ចម្លាក់ដី ចម្លាក់ព័រ្សឺឡែន ។ល។ ក្នុងនោះ ចម្លាក់ថ្មមានច្រើនប្រភេទ ។ ថ្មសម្រាប់ឆ្លាក់មានដូចជា ថ្មហួកាងយាន ថ្មតាលី ថ្មសាយាន និងថ្មគជំ ។ល។ សិប្បកម្មចម្លាក់ប្រពៃណីហួយអានមានចែកចេញជាប្រភេទសំខាន់ៗ ដូចជាចម្លាក់លេចចម្លាក់អណ្ដែត ចម្លាក់មូល ចម្លាក់ស្រមោល និងចម្លាក់សរសៃ ៥ ប្រភេទ ។

ផលិតផលសិល្បៈចម្លាក់មានប្រយោជន៍ប្រើប្រាស់ច្រើន ដូចជាធ្វើជាសិលាចារឹក រូបចម្លាក់សួនទីក្រុង រចនាបថសំណង់ រូបចម្លាក់ ខាងសាសនា គ្រឿងសង្ហារិម វត្ថុសិប្បកម្ម ។ល។ សិប្បកម្មថ្មចម្លាក់គឺជាផលិតផលសិប្បកម្មកើតចេញពីសិល្បៈ និងការរចនាជាមួយនឹងទឹកដៃឆ្លាក់ ។ ផលិតផលសិប្បកម្មចម្លាក់របស់ហួយអានមានលក្ខណៈសម្បូរបែប រចនាបថចម្លាក់ល្អមានតម្រៃខ្ពស់ខាងសិល្បៈ គឺជាសិប្បកម្មតំណាងឱ្យវប្បធម៌និងសិល្បៈប្រពៃណីហួយអាន ។

បច្ចុប្បន្ន ហួយអានមានក្រុមហ៊ុនចម្លាក់ថ្មជាង ៨០០ មានអ្នកប្រកបរបរនេះជាង ១០ ម៉ឺននាក់។ ស្រុកហួយអានទាំងមូលមានគ្រូជំនាញវិចិត្រសិល្បៈថ្នាក់ជាតិ ២ រូប គ្រូសិល្បៈចម្លាក់ថ្នាក់ជាតិ ៦ រូប គ្រូជំនាញវិចិត្រសិល្បៈថ្នាក់ខេត្ត ១៧ រូប គ្រូសិល្បៈចម្លាក់ថ្នាក់ខេត្ត ៤៨ រូប អ្នករចនាកម្រិតមធ្យមនិងខ្ពស់ជាង ៦០០ រូប អ្នកជំនាញថ្នាក់ដំបូងជាង ២ ១០០ រូប ហើយមានគ្រួសារត្រកូលអ្នកចម្លាក់ ២៣ គ្រួសារ និងកន្លែងបណ្ដុះបណ្ដាលសិប្បកម្មចម្លាក់ចំនួន ៤ ទៀត ។

# ចម្រៀងធំជនជាតិតុង

## 侗族大歌

文/岚　筱

侗族大歌是当今世界上十分罕见的多声部、无指挥、无伴奏民间合唱音乐形式。与侗寨鼓楼、侗乡花桥一起被称为侗族文化的“三大宝”，堪称中国民族音乐的瑰宝。其主要流行于贵州省黔东南州黎平、从江和榕江等县。侗族大歌代表性曲目有《耶老歌》、《嘎高胜》、《嘎音也》、《嘎戏》等。

（ZHONG YAOHUI 译）

ចម្រៀងធំជនជាតិតុងគឺជាតន្ត្រីចម្រៀងច្រៀងរួមគ្នាបែបប្រពៃណីដោយគ្មានភ្លេងអម គ្មានអ្នកបញ្ជាទំនុកភ្លេងនិងមានសំឡេងច្រើនគួបគ្នា ដែលលើពិភពលោកនាពេលបច្ចុប្បន្នកម្រមានបន្សល់ទុក ។ ចម្រៀងធំជនជាតិតុងជាមួយនឹងអគារគូឡៅ និងស្ពានតុងសៀងហ្វួឈៀវត្រូវបានចាត់ទុកជារតនវត្ថុទាំង ៣ ប្រភេទនៃវប្បធម៌ជនជាតិតុង និងជាសម្បត្តិដ៏មានតម្លៃរបស់តន្ត្រីជនជាតិរបស់ប្រទេសចិន ។ ចម្រៀងធំនេះមានការពេញនិយមនៅស្រុកលីភីន ឆុងជាំង និងយុងជាំងមណ្ឌលឈីនតុងណាមនៃខេត្តគួយចូវ ។ បទចម្រៀងដែលតំណាងឱ្យចម្រៀងធំជនជាតិតុងនោះមាន បទយ៉េឡោកី កាកោសឹងកាអ៊ីនយ៉េ កាស ។ល។



យុវជនយុវនារីកំពុងច្រៀងចម្រៀងធំជនជាតិតុងដែលមានសំឡេងច្រើនគួបគ្នាដោយគ្មានភ្លេងអម
姑娘小伙集中在一起唱起多声部无伴奏的侗族大歌

ចម្រៀងធំនេះមានលក្ខណៈ“សំឡេងទោខ្ពស់ សំឡេងច្រើនទាប” ដោយសំឡេងច្រើនច្រៀងជាក្រុម ជាការច្រៀងសម្តែងមានលក្ខណៈស្មុគស្មាញ លក្ខណៈពិសេសគឺសំឡេងច្រើន គ្មានអ្នកបញ្ជាទំនុកភ្លេង និងមិនមានភ្លេងអមជាមួយ ។ ការសម្តែងសំឡេងចាបនិងសត្វល្អិតយំ សំឡេងទឹកហូរពីកំពូលភ្នំដែលជាសំឡេងធម្មជាតិនោះ គឺជាលក្ខណៈពិសេសមួយរបស់ចម្រៀងធំនេះ ហើយវាក៏បង្ហាញឱ្យឃើញថា ចម្រៀងប្រភេទនេះកើតចេញពីធម្មជាតិដែរ ។ ខ្លឹមសារសំខាន់នៃចម្រៀងគឺច្រៀងអំពីធម្មជាតិ ការធ្វើពលកម្ម ស្នេហានិងមិត្តភាព គឺជាសំឡេងស្រុះស្រួលរវាងមនុស្សនិងធម្មជាតិឬមនុស្សនិងមនុស្ស ។ ការច្រៀងសម្តែងចម្រៀងធំជនជាតិតុងត្រូវការយ៉ាងតិចចាប់ពី ៣ នាក់ឡើងទើបអាចសម្តែងបានពិតហើយមនុស្សកាន់តែច្រើនកាន់តែប្រសើរ ។ ស្ទើរតែភូមិដ្ឋាននីមួយៗសុទ្ធតែមានក្រុមចម្រៀងរបស់ខ្លួនភូមិខ្លះមានដល់ទៅ ១០ ក្រុម ។ ការច្រៀងតទល់គ្នា និងការច្រៀងប្រឡងតែងតែធ្វើនៅថ្ងៃបុណ្យចូលឆ្នាំថ្មីរបស់ជនជាតិតុង បុណ្យឃឺស៊ីន និងបុណ្យចូលឆ្នាំចិន ហើយក៏ជាស្ពានសម្រាប់ការឆ្លើយឆ្លងស្នេហារវាងយុវជននិងយុវនារី ។

ការច្រៀងសម្តែងចម្រៀងធំជនជាតិតុង ទាំងទំនុកភ្លេង ខ្លឹមសារ និងទម្លាប់ប្រពៃណីអាចចែកចេញជា ៤ ផ្នែកដូចជា កាធីន កាម៉ា កាសៀង និងកាជី ក្នុងនោះកាធីនជាចំណែកល្អជាងគេ ។ ក្រៅពីនេះ ចម្រៀងធំជនជាតិតុងក៏មានបែងចែកតាមភេទនិងអាយុដែរ ដូចជា“ចម្រៀងធំសំឡេងប្រុស” “ចម្រៀងធំសំឡេងស្រី”និង“ចម្រៀងធំសំឡេងកុមារ” ។ល។ តាមការវិវត្តន៍នៃសម័យកាលគ្រូចម្រៀងជនជាតិតុងបានបន្ថែមអត្ថន័យកាន់តែសម្បូរបែបដល់ក្រុមចម្រៀងធំ ដើម្បីបំពេញតម្រូវការខាងវប្បធម៌ដល់មនុស្សយើង ហើយក៏បានបង្កើតនូវបទចម្រៀង ដែលពិពណ៌នាអំពីជីវភាពរស់នៅនិងភាពសប្បាយរីករាយនាសម័យថ្មីជាច្រើនទៀតដែរ ។

ជនជាតិតុងបានយកចម្រៀងទុកជាចំណីខាងស្មារតី



អ្នកច្រៀងចម្រៀងធំជនជាតិតុងកំពុងច្រៀងចម្រៀងធំជនជាតិតុងនៅមុខផ្ទះថ្មីមួយរបស់អ្នកស្រុក
侗族大歌队几名歌手在一户居民的新居前演唱侗族大歌　新华社 图

ដើម្បីមកកំដរអារម្មណ៍ស្មារតីរបស់ខ្លួន ។ នៅតំបន់ជនជាតិតុងគ្រូចម្រៀងតែងតែត្រូវបានសង្គមចាត់ទុកជាអ្នកមានចំណេះដឹងនិងមានសីលធម៌ខ្ពស់ជាងគេ ហើយត្រូវបានជនជាតិតុងគោរព ។ ពួកគាត់ស្រឡាញ់ចម្រៀង ច្រៀងចម្រៀងតពីមួយជំនាន់ទៅមួយជំនាន់ទៀត ដោយយកការចេះច្រៀង ចេះបទចម្រៀងច្រើនជាមោទនភាពរបស់ខ្លួន ។ គេតែងយកចម្រៀងមកសម្តែងពីមនោសញ្ចេតនានិងអារម្មណ៍រីករាយ កើតទុក្ខឬមិនសប្បាយចិត្តរបស់ខ្លួន ដូចនេះចម្រៀងបុរាណទាំងនេះច្រៀងមិនចេះធុញទ្រាន់ឡើយ ។ ចម្រៀងធំជនជាតិតុងគឺជាផ្នែកដ៏សំខាន់នៃចម្រៀងជនជាតិតុង ការច្រៀងសម្តែងគឺតែងភ្ជាប់ជាមួយនឹងទំនៀមទម្លាប់ បុគ្គលិកលក្ខណៈ ចិត្តសាស្ត្រ និងបរិស្ថានរស់នៅរបស់ជនជាតិតុង គឺជាការកត់ត្រាដោយផ្ទាល់ពីប្រវត្តិសាស្ត្រនិងវប្បធម៌ពិតៗរបស់ជនជាតិតុង ។

ចម្រៀងធំជនជាតិតុងគឺជាសម្បត្តិសិល្បៈបុរាណមួយដែលបន្សល់ដល់បច្ចុប្បន្នរបស់ប្រទេសចិន និងជាភ្លេងចម្រៀងច្រើនប្រភេទរួមជាមួយគ្នា ទៅជាភ្លេងចម្រៀងដ៏ពិរោះរណ្តំ ។ នៅឆ្នាំ ២០០៥ ចម្រៀងធំជនជាតិតុងបានត្រូវដាក់បញ្ចូលក្នុងបញ្ជីឈ្មោះបេតិកភ័ណ្ឌវប្បធម៌អរូបីក្រុមទី ១ ថ្នាក់ជាតិរបស់ប្រទេសចិន ហើយក៏បានត្រូវចាត់ទុកជាសម្បត្តិបន្តផ្សព្វផ្សាយតាមមាត់ និងបេតិកភ័ណ្ឌអរូបីរបស់មនុស្សជាតិនៃប្រទេសចិនផងដែរ ។

文/杨晓梅 蓝 天

# ចំណេះដឹងមូលដ្ឋាន(៤២) 基础知识（41）

一、日常用语

១-ពាក្យប្រើប្រាស់ប្រចាំថ្ងៃ

情景会话：聊聊大湄公河次区域的历史文化名城——大理古城

ការសន្ទនា ៖ និយាយអំពីក្រុងបុរាណតាលី ដែលជាក្រុងប្រវត្តិសាស្ត្រ និងវប្បធម៌ដ៏ល្បីល្បាញនៅមហាអនុតំបន់ទន្លេមេគង្គ ។

nǐ zhī dào dà méi gōng hé cì qū yù yǒu duō shǎo lì shǐ wén huà míng
A. 你知道大湄公河次区域有多少历史文化名
chéng ma
城吗？

ក-តើអ្នកដឹងថា នៅមហាអនុតំបន់ទន្លេមេគង្គមានក្រុងប្រវត្តិសាស្ត្រ និងវប្បធម៌ប៉ុន្មានទេ ?

bù hǎo yì si wǒ zhī dào de bù duō dàn tè bié xiǎng yǒu gèng duō de
B. 不好意思！我知道的不多，但特别想有更多的
liǎo jiě nín néng jiǎng jiang ma
了解，你能讲讲吗？

ខ-គួរឱ្យអៀនខ្មាសណាស់ ! ខ្ញុំស្គាល់មិនសូវច្រើនទេ តែខ្ញុំមានបំណងចង់ស្វែងយល់ឱ្យបានកាន់តែច្រើន តើអ្នកអាចឧទ្ទេសនាមខ្លះៗបានទេ ?

èn nǐ yě bié qiān xū nǐ qù guò de dì fāng bù shǎo wǒ men xū yào
A. 嗯…，你也别谦虚，你去过的地方不少，我们需要
jiāo liú jīn tiān jiù xiān liáo liao yún nán dà lǐ ba
交流，今天就先聊聊云南大理吧！

ក-អ្ហ៎ អ្នកកុំដាក់ខ្លួនពេក អ្នកក៏ធ្លាប់ទៅកន្លែងជាច្រើនដែរ ដូច្នេះយើងអាចផ្លាស់ប្តូរជាមួយគ្នាបាន ហើយនិយាយគ្នាលេងអំពីក្រុងតាលីនៅខេត្តយូណានចុះ !

dà lǐ shì wǒ lǎo jiā ya dà lǐ shì bái zú zì zhì zhōu wǒ mǔ qīn jiù
B. 大理是我老家呀！大理是白族自治州，我母亲就
shì dà lǐ bái zú bái zú zài lì shǐ shàng zhǔ yào jù jū zài lán cāng jiāng zhōng
是大理白族。白族在历史上主要聚居在澜沧江中、
shàng yóu yǐ dōng gǔ dài jiàn lì guò yǐ bái zú wéi zhǔ tǐ de dà lǐ guó xiǎo
上游以东，古代建立过以白族为主体的大理国。小
shí hòu tīng cūn li de lǎo rén shuō jiā xiāng de lán cāng jiāng liú guò xī shuāng
时候听村里的老人说，家乡的澜沧江流过西双
bǎn nà jiù chū guó jìng le míng zi yě gǎi chéng le méi gōng hé wǒ wèn yì
版纳就出国境了，名字也改成了湄公河，我问一
tiáo hé liú wèi shén me liǎng gè míng zi lǎo rén de huí dá hěn yǒu qù dà yì
条河流为什么两个名字？老人的回答很有趣，大意
shì jià chū qù de gū niáng pō chū qù de shuǐ míng zi dāng rán yào suí fū jiā
是：嫁出去的姑娘泼出去的水，名字当然要随夫家
le qí shí zài wǒ men xīn zhōng lán cāng jiāng méi gōng hé shì liú yù
了。其实，在我们心中，澜沧江—湄公河是流域
rén mín de mǔ qīn hé shì bǎ wǒ men jié chéng bāo bō de niǔ dài wǒ men kě
人民的母亲河，是把我们结成胞波的纽带，我们渴
wàng liǎo jiě liú yù zhōng de lì shǐ wén huà mù dì shì zēng jìn bāo bō qíng yì
望了解流域中的历史文化，目的是增进胞波情谊。

ខ-តាលីគឺជាស្រុកកំណើតរបស់ខ្ញុំ ! ក្រុងតាលីស្ថិតនៅក្នុងមណ្ឌលស្វយ័តជនជាតិប៉ៃ ម្តាយខ្ញុំគឺជាជនជាតិប៉ៃ ។ ជនជាតិប៉ៃសំខាន់គឺរស់នៅភាគខាងកើតនៃកំណាត់កណ្តាល និងកំណាត់ខាងលើនៃទន្លេឡានឆាង ហើយកាលពីសម័យបុរាណធ្លាប់មាននគរតាលីមួយដែលមានជនជាតិប៉ៃជាជនជាតិសំខាន់ ។ កាលពីខ្ញុំនៅតូច ធ្លាប់ឮចាស់ៗក្នុងភូមិនិយាយថា ទន្លេឡានឆាងនៅស្រុកកំណើតខ្ញុំនៅពេលហូរកាត់ស៊ីសាំងប៉ាន់ណាក៏ចេញពីព្រំដែនរបស់ប្រទេសចិន ហើយបានប្តូរឈ្មោះទៅជាទន្លេមេគង្គ ។ ខ្ញុំក៏សួរថាហេតុអ្វីបានជាទន្លេមួយមានឈ្មោះពីរ ចម្លើយរបស់ចាស់ៗគឺគួរឱ្យចាប់អារម្មណ៍ដែលមានខ្លឹមសារសង្ខេបថា "នារីដែលរៀបការជាមួយគេ ហាក់ដូចជាទឹកដែលជះចេញទៅ គឺត្រូវប្តូរឈ្មោះទៅតាមប្តីហើយ" ។ តាមពិត ក្នុងដួងចិត្តរបស់យើងខ្ញុំ ទន្លេឡានឆាង-មេគង្គគឺជាទន្លេមាតារបស់ប្រជាជនដែលរស់នៅក្នុងតំបន់តាមបណ្តោយទន្លេនេះ គឺជាចំណងមួយសម្រាប់តភ្ជាប់ប្រជាជននៃបណ្តាប្រទេសផ្សេងៗ យើងមានបំណងចង់ស្វែងយល់អំពីប្រវត្តិសាស្ត្រនិងវប្បធម៌នៃប្រទេសផ្សេងៗនៅតាមដងទន្លេនេះ ដើម្បីបង្កើនចំណងមិត្តភាពរវាងប្រជាជននៃប្រទេសនានា ។

dà lǐ gǔ chéng yǒu nǎ xiē yǔ lì shǐ wén huà yǒu guān de biāo zhì xìng
A. 大理古城有哪些与历史文化有关的标志性
jiàn zhù
建筑？

ក-នៅក្នុងក្រុងបុរាណតាលីមានសំណង់ជានិមិត្តសញ្ញាអ្វីខ្លះ ដែលពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រនិងវប្បធម៌ ?

yǒu nán zhào guó dì shí dài jūn zhǔ quàn fēng yòu zài gōng yuán nián
B. 有南诏国第十代君主劝丰佑在公元856年
xiū jiàn de guó bīn guǎn wǔ huá lóu tā zhōu cháng gōng lǐ gāo duō
修建的国宾馆——五华楼，它周长2.5公里，高30多
mǐ kě yǐ jū zhù yí wàn duō rén wǔ huá lóu zuò wéi guó bīn guǎn de lì shǐ dá
米，可以居住一万多人，五华楼作为国宾馆的历史达
shù bǎi nián zhī jiǔ měi nián sān yuè shí liù nán zhào shí qī de nán zhào wáng
数百年之久，每年三月十六，南诏时期的南诏王
yǐ jí hòu lái dà lǐ guó de dà lǐ wáng dōu huì zài wǔ huá lóu huì jiàn xī nán yí
以及后来大理国的大理王都会在五华楼会见西南夷
gè gè xiǎo guó jūn cháng hé zhòng yào bīn kè cì yǐ jiǔ xí jiā yáo zòu yǐ nán
各个小国君长和重要宾客，赐以酒席佳肴，奏以南
zhào dà lǐ shí qī de yīn yuè hái yǒu shǐ jiàn yú qīng kāng xī nián jiān yǒu
诏、大理时期的音乐；还有始建于清康熙年间、有
gǔ chéng dì yī mén zhī chēng de wén xiàn lóu lóu é xuán guà yún nán tí dū
古城第一门之称的文献楼，楼额悬挂云南提督
piān tú yú kāng xī sì shí nián suǒ tí de wén xiàn míng
偏图于康熙四十年（公元1701年）所题的"文献名
bāng biǎn é liǎng cè yǒu qīng dài wén rén jiǎn míng jiè shào dà lǐ gǔ chéng
邦"匾额，两侧有清代文人简明介绍大理古城
fēng qíng de cháng lián tā men dōu shì dà lǐ gǔ chéng de lì shǐ wén huà yìn jì
风情的长联，它们都是大理古城的历史文化印记。

ខ-មានសណ្ឋាគាររដ្ឋឈ្មោះ"វិមានអ៊ូហ្វា"ដែលសាងសង់ដោយស្តេចជំនាន់ទី ១០ ព្រះនាមឈីនហ្វឹងយូវនៃនគរណានចាវនៅឆ្នាំ ៨៥៦ ។ វិមានអ៊ូហ្វានេះមានបរិមាត្រ ២,៥ គីឡូម៉ែត្រ និងកម្ពស់ជាង ៣០ ម៉ែត្រ ហើយមនុស្សអាចស្នាក់នៅបានជាងមួយម៉ឺននាក់ ដែលធ្លាប់ធ្វើជាសណ្ឋាគាររដ្ឋអស់រាប់រយឆ្នាំ ។ នៅថ្ងៃទី ១៦ ខែ ៣ រៀងរាល់ឆ្នាំតាមចន្ទគតិចិន ស្តេចនគរណានចាវនិងអគ្គមហេសី ព្រមនិងស្តេចតាលីនៅជំនាន់ក្រោយៗតែងតែជួបសវនាការជាមួយស្តេចនិងភ្ញៀវកិត្តិយសដែលយាងនិងអញ្ជើញមកពីប្រទេសតូចៗនៅភាគនិរតី ហើយនិងប្រោសប្រទានសុរានិងអាហារសម្រាប់ជប់លៀងភ្ញៀវ និងឱ្យក្រុមសិល្បករប្រគំតន្ត្រីណានចាវឬតាលី ។ ក្រៅពីនេះ នៅមាន"វិមានវិនសៀន"ដែលសាងសង់ឡើងនៅសម័យស្តេចខាងស៊ីរជ្ជកាលឆេង និងបានត្រូវគេសន្មតជា"ខ្លោងទ្វារទី ១"របស់ក្រុងបុរាណ ។ នៅមុខវិមាននេះមានព្យួរស្លាកដែលចារពាក្យដោយមន្ត្រីរាជការប្រចាំយូណានលោក ភៀន ធូ នៅឆ្នាំ ១៧០១ ដែលមានខ្លឹមសារថា "រដ្ឋល្បីឈ្មោះខាងកំណត់ត្រាប្រវត្តិសាស្ត្រ" ហើយនៅសងខាងស្លាកមានសរសេរជាពាក្យទំនឹមរបស់អ្នកប្រាជ្ញរជ្ជកាលឆេង ដែលបានកត់ត្រាអំពីទំនៀមទម្លាប់ប្រពៃណីនៃក្រុងបុរាណតាលី និងជាស្លាកស្នាមវប្បធម៌និងប្រវត្តិសាស្ត្រដ៏សំខាន់របស់ក្រុងបុរាណមួយនេះ ។

shì de hái yǒu zuò luò yú cāng shān jiǎo xià ěr hǎi biān de chóng shèng
A. 是的。还有坐落于苍山脚下洱海边的崇圣
sì sān tǎ yě shì hè hè yǒu míng quàn fēng yòu tǒng zhì nán zhào shí qī chóng fó
寺三塔也是赫赫有名。劝丰佑统治南诏时期，崇佛
zhī fēng tè bié xīng shèng fó sì biàn bù yún nán jìng nèi yǒu xiǎo sì sān qiān dà
之风特别兴盛，佛寺遍布云南境内，有小寺三千，大
sì bā bǎi zhī shuō jù shǐ liào jì zǎi jǐn chóng shèng sì hé sì nèi sān tǎ zài
寺八百之说。据史料记载，仅崇圣寺和寺内三塔在
quàn fēng yòu tǒng zhì shí qī chóng xiū de huā fèi jiù jià zhí huáng jīn
劝丰佑统治时期重修的花费就价值黄金43054
jīn lì shí nián cái jùn gōng gōng chéng zhī hào dà kě xiǎng ér zhī
斤，历时8年才竣工，工程之浩大可想而知。

ក-ហ្នឹងហើយ នៅមានប្រាសាទ ៣ នៅវត្តឆុងស៊ឹង ដែលស្ថិតនៅតាមមាត់បឹងអឺហៃជើងភ្នំឆាងសាន ក៏ជាទីកន្លែងដ៏ល្បីឈ្មោះផងដែរ ។ នៅពេលស្តេចឈីនហ្វឹងយូវគ្រប់គ្រងនគរណានចាវ ព្រះពុទ្ធសាសនាមានប្រជាប្រិយភាពខ្លាំងនៅតំបន់នេះ វត្តអារាមរបស់សាសនាព្រះពុទ្ធមានពាសពេញក្នុងទឹកដីយូណាន ដែលត្រូវបានគេប្រៀបធៀបថា "វត្តតូច ៣ ០០០ និងវត្តធំ ៨០០" ។ តាមកំណត់ត្រាប្រវត្តិសាស្ត្រ គ្រាន់តែនៅក្នុងរជ្ជកាលស្តេចអង្គនេះ វត្តឆុងស៊ឹងនិងប្រាសាទទាំង ៣ ក្នុងវត្តនេះបានចំណាយមាស ២១ ៥២៧ គីឡូក្រាមនិងប្រើពេលអស់រយៈពេល ៨ ឆ្នាំទើបបានបញ្ចប់ការជួសជុលរួចជាស្ថាពរ គ្រាន់តែគិតក៏ដឹងថា មានទ្រង់ទ្រាយដ៏ធំអស្ចារ្យប៉ុណ្ណាដែរ ។

dà lǐ bù jǐn yǒu hòu zhòng de lì shǐ wén huà chén jī hái yǒu zhù míng
B. 大理不仅有厚重的历史文化沉积，还有著名
de fēng huā xuě yuè měi jǐng shì zuì zhí dé qù de lǚ yóu dì
的风花雪月美景，是最值得去的旅游地。



បឹងស៊ីហួនៅស្រុកអឺយាន់ក្រុងតាលី

大理洱源西湖 cnsphoto

ខ-ក្រុងបុរាណតាលីមិនគ្រាន់តែបានបង្កប់នូវអត្ថន័យប្រវត្តិសាស្ត្រនិងវប្បធម៌ដ៏សម្បូរក្រាស់ក្រែលប៉ុណ្ណោះទេ តែនៅមានតំបន់ទេសភាព"ខ្យល់ ផ្កា ព្រិល និងព្រះចន្ទ"ដ៏ស្រស់ស្អាតដែលគួរជាទស្សនាកម្សាន្តទៀតផង ។

dāng rán dà lǐ shì zhōng guó zuì zǎo de lǚ yóu shèng dì wǒ rèn shí
A. 当然，大理是中国最早的旅游胜地。我认识
dà lǐ shì cóng shàng shì jì nián dài mò pāi shè de diàn yǐng wǔ duǒ jīn huā
大理是从上世纪50年代末拍摄的电影《五朵金花》
kāi shǐ de nà shí wǔ duǒ jīn huā de zhǔ tí qǔ dà lǐ sān yuè hǎo fēng
开始的，那时《五朵金花》的主题曲"大理三月好风
guāng chuán biàn le quán zhōng guó jī xuě de cāng shān qīng chè de ěr hǎi hái yǒu
光"传遍了全中国，积雪的苍山、清澈的洱海，还有
hú dié fān fēi de hú dié quán měi jǐng chéng wéi xǔ duō rén xiàng wǎng de dì fāng
蝴蝶翻飞的蝴蝶泉美景成为许多人向往的地方。

ក-ពិតហើយ តាលីជាតំបន់ទេសចរណ៍មុនគេបង្អស់នៅប្រទេសចិន ។ ខ្ញុំស្គាល់តាលីតាមរយៈខ្សែភាពយន្តរឿង"បុប្ផាមាស ៥ ទង" ដែលថតនៅទសវត្សរ៍ឆ្នាំ ៥០ នៃសតវត្សរ៍មុន" ។ កាលណោះបទចម្រៀងសំខាន់នៃខ្សែភាពយន្តនេះដែលមានចំណងជើងថា"ខែមីនារបស់តាលី មានទេសភាពស្រស់ត្រកាល" បានល្បីសុសសាយទូទាំងប្រទេសចិន តំបន់ទេសភាពភ្នំព្រិលឆាងសានដ៏ខ្ពស់ត្រដែត បឹងអឺហៃដ៏ថ្លាឆ្វង់ និងជ្រោះមេអំបៅ ដែលមានមេអំបៅដ៏ច្រើនសន្ធឹកសន្ធាប់ បានក្លាយជាគោលដៅទេសចរណ៍របស់អ្នកទស្សនាជាច្រើនរាប់មិនអស់ ។

xiàn zài de dà lǐ yòu xīn tiān le xǔ duō lǚ yóu jǐng diǎn gèng xiǎn hé
B. 现在的大理又新添了许多旅游景点，更显和
xié měi lì huān yíng shì jiè gè dì de péng yǒu lái dà lǐ gǎn zhī lì shǐ wén
谐美丽。欢迎世界各地的朋友来大理感知历史文
huà xīn shǎng dú tè de fēng huā xuě yuè sì dà měi jǐng hái qǐng pǐn cháng dà
化，欣赏独特的风花雪月四大美景，还请品尝大
lǐ měi shí hé chá yǐn
理美食和茶饮。

ខ-សព្វថ្ងៃ តាលីនៅមានតំបន់ទេសចរណ៍ថ្មីជាច្រើនទៀត ដែលកាន់តែបង្ហាញឱ្យឃើញពីភាពចុះសម្រុងនិងទេសភាពល្អត្រកាល ។ ស្វាគមន៍មិត្តបរទេសមកទស្សនានិងស្វែងយល់អំពីប្រវត្តិសាស្ត្រនិងវប្បធម៌តាលី ចាប់អារម្មណ៍ពីទេសភាព"ខ្យល់ ផ្កា ព្រិល និងព្រះចន្ទ" និងទទួលទាននូវ

ម្ហូបអាហារនិងទឹកតែមានលក្ខណៈពិសេសរបស់តាលី ។

二、文化知识

២-ចំណេះដឹងផ្នែកវប្បធម៌

"រដ្ឋល្បីឈ្មោះខាងកំណត់ត្រាប្រវត្តិសាស្ត្រ" : ការឧទ្ទេសនាមអំពីក្រុងបុរាណតាលី

ក្រុងបុរាណតាលីធ្លាប់ជារាជធានីរបស់នគរណានចាវ(ឆ្នាំ ៧៣៨-៩០២) និងនគរតាលី(ឆ្នាំ ៩៣៧-១២៥៤) ។ កាលពីថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ១៩៨២ ក្រុមប្រឹក្សាកិច្ចការរដ្ឋចិនបានដាក់បញ្ចូលក្រុងបុរាណតាលីក្នុងបញ្ជីឈ្មោះ "ក្រុងបុរាណខាងប្រវត្តិសាស្ត្រនិងវប្បធម៌ទាំង ២៤"ក្រុមទី ១ របស់ចិន ។ នគរណានចាវជារដ្ឋអំណាចពហុជនជាតិដែលបង្កើតឡើងដោយបុព្វបុរសជនជាតិអ៊ី ហើយនគរតាលីជារដ្ឋអំណាចរបស់ជនជាតិប៉ៃ ។ ក្នុងប្រវត្តិសាស្ត្រ ក្រុងបុរាណតាលីជាទីប្រជុំជននិងមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ចនិងវប្បធម៌របស់ជនជាតិប៉ៃ ។ ក្រោមឥទ្ធិពលវប្បធម៌ជនជាតិហាន បានបង្កើតឡើងនូវភាសាប៉ៃដែលសរសេរជាអក្សរហាន និងអក្សរប៉ៃតាមសំនៀងភាសាប៉ៃ ហើយបានត្រូវប្រើប្រាស់ជាដំបូងសម្រាប់ការតែងអត្ថបទនៅសម័យណានចាវ ហើយប្រើប្រាស់ជាទូទៅនៅនគរតាលី តែដោយសារអក្សរផ្លូវការរបស់នគរណានចាវនិងតាលីជាអក្សរចិន ដូច្នេះអក្សរប៉ៃមិនបានត្រូវគេប្រើប្រាស់ជាទូទៅនៅទូទាំងប្រទេសនោះទេ គ្រាន់តែប្រើប្រាស់សម្រាប់ធ្វើការសិក្សាស្រាវជ្រាវប៉ុណ្ណោះ ។

ក្រុងបុរាណតាលីស្ថិតនៅទីរួមមណ្ឌលស្វយ័តជនជាតិប៉ៃ តាលី ចម្ងាយ ១៣ គីឡូម៉ែត្រពីភាគខាងជើងឆៀងខាងលិចស្រុកសៀក្វាន់ខាងកើត ជាប់នឹងបឹងអឺហៃដ៏ថ្លាឆ្វង់ ឯខាងលិចជាប់នឹងភ្នំឆាងសានដ៏ខ្ពស់ស្កឹមស្កៃដែលបានបង្កើតជារចនាសម្ព័ន្ធ"ទឹកបឹងព័ន្ធជុំវិញភ្នំឆាងសាន ភ្នំឆាងសានឱបក្រុងបុរាណនៅកណ្ដាល" ។ ចាប់តាំងពីស្ដេចអ៊ីមូសៀនផ្លាស់រាជធានីនគរណានចាវមកទីនេះនៅឆ្នាំ ៧៧៩ គឺមានប្រវត្តិសាស្ត្រជាង ១២០០ ឆ្នាំទៅហើយ ។ ក្រុងបុរាណតាលីដែលរក្សាទុកមកដល់ពេលនេះ គឺជាក្រុងបុរាណមួយដែលជួសជុលជាថ្មីលើភាពដើមនៃក្រុងដើមរជ្ជកាលម៉េង ដែលមានរាងបួនជ្រុង ខ្លោងទ្វារ ៤ លើកំផែងមានវិមាន ក្រោមកំផែងមានជញ្ជាំងការពារ ។ កំផែងក្រុងសាងសង់ដោយឥដ្ឋ ហើយនៅមានព្រែក ៣ ខ្សែសម្រាប់ជារបាំងធម្មជាតិ ។ ក្នុងក្រុងមានមហាវិថី ៥ លាតសន្ធឹងពីត្បូងទៅជើង និងផ្លូវ ៨ ខ្សែលាតសន្ធឹងពីលិចទៅកើត ដែលបានធ្វើឱ្យក្រុងបុរាណនេះមានរចនាសម្ព័ន្ធដូចក្ដារអុក ។

សព្វថ្ងៃ ក្រុងបុរាណតាលីមានលក្ខណៈសាមញ្ញនិងស្ងប់ស្ងាត់ ដោយមានព្រែកថ្លាឆ្វង់ហូរកាត់គ្រប់ទិសទី ។ ផ្លូវលំក្រាលថ្មខៀវ អណ្ដូងទឹក ដើមឈើ និងរបងផ្ទះបែបបុរាណបានបង្ហាញឱ្យឃើញនូវភាពសាមញ្ញនិងអស្ចារ្យរបស់តាលី ។ គ្រប់ក្រុមគ្រួសារដាំផ្កានិងស្មៅ ផ្កាក្រហមនិងស្មៅបៃតងលូតចេញពីរបង តភ្ជាប់គ្នាជាច្រកជឿងហែមផ្កាជាច្រើនខ្សែ ក្លិនក្រអូបនៃផ្កាសាយភាយពាសពេញទីក្រុង ។ នៅតាមផ្លូវមានហាងលក់ផលិតផលថ្មកែវ ក្រណាត់ជនជាតិប៉ៃ និងវត្ថុសិប្បកម្មធ្វើពីវល្លិ ព្រមទាំងហាងលក់អាហារពិសេសជនជាតិប៉ៃជាដើម ។

វត្តឆុងស៊ឹងគឺជាតំបន់ទេសចរណ៍ខាងប្រវត្តិសាស្ត្រនិងវប្បធម៌នៅជិតក្រុងបុរាណតាលី ។ តាមកំណត់ត្រាប្រវត្តិសាស្ត្រ ព្រះចៅនិងព្រះរាជបុត្រភូមាសម័យបុរាណធ្លាប់ទៅបួងសួងនៅប្រាសាទទាំង ៣ នៃវត្តឆុងស៊ឹង ហើយនៅមានស្ដេចតាលី ៩ អង្គធ្លាប់សាងផ្នួសនៅក្នុងវត្តនេះ ។ ព្រះសង្ឃព្រះនាម"យាន់ហ្វូ"នៃសម័យយានបានចារពាក្យលើស្លាកថា"រដ្ឋសាសនាព្រះពុទ្ធ" ហើយដោយសារនគរតាលីនិងនគរណានចាវ មានជំនឿលើព្រះពុទ្ធសាសនា ក៏បានត្រូវគេហៅថា"នគរបុរាណដ៏អស្ចារ្យ" ។ មិនតែប៉ុណ្ណោះទេ អ្នកទស្សនាក៏អាចជិះកន្ត្រកខ្សែកាបដើរកម្សាន្តនៅភ្នំឆាងសានដែលមានព្រិលពេញមួយឆ្នាំ ជិះនាវាទេសចរណ៍លេងកម្សាន្តលើបឹងអឺហៃដ៏ថ្លាឆ្វង់ និងគយគន់ទេសភាព"ខ្យល់ បុប្ផ ព្រិល និងព្រះចន្ទ"ដ៏ស្រស់ស្អាតនិងអាថ៌កំបាំងផងដែរ ។

(ចប់)

"文献名邦"——大理古城简介

大理古城曾经是南诏国（公元738年—902年）、大理国（公元937年—1254年）的国都所在地。1982年2月8日，中国国务院公布大理古城为中国首批24个历史文化名城之一。南诏国是由彝族先民建立的多民族政权，大理国是以白族为主体的政权。历史上，大理古城作为白族的主要聚居地和政治、经济、文化的中心，在汉文化的影响下，产生了用汉字写白语,读白音的僰（白）文，南诏时已用于写作,广泛使用则是在大理国时期，但由于南诏国和大理国的官方文字都是汉字，僰（白）文没有普及，仅用于学术研究。

大理古城位于大理白族自治州州府所在地——下关北偏西方向13公里，东临碧波荡漾的洱海，西倚常年青翠的苍山，形成了"一水绕苍山，苍山抱古城"的城市格局。从779年南诏王异牟寻迁都到此，已有1200多年的建造历史。现存的大理古城是明朝初年在原城基础上恢复的，城呈方形，开四门，上建城楼，下有卫城，城墙外层是砖砌的，更有南北三条苍山溪水作为天然屏障；城内由南到北横贯着五条大街，自西向东纵穿了八条街巷，整个城市呈棋盘式布局。

现在的古城朴素而宁静，到处流淌着清澈的溪流，青石铺就的小路一直通往小巷的深处，古井、古树和古石砌成的院墙显示着大理的古朴、奇观。家家户户养花种草，各种红花绿草伸出墙外，连成一条条花巷，四时不绝的花香弥漫了整个古城。街边有各种专卖大理石制品、白族扎染布艺、草编等名特产品的店铺和风味十足的白族饮食店。

古城周边的历史文化景点是崇圣寺。史料记载，当年骠国（今缅甸）国王雍羌和王子舒难陀，曾在南诏王异牟寻的陪同下到崇圣寺三塔祈拜敬香，历史上共有九位大理国国王在此出家为僧，元代高僧圆护为崇圣寺手书"佛都"匾，因大理国与南诏国崇尚佛教，被称为"妙香古国"。还可以坐索道游览终年积雪的苍山、坐游艇游览清澈的洱海，感受风花雪月的美景。

（本期完）


ស្នាមញញឹមអង្គរ
吴 哥 的 微 笑
ការវិលត្រលប់មកវិញនៃទេវ នៅក្នុងចម្លាក់
复活凝固在石块上的神话
ការសំដែងដ៏ធំលំដាប់ទីមួយនៅព្រះរាជាណាចក្រកម្ពុជា
柬埔寨第一大歌舞史诗表演
ពេវេលាសំដែង:១៩: ១៥——២០: ២៥ (សំដែងជារៀងរាល់ថ្ងៃ)
表演时间：19:15——20:25（天天上演）
អាស័យដ្ឋានៈ សាលមហោស្រពស្នាមញញឹមអង្គរ (មជ្ឈមណ្ឌលពិធីតាំងពិព័រណ៍អង្គរ-ឃ្សួងយូ)
地址：吴哥微笑大剧院（柬埔寨暹粒吴哥会展中心）
ទំនាក់ទំនងៈ ០៩៧ ៤៥១ ១៧១៧ ០៦៣ ៦៥៥ ០១៦៨
电话： 097 451 1717 063 6550168
គេហទំព័រៈ www.smileofangkor.com
网址：www.smileofangkor.com
E-Mail: market@smileofangkor.com


彩雲之南　神秘之釀
釣魚臺
国宾馆
国宴特供酒
Two hundred years ago,
French missionaries discovered this
unique highland for growing
excellent wine grapes.
雲南紅
YunnanRedWine
酒 庄
MILE.YUNNAN.CHINA
全汁干型葡萄酒
ក្រេបសុរាហាមបើកបរ
云南红酒庄葡萄酒有限公司
Yunnan Red Chateau Co. , Ltd
www.yunnanhong.com